មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែកុម្ភៈ ឆ្នាំ២០១២

# សៀវភៅមគ្គុទេសក៍
## ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ

សេចក្តីបរិយាយ អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅក្នុងបរិបទច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ និងអំពីមគ្គុទ្ទេសក៍សម្រាប់បង្កើតគម្រោងសង្កេតការណ៍សវនាការ



USAID
FROM THE AMERICAN PEOPLE

EAST · WEST MANAGEMENT INSTITUTE
Program on Rights and Justice (PRAJ)
កម្មវិធីសិទ្ធិ និង យុត្តិធម៌ (ប្រាជ)

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

សៀវភៅមគ្គុទ្ទេសក៍ស្តីពី ″ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការ″ នេះ ជាលទ្ធផលនៃការអនុវត្តគម្រោងសង្កេតការណ៍សវនាការ ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (″ម.ស.ម.ក″)។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺកម្ពុជាជាព្រះរាជាណាចក្រមួយ គ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាព ទទួលបានអំណាចឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ ម.ស.ម.ក មានគោលបំណងចង់បាននីតិរដ្ឋ ជាជាងនិទណ្ឌភាព ចង់បានស្ថាប័នរឹងមាំ ជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយម ដោយក្នុងនោះភាពចម្រុះត្រូវបានទទួលយក និងសាទរ ជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបសត្វព្រាបស ហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវ ជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ ព្រមទាំងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅទូទាំងប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ គេហទំព័រ www.cchrcambodia.org។

## សេចក្តីថ្លែងអំណរគុណ

សៀវភៅមគ្គុទ្ទេសក៍នេះ កើតចេញពីកិច្ចឧបត្ថម្ភគាំទ្រដ៏សប្បុរសពីសំណាក់ប្រជាពលរដ្ឋអាមេរិកាំង តាមរយៈទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍអន្តរជាតិនៃសហរដ្ឋអាមេរិក (ទ.អ.ស.អ)។ ខ្លឹមសារនៃរបាយការណ៍នេះ ជាការទទួលខុសត្រូវរបស់ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ ទ.អ.ស.អ រដ្ឋាភិបាលសហរដ្ឋអាមេរិក ឬវិទ្យាស្ថានគ្រប់គ្រងបច្ចឹមបូព៌ាឡើយ។

# មាតិកា


**សេចក្តីផ្តើម** ........ 2

**ផ្នែកទី១ ៖ ការជំនុំជម្រះដោយយុត្តិធម៌** ........ 4

នីតិរដ្ឋ ........ 4

ការជំនុំជម្រះដោយយុត្តិធម៌ជាអ្វី? ........ 4

តើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានការពារជាលក្ខណៈអន្តរជាតិ តាមរបៀបណា? ........ 5

តើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានការពារដោយច្បាប់កម្ពុជា តាមរបៀបណា? 6

តួនាទីរបស់តុលាការក្នុងការអនុវត្តនីតិរដ្ឋ និងសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌ ........ 8

សេចក្តីសង្ខេបអំពីប្រព័ន្ធតុលាការកម្ពុជា ........ 8

**ផ្នែកទី២ ៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌** ........ 11

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ........ 11

សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យារពេល ........ 12

សិទ្ធិមានសេរីភាព ........ 13

សិទ្ធិទទួលបានជំនួយពីមេធាវី ឬស្វ័យការពារ ........ 15

សិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី ........ 17

សិទ្ធិទទួលបានព័ត៌មានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ........ 19

សិទ្ធិពាក់ព័ន្ធនឹងភស្តុតាង៖ សិទ្ធិទទួលដឹងឮភស្តុតាងដើម្បីការរៀបចំការពារក្តី ........ 20

សិទ្ធិទទួលបានការជំនុំជម្រះ ពីតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ........ 21

សិទ្ធិមានវត្តមាននៅក្នុងសវនាការ ........ 23

សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ........ 25

សិទ្ធនៅស្ងៀម ........ 27

សិទ្ធិរួចផុតពីការដាក់ខ្លួនក្នុងការចោទប្រកាន់ ........ 27

សិទ្ធិពាក់ព័ន្ធភស្តុតាង៖ សិទ្ធិហៅ និងសាកសួរសាក្សី ........ 29

សិទ្ធិនិយាយសម្តីចុងក្រោយ ........ 31

សិទ្ធិទទួលបានសាលក្រមក្នុងរយៈពេលមួយសមរម្យ ........ 31

សិទ្ធិទទួលបានសាលក្រមដែលមានសំអាងហេតុ ........ 32

សិទ្ធិនៅពេលផ្តន្ទាទោស ............ 32
ការហាមឃាត់ចំពោះការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ ............ 34
ការហាមឃាត់ការវិនិច្ឆ័យទោសពីរដង ............ 36
សិទ្ធិរបស់អនីតិជន ............ 37
អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ............ 38
ការឃុំខ្លួនអនីតិជន - ការឃុំខ្លួនបណ្តោះអាសន្ន ............ 39
សិទ្ធិទទួលបានជំនួយពីមេធាវី ............ 40
សិទ្ធិនៃជីវភាពឯកជន ............ 41
ការឃុំខ្លួនអនីតិជន - ការឃុំខ្លួនក្រោយសវនាការ ............ 41
**ផ្នែកទី៣ ៖ ការសង្កេតការណ៍សវនាការ ............ 43**
**ក. ការរៀបចំមុនពេលសង្កេតការណ៍សវនាការ ............ 43**
គោលដៅ ............ 44
សិទ្ធិសំខាន់ៗដែលជ្រើសរើសសម្រាប់ការសង្កេតការណ៍សវនាការ ............ 46
ការជ្រើសរើសសវនាការ ............ 46
ការជ្រើសរើសមន្ត្រីសង្កេតការណ៍សវនាការ ............ 46
ការផ្តល់ព័ត៌មានដល់មន្ត្រីសង្កេតការណ៍សវនាការ ............ 47
ការអនុវត្តដ៏ល្អបំផុត៖ ការជូនដំណឹងដល់តុលាការ អំពីការសង្កេតការណ៍សវនាការ ............ 48
ការវាយតម្លៃខាងហានិភ័យសុវត្ថិភាព ............ 48
**ខ. ការអនុវត្តការសង្កេតការណ៍សវនាការ ............ 48**
តារាងសង្កេតការណ៍សវនាការ ............ 49
ការចូលទៅកាន់បន្ទប់សវនាការ ............ 49
ការធ្វើកំណត់ត្រា ............ 51
ការមិនធ្វើអន្តរាគមន៍ក្នុងដំណើរការជំនុំជម្រះ ............ 51
**គ .ប្រព័ន្ធផ្ទុកទិន្នន័យ ............ 52**
**ឃ. កិច្ចពិភាក្សា និងការតស៊ូមតិ ............ 52**
**ង .ការវាយតម្លៃដំណើរការសង្កេតការណ៍សវនាការ ............ 54**
**សេចក្តីសន្និដ្ឋាន ............ 55**

គន្ថនិទ្ទេស ..................................................................................................................56
ឧបសម្ព័ន្ធទី១ ៖ តារាងសង្ខេតការណ៍សវនាការ..................................................................58
ឧបសម្ព័ន្ធទី២ ៖ ក្រមសីលធម៌មន្ត្រីសង្ខេតការណ៍សវនាការ ...............................................79

# តំនូសតាង

គំនូសតាង ១ ៖ ការបែងចែកអំណាច ....9
គំនូសតាង ២ ៖ ឋានានុក្រមនៃតុលាការកម្ពុជា ....10

# ករណីសិក្សា

ករណីសិក្សាទី១ ៖ សំណុំរឿង ០០១ - អ.វ.ត.ក និងសវនាការរបស់ឌុច ....14
ករណីសិក្សាទី២ ៖ ករណីលោក មឿង សុន ....35
ករណីសិក្សាទី៣ ៖ គម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ....45
ករណីសិក្សាទី៤ ៖ តារាងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ....49
ករណីសិក្សាទី៥ ៖ ការសរសេររបាយការណ៍ និងកិច្ចពិភាក្សា - តឹកតាងនៃវឌ្ឍនភាព ....54

# សេចក្ដីផ្ដើម

ដំណើរការប្រកបដោយឯករាជ្យភាព និងប្រសិទ្ធភាព នៃស្ថាប័នតុលាការ គឺជាចំណុចស្នូលនៃកិច្ចការពារ និងការពង្រឹងការគោរពសិទ្ធិមនុស្សនៅកម្ពុជា។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") បានទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចដែលមានចែងនៅក្នុងលិខិតូបករណ៍អន្តរជាតិនានាដែលពាក់ព័ន្ធ។ នេះគឺរាប់ទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានឲ្យនិយមន័យយ៉ាងជាក់លាក់ នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយថាជា *«សិទ្ធិដែលអនុញ្ញាតឲ្យជនជាប់ចោទគ្រប់រូប ទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ ពីតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ហើយដែលត្រូវបានបង្កើតឡើងដោយច្បាប់ ។»*

ក្នុងស្រទាប់គោលនយោបាយវិញ គេឃើញថា ការបង្កើតស្ថាប័នតុលាការមួយ ដែលដំណើរការបានត្រឹមត្រូវ នៅតែជាសសរគោលដ៏សំខាន់នៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ត្រូវបានតម្រង់ទិស ដោយយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៃរាជរដ្ឋាភិបាលកម្ពុជា។ គោលដៅមួយនៃយុទ្ធសាស្ត្រនេះគឺ *«បង្កើតឲ្យបាននូវវិស័យច្បាប់ និងយុត្តិធម៌មួយ ដែលរឹងមាំ និងអាចជឿជាក់បាន»* ហើយក្នុងនោះទៀតសោត *«ការបែងចែកអំណាច »* នៅតែជាសសរទ្រូងនៃស្ពានរបស់រដ្ឋាភិបាល ឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យសេរី ។ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពដល់ការពង្រឹងវិស័យច្បាប់ និងប្រព័ន្ធតុលាការ ដូចមានចែងក្នុងគោលដៅទី៧ នៃយុទ្ធសាស្ត្ររបស់ខ្លួន។ មកដល់ត្រង់នេះ ការទទួលស្គាល់ដោយរាជរដ្ឋាភិបាល គឺជាមធ្យោបាយសម្រាប់វាយតម្លៃលើសកម្មភាពអនុវត្តន៍ នៅក្នុងវិស័យច្បាប់ និងយុត្តិធម៌ ដើម្បីដាក់ចេញនូវអនុសាសន៍ជាក់ស្តែង ក្នុងគោលបំណងកែលំអដំណើរការរបស់វិស័យនេះ។ ផ្នែកសំខាន់នៃការសង្កេតការណ៍ស្ថាប័នតុលាការ គឺការប្រមូល និងវិភាគទិន្នន័យ ដើម្បីកំណត់អំពីភាពខ្លាំង និងភាពខ្សោយនៅក្នុងប្រព័ន្ធយុត្តិធម៌ ក្នុងបំណងជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយអន្តរជាតិ ក្នុងការពង្រឹង និងកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ។

នៅខែសីហា ឆ្នាំ២០០៩ ម.ស.ម.ក បានចាប់ផ្តើមអនុវត្ត «គម្រោងសង្កេតការណ៍សវនាការ» ក្នុងគោលបំណងសង្កេតសវនាការព្រហ្មទណ្ឌនៅកម្ពុជា ដូចជា នៅសាលាដំបូងរាជធានីភ្នំពេញ និងសាលាដំបូងខេត្តកណ្តាល ដើម្បីវាយតម្លៃទៅលើការគោរពបទដ្ឋានយុត្តិធម៌ដែលមានចែងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិដោយតុលាការនីមួយៗ និងផ្តល់ជាអនុសាសន៍ជាក់ស្តែង ដើម្បីលើកកំពស់ការគោរព និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ លើសពីនេះ គម្រោងសង្កេតការណ៍សវនាការ ប្រើប្រាស់ទិន្នន័យ និងការរកឃើញ ជាមូលដ្ឋានសម្រាប់កិច្ចពិភាក្សាជាមួយតុលាការដែលបានសង្កេត និងដៃគូពាក់ព័ន្ធដទៃទៀតក្នុងវិស័យយុត្តិធម៌។ ព័ត៌មានដែលប្រមូលបានតាមរយៈការសង្កេតការណ៍នេះ ត្រូវបានរក្សាទុកជាឯកសារយោងសម្រាប់ការអនុវត្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ម.ស.ម.កបានរកឃើញថា ការសង្កេតសវនាការ និងការប្រមូលទិន្នន័យដែលមានបរិមាណ និងពីការអនុវត្តជាក់ស្តែង បង្កើតបានជាមូលដ្ឋានដ៏រឹងមាំសម្រាប់ការតស៊ូមតិដែលផ្អែកលើភស្តុតាងច្បាស់លាស់ ដើម្បីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ពាក់ព័ន្ធនឹងការបង្កើតគម្រោងសង្កេតការណ៍សវនាការនៅកម្ពុជា ម.ស.ម.ក បានតាក់តែងសៀវភៅមគ្គុទ្ទេសក៍ស្តីពី "ការសង្កេតការណ៍សវនាការ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌" នេះ

ឡើង (តទៅហៅថា "សៀវភៅមគ្គុទ្ទេសក៍") ដើម្បីជាមគ្គុទេសក៍តម្រង់ទិសដល់ការបង្កើតកម្មវិធីសង្កេតការណ៍សវនាការនៅកម្ពុជា ។ សៀវភៅមគ្គុទ្ទេសក៍មួយនេះ ត្រូវបានចែកចេញជាបីផ្នែក៖

ផ្នែកទី១ នៃសៀវភៅមគ្គុទ្ទេសក៍នេះ បរិយាយអំពីមូលដ្ឋានច្បាប់ជាតិ និងអន្តរជាតិ ដែលធានាការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ផ្នែកនេះពិភាក្សាអំពីគោលគំនិតនៃ "នីតិរដ្ឋ" និងតួនាទីរបស់ស្ថាប័នតុលាការ ក្នុងកិច្ចការពារនិងពង្រឹងការអនុវត្ត "នីតិរដ្ឋ" និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និង ព្រមទាំងបរិយាយអំពីប្រព័ន្ធតុលាការកម្ពុជា ។

ផ្នែកទី២ ផ្តល់ព័ត៌មានលំអិតជុំវិញសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងពន្យល់អំពីទិដ្ឋភាពសំខាន់ៗនៃសិទ្ធិទាំងនេះ។ ផ្នែកនេះសង្ខេបអំពីលិខិតូបករណ៍ច្បាប់ជាតិ និងអន្តរជាតិ ដែលធានាដល់សិទ្ធិមនុស្សជាមូលដ្ឋានទាំងនេះ ។

ផ្នែកទី៣ ផ្តល់នូវការណែនាំអំពីដំណើរការជាក់ស្តែងនៃការសង្កេតការណ៍សវនាការ ដែលជាដំណើរការមួយ មានសារៈសំខាន់សម្រាប់កិច្ចការពារសិទ្ធិមនុស្ស និងបឋមភាពនីតិរដ្ឋ ។ ម.ស.ម.ក ទទួលស្គាល់ថា ស្ថាប័នសង្កេតការណ៍ផ្សេងៗគ្នា ធ្វើការសង្កេតការណ៍សវនាការ ដោយឈរលើមូលហេតុខុសៗគ្នា ហើយដែលមូលហេតុខ្លះអាចជះឥទ្ធិពលទៅលើរបៀបរបបនៃការសង្កេតការណ៍សវនាការ ដូច្នេះនាំឲ្យបែបបទសង្កេតការណ៍សវនាការទាំងនោះ ពុំដូចគ្នាទៅនឹងរបៀបសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏ផ្នែកនេះ នៅតែជាឯកសារព័ត៌មានដ៏មានតម្លៃ សម្រាប់បណ្តាស្ថាប័នទាំងឡាយណា ដែលមានបំណងចង់បង្កើតកម្មវិធីសង្កេតការណ៍សវនាការ ។

ម.ស.ម.ក មានកិច្ចខិតខំប្រឹងប្រែងជាពិសេស ដើម្បីកំណត់អំពីគោលដៅអ្នកអាននៃសៀវភៅមគ្គុទ្ទេសក៍នេះ។ ដូច្នេះ សៀវភៅមគ្គុទ្ទេសក៍នេះត្រូវបានរៀបចំឡើងសម្រាប់មេធាវី អ្នកការពារសិទ្ធិមនុស្ស និងអង្គការសិទ្ធិមនុស្សនានា ដែលកំពុងអនុវត្ត ឬមានបំណងអនុវត្តការសង្កេតការណ៍សវនាការ ។ ម.ស.ម.កសម្រេចបោះពុម្ពផ្សាយសៀវភៅមគ្គុទ្ទេសក៍នេះឡើង ក្នុងគោលបំណងចែករំលែកចំណេះដឹង ព្រមទាំងបទពិសោធន៍ពាក់ព័ន្ធនឹងការសង្កេតការណ៍សវនាការ និងដើម្បីពង្រឹងកិច្ចការពារ និងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងរដ្ឋបាលយុត្តិធម៌មួយដ៏ត្រឹមត្រូវនៅកម្ពុជា តាមរយៈការសង្កេតការណ៍សវនាការព្រហ្មទណ្ឌ ។

# ផ្នែកទី១ ៖ ការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាសិទ្ធិមួយដ៏មានសារៈសំខាន់ និងត្រូវបានទទួលស្គាល់ជាសាកល។ សិទ្ធិនេះជាសមាសភាពមួយដ៏សំខាន់ នៃនីតិរដ្ឋ និងរដ្ឋបាលយុត្តិធម៌ដ៏ត្រឹមត្រូវ។

## នីតិរដ្ឋ

នីតិរដ្ឋសំដៅទៅលើគោលការណ៍ ដែលសមាជិកទាំងអស់នៃសង្គម ត្រូវគោរពច្បាប់ ហើយច្បាប់នេះទៀតសោត មានវិសាលភាពគ្របដណ្តប់លើគ្រប់ផលប្រយោជន៍ទាំងអស់ ដែលបម្រើសង្គមជាតិទាំងមូល ដរាបណានីតិរដ្ឋមិនប៉ះពាល់ដល់សិទ្ធិបុគ្គល និងក្រុមដទៃទៀត។ គោលការណ៍នេះមានលក្ខណៈសំខាន់ សម្រាប់សេរីភាព និងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងបង្កើតបានជាមូលដ្ឋានគ្រឹះនៃគ្រប់ប្រព័ន្ធតុលាការទាំងអស់ ។ គោលគំនិតនៃនីតិរដ្ឋនេះ រួមមាន៖

- ឧត្តមភាពនៃច្បាប់
- ច្បាប់ត្រូវបានដឹងឮ និងអាចស្វែងរកបាន ជាសាធារណៈ
- ច្បាប់ស្របជាមួយគោលការណ៍សិទ្ធិមនុស្ស
- ច្បាប់ត្រូវបានអនុវត្តដោយស្មើភាពគ្នា និងដោយមិនរើសអើង ទៅលើបុគ្គលគ្រប់រូប
- ការបែងចែកអំណាច
- ការចៀសវាងអំពើរំលោភបំពានតាមអំពើចិត្ត
- នីតិវិធី និងច្បាប់ មានតម្លាភាព

## ការជំនុំជម្រះដោយយុត្តិធម៌ជាអ្វី?

ការជំនុំជម្រះដោយយុត្តិធម៌ ជាការធានាដល់បុគ្គលណាម្នាក់ ដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌណាមួយ ទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជាការពិត សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសិទ្ធិមួយ ដែលកើតចេញពីសិទ្ធិដ៏ទៃទៀតរួមបញ្ចូលគ្នានៅក្នុងនីតិវិធីច្បាប់ទាំងមូល ចាប់តាំងពីការចាប់ខ្លួនជនសង្ស័យលើកដំបូង រហូតដល់ការប្តឹងតវ៉ាត្រូវបានបញ្ចប់។ ការជំនុំជម្រះដោយយុត្តិធម៌ មានសារៈសំខាន់ មិនត្រឹមតែសម្រាប់ការពារសិទ្ធិជនជាប់ចោទ និងជនរងគ្រោះប៉ុណ្ណោះទេ ថែមទាំងសម្រាប់ធានាដល់រដ្ឋបាលយុត្តិធម៌ឲ្យបានត្រឹមត្រូវផងដែរ ដែលនេះជាផ្នែកមូលដ្ឋាននៃនីតិរដ្ឋ ។

គោលគំនិតនៃការជំនុំជម្រះដោយយុត្តិធម៌ រួមបញ្ចូលនូវការធានា និងដំណើរការទាំងអស់ពាក់ព័ន្ធនឹងបទដ្ឋានអន្តរជាតិនៃនីតិវិធីត្រឹមត្រូវ ដែលមាននៅក្នុងយន្តការច្បាប់អន្តរជាតិ។ ការធានា និងដំណើរការទាំងនេះ រួមបញ្ចូល ប៉ុន្តែមិនកម្រិតនៅត្រឹមប៉ុណ្ណោះ នូវបណ្តាសិទ្ធិ ការហាមឃាត់ និងគោលការណ៍ ខាងក្រោម ៖

- សិទ្ធិទទួលការជំនុំជម្រះជាសាធារណៈ

- សិទ្ធិទទួលបានការជំនុំជម្រះ ដោយគ្មានការពន្យារពេល
- សិទ្ធិទទួលបានព័ត៌មានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិទទួលបានការពន្យល់ពីសិទ្ធិរបស់ជនជាប់ចោទ
- សិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី
- សិទ្ធិទទួលបានជំនួយពីមេធាវី
- សិទ្ធិមានវត្តមាននៅក្នុងសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលំអៀង
- សិទ្ធិពាក់ព័ន្ធនឹងភស្តុតាង (រាប់ទាំងសិទ្ធិហៅ និងសាកសួរសាក្សី)
- សិទ្ធិដឹងឮភស្តុតាង ដើម្បីរៀបចំការពារក្តី
- សិទ្ធិរួចផុតពីការដាក់ខ្លួនក្នុងការចោទប្រកាន់ (សិទ្ធិមិនសារភាព ដោយសារការបង្ខិតបង្ខំ ឬការបញ្ចុះបញ្ចូល)
- ការហាមឃាត់ចំពោះការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ (ការណ៍ដែលត្រូវបានកាត់ទោសពីបទល្មើសមួយ ដែលពុំមែនជាបទល្មើសនៅខណៈដែលប្រព្រឹត្ត)
- ការហាមឃាត់ការវិនិច្ឆ័យទោសពីរដង (ត្រូវបានជំនុំជម្រះទោសលើសពីមួយដងចំពោះបទល្មើសតែមួយ)
- សិទ្ធិទទួលបានសាលក្រមក្នុងរយៈពេលមួយសមរម្យ និង
- សិទ្ធិប្តឹងទៅតុលាការថ្នាក់បន្ទាប់ ដោយឈរមូលដ្ឋានលើអង្គហេតុ និងអង្គច្បាប់

## តើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានការពារជាលក្ខណៈអន្តរជាតិ តាមរបៀបណា?

យោងតាមច្បាប់អន្តរជាតិ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានការពារដោយសេចក្តីប្រកាស កតិកាសញ្ញា និងអនុសញ្ញាមួយចំនួន រួមមាន ៖

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ ("អ.ស.ប") ក្នុងឆ្នាំ១៩៤៨ និង
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៃអ.ស.ប ក្នុងឆ្នាំ១៩៦៦ ហើយបានចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ។

ប្រទេសកម្ពុជាជារដ្ឋសមាជិកនៃអ.ស.ប ហើយក៏ជាភាគីមួយនៃលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗជាច្រើន រួមមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ។[1] លិខិតូបករណ៍ទាំងអស់នេះធានាថា បុគ្គលដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្ម

[1] ប្រទេសកម្ពុជាផ្តល់សច្ចាប័នលើកតិកាសញ្ញអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅឆ្នាំ១៩៩២ ដែលជាលខិតូបករណ៍ដ៏សំខាន់ដែលចងក្រងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមបញ្ចូលទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ សេចក្តីប្រកាស

ទណ្ឌ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ ដោយសាលាក្តីឯករាជ្យ និងមិនលំអៀង[2] និងសិទ្ធិទទួលបានការសន្មតទុកជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់។[3] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ ដាក់កាតព្វកិច្ចឲ្យរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នតុលាការ ធានាគាំពារ និងអនុវត្ត នូវបណ្តាសិទ្ធិទាំងឡាយ ដែលមានចែងនៅក្នុងលិខិតូបករណ៍ទាំងនេះ ។ លើសពីនេះ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ពង្រឹងបន្ថែមនូវសិទ្ធិដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងនៅក្នុងបណ្តាកតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិទាំងឡាយដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។ ដូច្នេះ បទប្បញ្ញត្តិណាមួយនៅក្នុងលិខិតូបករណ៍អន្តរជាតិ ដែលមានការចែងផ្ទុយត្រូវបានចាត់ទុកថាជាការរំលោភបំពានរដ្ឋធម្មនុញ្ញកម្ពុជា ។

## តើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានការពារដោយច្បាប់កម្ពុជា តាមរបៀបណា?

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានការពារដោយច្បាប់កម្ពុជា ទាំងតាមរយៈបទប្បញ្ញត្តិទូទៅ និងបទប្បញ្ញត្តិជាក់លាក់ ដែលត្រូវបានចែងនៅក្នុងលិខិតូបករណ៍មួយចំនួនដូចជា ៖

- រដ្ឋធម្មនុញ្ញ
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ("ក្រមនីតិវិធីព្រហ្មទណ្ឌ) និង
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ("ក្រមព្រហ្មទណ្ឌ") ។

រដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីរបៀបដែលច្បាប់កម្ពុជាទាំងអស់ ត្រូវបានតាក់តែងឡើង បកស្រាយ និងអនុវត្ត។ រដ្ឋធម្មនុញ្ញបានចែងអំពីការធានាជាច្រើន ដែលជារួមបង្កើតបានជាគម្រោងបទដ្ឋាននៃការជំនុំជម្រះក្តីដោយយុត្តិធម៌។ ដូចដែលបានរៀបរាប់ខាងលើ រដ្ឋធម្មនុញ្ញក៏ចែងបញ្ចូលផងដែរ នូវបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស រួមទាំងបទដ្ឋានដែលមាននៅក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (និងយន្តការសិទ្ធិមនុស្សអន្តរជាតិដទៃទៀត ដូចដែលបានរៀបរាប់ខាងលើ) ទៅក្នុងប្រព័ន្ធច្បាប់ជាតិ។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានចែងថា៖

*"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។*

---

ជាសកលស្តីពីសិទ្ធិមនុស្ស មិនត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋណាមួយឡើយ ប៉ុន្តែបទប្បញ្ញត្តិនៃសេចក្តីប្រកាសនេះ ជាច្បាប់ប្រពៃណីអន្តរជាតិ ដូច្នេះមិនទាមទារឲ្យមានការផ្តល់សច្ចាប័នពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឲ្យមានការអនុវត្តឡើយ។

[2] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[3] មាត្រា ១៤(២) នៃនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

*ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។"*

នៅក្នុងសេចក្តីសម្រេចមួយ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានបកស្រាយបទប្បញ្ញត្តិនេះ ថា "*អនុសញ្ញាអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់*" គឺជាផ្នែកមួយនៃច្បាប់ដែលចៅក្រមជំនុំជម្រះត្រូវតែពិចារណា។[4]

មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ បានបង្កើតឲ្យមានសិទ្ធិសម្រាប់ប្រជាពលរដ្ឋខ្មែរ និងគាំពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយធានាថាៈ

- ច្បាប់ហាមរាល់មិនឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។
- ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។
- ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។
- ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ។ អ្នកដែលស់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់។
- ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។
- វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។
- ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

ការធានារដ្ឋធម្មនុញ្ញខាងលើនេះ តំណាងឲ្យបទដ្ឋានសិទ្ធិមនុស្សជាច្រើន ដែលត្រូវបានទទួលស្គាល់ និងចែងនៅក្នុងច្បាប់អន្តរជាតិ ។ បន្ថែមពីលើនេះ មាត្រា ៥១ ១២៨(ថ្មី) ១៣០(ថ្មី) និង ១៣២(ថ្មី) នៃរដ្ឋធម្មនុញ្ញ បានចែងអំពីការបែងចែកអំណាច និងភាពឯករាជ្យនៃតុលាការដែលត្រូវបានធានាដោយព្រះមហាក្សត្រ។ ដោយហេតុនេះ រដ្ឋធម្មនុញ្ញបានចែងអំពីការបង្កើតស្ថាប័នមួយឈ្មោះ «ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម» ដែលស្ថិតក្រោមព្រះរាជធិបតីភាពនៃព្រះមហាក្សត្រ និងមានអាណត្តិជួយព្រះមហាក្សត្រ ក្នុងការបំពេញតួនាទីជាអ្នកធានាឯករាជ្យភាពរបស់តុលាការ ។

នីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រូវបានចងក្រងជាក្រមនៅក្នុងឆ្នាំ២០០៧។ ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានដាក់ឲ្យអនុវត្តក្នុងបំណងជំនួសបទប្បញ្ញត្តិទាំងឡាយ ស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាល (ច្បាប់អ៊ុនតាក់)។ ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលផ្អែកលើគោលការណ៍ចែងនៅក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តិយ៉ាងលំអិតអំពីរបៀបដែលជនសង្ស័យគួរត្រូវបានគេប្រព្រឹត្តចំពោះ និងតួនាទី និងការទទួលខុសត្រូវរបស់ចៅក្រម ព្រះរាជអាជ្ញា និងភាគីជនជាប់ចោទ ចាប់តាំងពីពេលផ្តើមការស៊ើបអង្កេត រហូតដល់ពេល

[4] សេចក្តីសម្រេចនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

ចាប់ខ្លួន ក្នុងដំណើរការព្រហ្មទណ្ឌទាំងមូល រហូតដល់ការប្តឹងតវ៉ាចុងក្រោយ។ ក្រមនីតិវិធីព្រហ្មទណ្ឌ ចែងយ៉ាងពិស្តារ នូវនីតិវិធីច្បាប់សម្រាប់ការស៊ើបអង្កេត និងការកាត់ទោសបទល្មើសព្រហ្មទណ្ឌ ព្រម ទាំងសិទ្ធិរបស់ជនរងគ្រោះ និងសិទ្ធិបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។

ក្នុងឆ្នាំ២០០៩ ក្រមព្រហ្មទណ្ឌត្រូវបានប្រកាសឲ្យប្រើ។ ក្រមនេះបានចែងអំពី ចំណាត់ថ្នាក់នៃបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ គោលការណ៍នៃការដាក់ទោស យុត្តាធិការនៃតុលាការ និងបទល្មើសព្រហ្មទណ្ឌជាច្រើន រួមទាំងបទល្មើសថ្មីៗ ដែលពុំមានចែងនៅក្នុងច្បាប់កម្ពុជាពីមុនមក ។ បទប្បញ្ញត្តិទូទៅនៅក្នុងគន្ថីទី១នៃក្រមព្រហ្មទណ្ឌ បានចូលជាធរមានកាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ ។ បទប្បញ្ញត្តិដែលនៅសល់ រួមទាំងបញ្ញត្តិដែលបង្កើតបទល្មើសថ្មីៗ បានចូលជាធរមានកាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ នៅរាជធានីភ្នំពេញ និងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ នៅបណ្តាខេត្តក្រុងដទៃទៀត។

## តួនាទីរបស់តុលាការក្នុងការអនុវត្តនីតិរដ្ឋ និងសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌

តុលាការធ្វើការក្នុងគោលបំណង ២ ទាក់ទងនឹងនីតិរដ្ឋ ។ យោងតាមនីតិរដ្ឋ គ្មានជនណាម្នាក់ត្រូវបានដាក់ទោសឡើយ លើកលែងតែនៅពេលដែលតុលាការមានសមត្ថកិច្ច និងមិនលំអៀងបានសម្រេចលើការបំពានច្បាប់នោះ។ នីតិរដ្ឋក៏តម្រូវផងដែរឲ្យតុលាការធានាថា ច្បាប់ត្រូវបានអនុវត្តដោយស្មើភាព និងគ្មានការរើសអើង ដែលនេះគឺរួមបញ្ចូលទាំងការធានាឲ្យមានការត្រួតពិនិត្យសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅក្នុងគ្រប់ករណីទាំងអស់។ សវនាការព្រហ្មទណ្ឌជាមធ្យោបាយមួយ ដែលអាចឲ្យអាជ្ញាធរមានសមត្ថកិច្ចវិនិច្ឆ័យ ថាតើបុគ្គលម្នាក់ បានបំពានច្បាប់របស់ប្រទេស ឬមួយយ៉ាងណា។ ដំណើរការនៃការវិនិច្ឆ័យនេះត្រូវតែធ្វើឡើងដោយយុត្តិធម៌ និងរួមបញ្ចូលទាំងការសង្កេតទៅលើសិទ្ធិរបស់ជនជាប់ចោទ ដោយផ្តើមពីសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងធានាថាជនជាប់ចោទត្រូវបានផ្តល់ជំនួយ ដើម្បីផ្តល់លទ្ធភាពក្នុងការបញ្ចេញយោបល់ជុំវិញការចោទប្រកាន់ និងការការពារប្រឆាំងនឹងការចោទប្រកាន់នោះ។ ភាពយុត្តិធម៌ជាសសរគ្រឹះនៃដំណើរការទាំងមូល ធានាថាយុត្តិធម៌មានជ័យជំនះ ហើយមានតែបុគ្គលប្រព្រឹត្តបទល្មើសទេ ដែលត្រូវបានផ្តន្ទាទោស និងដាក់ពន្ធនាគារ រីឯបុគ្គលដែលគ្មានកំហុស អាចចូលរួមដោយសេរីក្នុងសង្គមដោយពុំមានការរើសអើងឡើយ ។

## សេចក្តីសង្ខេបអំពីប្រព័ន្ធតុលាការកម្ពុជា

យោងតាមមាត្រា ៥១ នៃរដ្ឋធម្មនុញ្ញ ប្រទេសកម្ពុជាអនុវត្តគោលនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ "ការបែងចែកអំណាច" អនុញ្ញាតឲ្យប្រទេសកម្ពុជាចែកអំណាចជាបី ដែលឯករាជ្យនិងដាច់ដោយឡែកពីគ្នាគឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ អំណាចនីមួយៗដើរតួជាអ្នកពិនិត្យមើលសកម្មភាពរបស់អំណាចដទៃទៀត និងជាកម្លាំងទប់នឹងការបំពានអំណាចណាមួយ។ គំនូសតាង ១ ខាងក្រោមនេះ បង្ហាញអំពីសមាសភាពទាំងឡាយនៃអំណាចនីមួយៗ៖

## គំនូសតាង ១ ៖ ការបែងចែកអំណាច




គំនូសតាង ២ ខាងក្រោមនេះ បង្ហាញពីឋានានុក្រម និងរចនាសម្ព័ន្ធនៃតុលាការកម្ពុជា ដោយបង្ហាញថា គ្រប់រឿងក្តីព្រហ្មទណ្ឌទាំងអស់ ត្រូវបានជំនុំជម្រះជាលើកដំបូងដោយតុលាការខេត្តក្រុង ឬដោយតុលាការយោធា ប្រសិនបទល្មើសពាក់ព័ន្ធនឹងយោធា។ យោងតាមមាត្រា ២៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ករណីបទលហុ និងបទមជ្ឈិមត្រូវបានជំនុំជម្រះដោយចៅក្រមតែម្នាក់ វៀរលែងតែករណីឧក្រិដ្ឋ ដែលតម្រូវឲ្យមានចៅក្រមបីរូប។ សេចក្តីសម្រេចរបស់តុលាការខេត្តក្រុង និងតុលាការយោធា អាចជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដែលបណ្តឹងនេះត្រូវបានជំនុំជម្រះដោយចៅក្រមបីរូប។ បណ្តឹងសាទុក្ខពីរដងអាចធ្វើឡើងទៅតុលាការកំពូល ដែលជាតុលាការថ្នាក់ខ្ពស់បំផុតនៅកម្ពុជា។ បណ្តឹងសាទុក្ខលើកទីមួយទៅតុលាការកំពូល នឹងត្រូវជំនុំជម្រះដោយចៅក្រម ៥ នាក់ ដោយពិនិត្យតែទៅលើអង្គច្បាប់ប៉ុណ្ណោះ រីឯលើកទីពីរនិងជាលើកចុងក្រោយ នឹងត្រូវជំនុំជម្រះដោយចៅក្រម ៩ នាក់ និងពិនិត្យទៅលើទាំងអង្គហេតុ និងអង្គច្បាប់។ បន្ទាប់ពីនេះ គេពុំអាចធ្វើការប្តឹងផ្តល់បន្តទៀតឡើយ។ ទាំងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាធម្មនុញ្ញ ពុំមានអំណាចសើរើសេចក្តីសម្រេចតុលាការឡើយ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអំណាចដាក់ពិន័យ និងតែងតាំងចៅក្រម។ ស្ថាប័ននេះ ធានាភាពឯករាជ្យ និងមិនលំអៀងរបស់ចៅក្រម។ ក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកសម្រេច ថាតើច្បាប់ដែលត្រូវបានតាក់តែងឡើងដោយរដ្ឋសភាកម្ពុជា មានធម្មនុញ្ញភាពដែរឬទេ និងមានអំណាចត្រួតពិនិត្យធម្មនុញ្ញភាពនៃការអនុវត្តច្បាប់។ សេចក្តីសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ណាមួយ មានវិសាលភាពគ្របដណ្តប់ លើគ្រប់តុលាការទាំងអស់នៅទូទាំងប្រទេសកម្ពុជា ។

## គំនូសតាង ២ ៖ ឋានានុក្រមនៃតុលាការកម្ពុជា



# ផ្នែកទី២ ៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

ផ្នែកទី២ នៃសៀវភៅមគ្គុទ្ទេសក៍នេះ វិភាគលើរបៀបរបប និងវិសាលភាព ដែលមាននៅក្នុងច្បាប់ជាតិ និងអន្តរជាតិ ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នីមួយៗ។ ក្នុងគោលបំណងនេះ ជាបឋម ការវិភាគនឹងផ្តោត ទៅលើសិទ្ធិដែលមានចែងក្នុងច្បាប់ជាតិនានា រួមមាន រដ្ឋធម្មនុញ្ញ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ។ នៅខណៈដែលការអនុវត្តច្បាប់អន្តរជាតិមានលក្ខណៈសមស្រប បទប្បញ្ញត្តិនៃកតិកាសញ្ញាអន្តរជាតិ នឹងត្រូវបានអនុវត្ត។

ដើម្បីធានាបាននូវភាពស្របគ្នា និងជៀសវាងការភ័ន្តច្រឡំពីសំណាក់អ្នកអាន វាក្យស័ព្ទ "ជនជាប់ចោទ" នឹងត្រូវបានយកមកប្រើប្រាស់ជាទូទៅក្នុងផ្នែកទី២ នៃសៀវភៅនេះ សម្រាប់សំដៅលើជនសង្ស័យ ជនជាប់ចោទ និងចុងចម្លើយ។ ទោះជាយ៉ាងនេះក្តី អ្នកអានចាំបាច់ត្រូវយល់ឲ្យបានច្បាស់ ពីភាពខុសគ្នានៃបណ្តាវាក្យស័ព្ទទាំងនេះ៖ "ជនសង្ស័យ" គឺជាជនណាម្នាក់ដែលត្រូវបានសង្ស័យ ថាបានប្រព្រឹត្តបទល្មើស ប៉ុន្តែមិនទាន់ត្រូវបានចោទប្រកាន់ជាផ្លូវការនៅឡើយទេ។ រីឯ "ជនជាប់ចោទ" វិញ សំដៅលើបុគ្គលទាំងឡាយណា ដែលត្រូវបានចោទប្រកាន់ជាផ្លូវការនូវបទល្មើសណាមួយ។ ចំណែកពាក្យថា "ចុងចម្លើយ" គឺជាបុគ្គលដែលកំពុងត្រូវបានជំនុំជម្រះក្តីលើបទល្មើសណាមួយ ដែលត្រូវបានចោទប្រកាន់ជាផ្លូវការ។

## សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

**ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

- **មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ** ចែងថា ៖ "*ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ*" ។
- **មាត្រា ១៤ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ "*ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់*"។

ជាទូទៅ បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស រហូតទាល់តែពិរុទ្ធភាពត្រូវបានរកឃើញតាមច្បាប់។ សិទ្ធិទទួលបានការសន្មតទុកជាមុខថាគ្មានទោស ជាសិទ្ធិមូលដ្ឋាន និងជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយ ដែលត្រូវបានបង្កើតឡើងយ៉ាងរឹងមាំ។ សិទ្ធិនេះត្រូវបានបង្កើតឡើង ដើម្បីធានាថាគ្មានបុគ្គលណាម្នាក់ ត្រូវបានដាក់ទោសតាមតែអំពើចិត្ត ដោយសារតែអំពើដែលខ្លួនមិនបានប្រព្រឹត្ត ដោយតម្រូវថា អំពើណាមួយដែលត្រូវបានអះអាងថាធ្វើខុស ត្រូវជំនុំជម្រះដោយតុលាការដែលបង្កើតឡើងដោយច្បាប់ មុននឹងទទួលទណ្ឌកម្ម។ សិទ្ធិនេះក៏ជាប្រភពនៃសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកខ្លួនឯង ឬសារភាពអំពីពិរុទ្ធភាព សិទ្ធិនៅស្ងៀម និងការសន្មតជាប្រយោជន៍ដល់កិច្ចធានា និងដោះលែងពីការឃុំខ្លួនបណ្តោះអាសន្ន ។

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ចែងថា ៖

- ចៅក្រមត្រូវតែរក្សាភាពមិនលំអៀង និងចៀសវាងការវិនិច្ឆ័យរឿងក្តីមុនសេចក្តីសម្រេច។
- មន្ត្រីសាធារណៈ (រួមទាំងប៉ូលីស និងព្រះរាជអាជ្ញា) មិនត្រូវធ្វើសេចក្តីថ្លែងការណ៍ ទាក់ទងនឹងភាពមាន ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទណាម្នាក់ មុនកិច្ចជំនុំជម្រះក្តីត្រូវបានបញ្ចប់ជាស្ថាពរ។
- អាជ្ញាធរត្រូវរារាំងសារព័ត៌មាន មិនឲ្យជះឥទ្ធិពលលើលទ្ធផលនៃរឿងក្តី ដោយធ្វើការវិនិច្ឆ័យទៅលើភាពមាន ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទ។
- គោលបំណងនៃបណ្តឹងព្រហ្មទណ្ឌ គឺពិនិត្យមើលភាពល្មើសដែលអាចកើតមាន និងបង្ហាញពីពិរុទ្ធភាពរបស់ជនល្មើស។
- ប្រសិនបើមានការសង្ស័យណាមួយអំពីពិរុទ្ធភាព ជនជាប់ចោទត្រូវបានសម្រេចថាគ្មានទោស។
- តុលាការមិនគួរសន្មតពិរុទ្ធភាពជនជាប់ចោទ ដោយឈរលើសូចនាករខាងក្រៅឡើយ។

បទប្បញ្ញត្តិដែលហាមឃាត់ "សូចនាករខាងក្រៅនៃពិរុទ្ធភាព" រួមបញ្ចូលទាំងសិទ្ធិជនជាប់ចោទស្លៀកពាក់ស៊ីវិលធម្មតា និងមិនត្រូវដាក់ច្រវ៉ាក់ ឬខ្នោះ ក្នុងពេលជំនុំជម្រះ។ ជនជាប់ចោទគ្រប់រូប មានសិទ្ធិត្រូវបាននាំខ្លួនទៅកាន់តុលាការ ក្នុងរូបភាព និងកិត្តិយសជាជនគ្មានទោស។ នៅពេលដែលជនជាប់ចោទត្រូវបានបង្ខំឲ្យចូលរួមក្នុងសវនាការ ក្នុងឯកសណ្ឋានជាអ្នកទោស ឬជាប់ខ្នោះ ឬច្រវ៉ាក់នោះ អាចនាំឲ្យមានការយល់ថា ជនជាប់ចោទមានពិរុទ្ធភាព ឬក៏ជាឧក្រិដ្ឋជនដ៏គ្រោះថ្នាក់ និងអាចជះឥទ្ធិពលដោយចេតនា ឬអចេតនា ទៅលើការវិនិច្ឆ័យរបស់ចៅក្រមជំនុំជម្រះ នីតិវិធីជំនុំជម្រះ និងលទ្ធផលនៃរឿងក្តី។ អាស្រ័យហេតុនេះ មាត្រា ៥(៥)(ច) នៃប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពន្ធនាគារ ដែលចេញដោយក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៨ បានចែងថា *"អ្នកទោសដែលតម្រូវឲ្យបង្ហាញខ្លួននៅចំពោះមុខតុលាការ ត្រូវអនុញ្ញាតឲ្យស្លៀកពាក់សម្លៀកបំពាក់ស្អាតបាត និងសមរម្យ ផ្ទាល់ខ្លួនរបស់គេ"*។

## សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យារពេល

**ប្រភពនៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

- **មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ** ចែងថា ៖ *"ការចោទប្រកាន់ ការចាប់ខ្លួន ឬការឃុំ ខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។"*
- **មាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា ៖ *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះដោយឥតពន្យារពេលយូរហួស។"*

សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យារពេល ជាការធានាជាអប្បបរមារបស់បុគ្គលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌណាមួយ។ មាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងយ៉ាងច្បាស់អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យារពេល។ លើសពីនេះ សិទ្ធិនេះក៏មានចែងនៅក្នុងច្បាប់ជាតិ ដោយមាត្រា ៣១ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ។ ដូច្នេះ បុគ្គលគ្រប់រូបដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌណាមួយ មានសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យារពេល។ សិទ្ធិនេះមានសារៈសំខាន់ ដោយសារមូលហេតុជាច្រើនដូចខាងក្រោម៖

- សិទ្ធិនេះធានាថា ជនជាប់ចោទដែលត្រូវបានឃុំខ្លួនក្នុងអំឡុងពេលសវនាការ មិនត្រូវបានដកហូតសេរីភាពយូរហួសពីភាពចាំបាច់។
- សិទ្ធិនេះការពារជនជាប់ចោទ ពីការបន្តការឃុំខ្លួន ដោយគ្មានការជំនុំជម្រះ ស្ថិតក្នុងស្ថានភាពមួយមិនច្បាស់លាស់ ទាក់ទងនឹងជោគវាសនារបស់ខ្លួន ក្នុងរយៈពេលមួយអូសបន្លាយ។
- សិទ្ធិនេះកាត់បន្ថយនូវឱកាសបាត់បង់ បំផ្លាញ ឬខូចខាតភស្តុតាង ឬក្នុងករណីសាក្សី សិទ្ធិនេះបង្ការនូវភាពថមថយភាពចងចាំ និងការផ្តល់សក្ខីភាព។
- សិទ្ធិនេះកាត់បន្ថយនូវភាពអយុត្តិធម៌ ដោយធានាថា បុគ្គលគ្មានកំហុស ដែលរងការចោទប្រកាន់ពីបទល្មើស នឹងមិនត្រូវបានបន្តឃុំខ្លួនក្នុងរយៈពេលមួយយូរហួស ដោយសារបទល្មើសដែលខ្លួនមិនបានប្រព្រឹត្ត។

## សិទ្ធិមានសេរីភាព

**ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

- **មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *"បុគ្គលណាដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឲ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជំនុំជម្រះ គឺមិនមែនជាវិធានទូទៅទេ ប៉ុន្តែការឲ្យនៅក្រៅឃុំ ត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះនៅពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តសាលក្រម។"*
- **មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"ជាគោលការណ៍ ជនត្រូវចោទ ត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន ក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកនេះ។"*
- **មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះ ជាការចាំបាច់ ៖*

*១. ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសដើម្បីកុំឲ្យកើតជាថ្មី ។*
*២. ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត។*
*៣. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។*
*៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។*
*៥. ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ។*
*៦.ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលពីបទល្មើស។*

- **មាត្រា ២០៨** ដល់មាត្រា **២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងអំពីថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ។

សិទ្ធិមានសេរីភាព ផ្សាភ្ជាប់ជាមួយនឹងសិទ្ធិទទួលបាន ការសន្មតទុកជាមុនថាគ្មានទោស។ មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបង្កើតឲ្យមានសច្ចធារណ៍ ប្រឆាំងនឹងការឃុំខ្លួនជនត្រូវចោទទាំងឡាយ ដែលកំពុងរង់ចាំការជំនុំជម្រះ ដោយចង្អុលបង្ហាញថា ការឃុំខ្លួនបែបនេះ អាចត្រូវធ្វើឡើង តែនៅក្នុងករណីចាំបាច់ និងពិសេស ដូចចែងនៅក្នុងមាត្រា ២០៥ ដែលបានរៀបរាប់ខាងលើ។

មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថិរវេលា ដែលជនជាប់ចោទម្នាក់អាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងករណីបទឧក្រិដ្ឋ គឺរយៈពេល ៦ ខែ។ ទោះយ៉ាងនេះក្តី ចៅក្រមស៊ើបសួរអាចពន្យារថិរវេលានេះបន្ថែមរយៈពេល ៦ ខែទៀត ដោយភ្ជាប់ជាមួយនឹងដីកាសំអាងហេតុ។ ការពន្យារការឃុំខ្លួនខ្លួននេះ អាចត្រូវធ្វើបានតែចំនួនពីរដងប៉ុណ្ណោះ។

មាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថានីតិជន ដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ដោយរងការចោទប្រកាន់ ពីបទល្មើសមជ្ឈិម មិនអាចត្រូវបានឃុំខ្លួនលើសពីរយៈពេល ៤ខែ ឡើយ ហើយចៅក្រមស៊ើបសួរអាចពន្យារពេល បន្ថែម ២ ខែទៀត ដែលការបន្ថែម



**ករណីសិក្សាទី១ ៖ អ.វ.ត.ក និងសវនាការរបស់ឌុច**

អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានបង្កើតឡើង ដោយកិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីនាំខ្លួនអ្នកដឹកនាំជាន់ខ្ពស់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត នៃបទឧក្រិដ្ឋ និងការរំលោភបំពានធ្ងន់ធ្ងរ ដែលកើតឡើងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៩។ លិខិតូបករណ៍ច្បាប់ដែលអ.វ.ត.ក អនុវត្តរួមមានច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់ប្រពៃណី និងអនុសញ្ញាអន្តរជាតិ ទទួលស្គាល់ដោយប្រទេសកម្ពុជា។

បុគ្គលម្នាក់ក្នុងចំណោមជន ដែលទទួលខុសត្រូវខ្ពស់បំផុត គឺលោក កាំង ហ្គេចអ៊ាវ ហៅ "ឌុច" ដែលជាសមាជិកខ្មែរ

នេះ អាចធ្វើបានតែម្តងប៉ុណ្ណោះ ដោយភ្ជាប់ជាមួយនូវដីកាសំអាងហេតុផងដែរ។ រយៈពេលដែលជនជាប់ចោទ ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពីពាក់កណ្តាលនៃអប្បបរមា នៃទោសដែលច្បាប់បានកំណត់សម្រាប់បទមជ្ឈិមឡើយ។ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះ ត្រូវគិតបញ្ចូលទាំងស្រុង ទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល ស្របតាមមាត្រា ៥១ នៃក្រមព្រហ្មទណ្ឌ ។

យោងតាមមាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជនជាប់ចោទណាម្នាក់ដែលមិនត្រូវបាននាំខ្លួនទៅជំនុំជម្រះនៅក្នុងរយៈពេលសមស្របណាមួយ ជននោះមានសិទ្ធិត្រូវបានដោះលែងពីការឃុំខ្លួន។ ការនេះមិនមែនមានន័យថា ជាការលើកលែងការចោទប្រកាន់នោះឡើយ ជនជាប់ចោទអាចនឹងមិនត្រូវបានឃុំខ្លួន នៅពេលដែលចៅក្រមស៊ើបសួររៀបចំសំណុំរឿង (សូមមើលមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ក្រហម និងជាអតីតប្រធានគុកទួលស្លែង (ស២១) ត្រូវបានរកឃើញថាមានទោសដោយ អ.វ.ត.ក. ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ មនុស្សឃាត និងទារុណកម្ម។ នៅក្នុងសវនាការឌុចបានទទួលស្គាល់ នូវការទទួលខុសត្រូវរបស់ខ្លួន ក្នុងការសម្លាប់អ្នកទោសចំនួនជាង ១២ ០០០ នាក់ នៅក្នុងអំឡុងពេលដែលខ្លួនកំពុងកាន់តួនាទីជាប្រធានគុក ស២១។

អ.វ.ត.កបានសម្រេចថា ដោយសារឌុចត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ខុសច្បាប់ ដោយតុលាការយោធា អស់រយៈពេល ៨ ឆ្នាំ ឌុចត្រូវទទួលបានការបន្ថយទោសរយៈពេល ៨ ឆ្នាំ (ដែលជារយៈពេលឌុចបានបំពេញរួចហើយ) និងការបន្ថយទោសរយៈពេល ៥ ឆ្នាំទៀត ជាការសងជំងឺចិត្ត ទៅនឹងការឃុំខ្លួនខុសច្បាប់ និងការបន្ថយទោសរយៈពេល ៣ ឆ្នាំផ្សេងទៀត ទូទាត់នឹងការឃុំខ្លួននៅអ.វ.ត.ក ។

## សិទ្ធិទទួលបានជំនួយពីមេធាវី ឬស្វ័យការពារ

**ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

- **មាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *"ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិ ៖ ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅគ្រប់ករណីបែបនេះ បើជនជាប់ចោទ គ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។"*
- **មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ** ចែងថា ៖ *"ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។"*
- **មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា ៖ *"ជនជាប់ចោទត្រូវចូលបង្ហាញ*

*ខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។"*

- **មាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"ជំនួយពីមេធាវីត្រូវតែមានដាច់ខាត នៅក្នុងករណីដូចតទៅ៖ ១. ករណីបទឧក្រិដ្ឋ និង ២. កាលណាជនជាប់ចោទជាអនីតិជន។"*
- សូមមើលផងដែរ នូវ**មាត្រា ៩៦ ៩៨ ១៤៣ ១៤៩** និង**មាត្រា ៥១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ។

ជនដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិទទួលបានជំនួយពីមេធាវី។ ជំនួយពីមេធាវី ដើម្បីធានាថា៖

- ជនជាប់ចោទទទួលបានកិច្ចការពារខាងច្បាប់ល្អបំផុត ពីអ្នកជំនាញដែលមានវិជ្ជាជីវៈ។
- ជនជាប់ចោទទទួលបានជំនួយពីបុគ្គលម្នាក់ ដែលមានសមត្ថភាពពន្យល់ និងការពារផលប្រយោជន៍របស់ខ្លួននៅក្នុងតុលាការ។
- ជនជាប់ចោទគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ ហើយភាពយុត្តិធម៌មិនត្រូវបានផ្តល់ដោយមានភាពរើសអើង។

រដ្ឋធម្មនុញ្ញបានផ្តល់ឲ្យប្រជាពលរដ្ឋគ្រប់រូប នូវសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ យោងតាមមាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជំនួយពីមេធាវី ត្រូវតែមានដាច់ខាត ក្នុងករណីបទឧក្រិដ្ឋ ឬជនជាប់ចោទជាអនីតិជន។ តុលាការនឹងចាត់តាំងមេធាវីម្នាក់ ប្រសិនបើជនជាប់ចោទ ពុំទាន់បានជ្រើសរើសមេធាវីដោយខ្លួនឯង។ ប្រសិនបើតុលាការរំលោភលើការអនុវត្តសិទ្ធិទទួលបានជំនួយពីមេធាវីរបស់ជនជាប់ចោទ ជនជាប់ចោទនោះនឹងពុំទទួលបានការជំនុំជម្រះមួយ ដែលស្របទៅតាមគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ឡើយ។ ក្នុងករណីនេះ នៅពេលដែលជនជាប់ចោទប្រឈមមុខនឹងការផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយ ដោយពុំទទួលបានជំនួយពីមេធាវី ឬពុំត្រូវបានប្រាប់អំពីសិទ្ធិក្នុងការទទួលបានជំនួយពីមេធាវីនេះទេ នោះនឹងពុំមានយុត្តិធម៌ទេ ហើយសិទ្ធិរបស់ជនជាប់ចោទក៏ត្រូវបានរំលោភបំពានផងដែរ ។

នៅខណៈដែលជំនួយពីមេធាវី ពុំមានលក្ខណៈដាច់ខាតនៅក្នុងករណីបទល្មើសមជ្ឈិម នៅតែមានការជម្រុញឲ្យគោរពគោលការណ៍ស្មើភាពគ្នា ពោលគឺភាគីទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ ត្រូវបានប្រព្រឹត្តចំពោះដោយស្មើភាពគ្នា ក្នុងបំណងធានាថាភាគីទាំងអស់មានឋានៈស្មើគ្នានៅក្នុងនីតិវិធី ដើម្បីបង្ហាញពីអំណះអំណាងនៅក្នុងអំឡុងពេលសវនាការទាំងមូល។

## សិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី

**ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

- **មាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *"ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិ៖ មានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លងឆ្លើយជាមួយមេធាវី ដែលជ្រើសរើសដោយខ្លួនឯង។"*
- **មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស (...) ជននេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយនឹងបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទី (...)។ ក្រោយការសន្ទនានេះ បុគ្គលនេះអាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរ ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។"*
- **មាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"មេធាវីរបស់ជនត្រូវចោទដែលជាប់ឃុំ អាចប្រាស្រ័យទាក់ទងដោយសេរី ជាមួយនឹងកូនក្តីរបស់ខ្លួន នៅក្នុងពន្ធនាគារ ឬនៅក្នុងមណ្ឌលឃុំខ្លួន ។ ការសន្ទនារវាងមេធាវី និងជនត្រូវចោទមិនត្រូវអាចគេស្តាប់ ឬថតបានទេ។"*
- **មាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ នៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី" ។ មេធាវី ឬលេខាធិការរបស់មេធាវី អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការ ឲ្យធ្វើការចម្លងលិខិតនៃសំណុំរឿងដោយខ្លួនឯងជាអ្នកចេញសោហ៊ុយ និងនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី" ។*

សិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារក្តី ផ្សារភ្ជាប់ជាមួយនឹង "គោលការណ៍ស្មើភាពគ្នា" ពោលគឺ ភាគីជនជាប់ចោទ និងភាគីដើមចោទក្នុងរឿងព្រហ្មទណ្ឌ ទទួលបានការប្រព្រឹត្តស្មើភាពគ្នា ដើម្បីធានាថាភាគីទាំង ២ ទទួលបានឱកាសស្មើគ្នា ក្នុងការរៀបចំ និងបង្ហាញរឿងក្តីរបស់ខ្លួន នៅគ្រប់ដំណាក់កាលនៃនីតិវិធី។ ការបង្កើតឲ្យមានបញ្ញត្តិទាក់ទងនឹងពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ ដើម្បីធានាថា សិទ្ធិរបស់ជនជាប់ចោទម្នាក់ៗ ក្នុងការការពារខ្លួន ត្រូវបានអនុវត្តពិតប្រាកដមែន។ ចម្លើយទៅនឹងសំណួរថាតើពេលវេលាគ្រប់គ្រាន់ដែរឬទេ អាស្រ័យលើកត្តាមួយចំនួន ដែលរួមមាន ភាពស្មុគស្មាញនៃរឿងក្តី ថិរវេលាដែលកំណត់ដោយច្បាប់ជាតិ លទ្ធភាពជនជាប់ចោទទទួលបានជំនួយពីមេធាវី និងភស្តុតាង។ ការអនុវត្តសិទ្ធិនេះត្រូវតែមានតុល្យភាព ជាមួយនឹងសិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលមួយសមរម្យ។ សិទ្ធិនេះតម្រូវឲ្យមានកាតព្វកិច្ចអនុញ្ញាតឲ្យលើកពេលសវនាការតាមសំណូមពរដែលសមហេតុផល ជាពិសេសនៅពេល

ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ ហើយចាំបាច់ឲ្យមានរយៈពេលបន្ថែមសម្រាប់ការពារក្តី។

ការផ្តល់ឲ្យនូវសម្ភារៈរូបវន្តគ្រប់គ្រាន់ រួមមាន ៖

- **សិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងបទចោទប្រកាន់៖** ដូចដែលបានពិភាក្សាខាងលើ នេះជាសិទ្ធិយល់ដឹងពីការចោទប្រកាន់ រួមបញ្ចូលទាំងព័ត៌មានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ដែលគ្មានព័ត៌មានទាំងនេះ ការការពារក្តីមិនអាចធ្វើទៅរួចឡើយ។
- **ការទទួលបានជំនួយពីមេធាវី៖** ជនជាប់ចោទ និងមេធាវីរបស់ខ្លួន ត្រូវបានអនុញ្ញាតឲ្យមានការសន្ទនាជាសម្ងាត់ (មាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- **ការទទួលបានព័ត៌មានត្រឹមត្រូវ៖** ពោលគឺ ជនជាប់ចោទ និងមេធាវីរបស់ខ្លួនអាចទទួលបានឯកសារ និងភស្តុតាងផ្សេងៗ ដែលនឹងជួយសម្រួលដល់ការរៀបចំការការពារក្តី ជួយសម្រាលទោសដែលជនជាប់ចោទអាចនឹងទទួល ឬជួយឲ្យរួចពីការចោទប្រកាន់ (មាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។
- **ទទួលបានអ្នកបកប្រែនៅពេលដែលចាំបាច់៖** មាត្រា ១៤(៣)(ច) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ផ្តល់សិទ្ធិឲ្យជនជាប់ចោទ *"ទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ"*។ មាត្រា ៣៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា *"ក្នុងករណីចាំបាច់ ប្រធានអាចហៅរកអ្នកបកប្រែ"*។ សិទ្ធិទទួលបានអ្នកបកប្រែ បង្កប់នៅក្នុងសិទ្ធិយល់ដឹងពីបទចោទប្រកាន់។ ការបដិសេធមិនផ្តល់អ្នកបកប្រែ គឺការខុសឆ្គងរបស់តុលាការ។
- **ប្រសិនបើចាំបាច់អនុវត្តបទប្បញ្ញត្តិសម្រាប់ជនអសមត្ថភាព៖** មាត្រា ៣៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងបទប្បញ្ញត្តិបន្ថែម ដើម្បីធានាថាជន គ ថ្លង់ អាចទទួលបានឱកាសពេញលេញយល់ដឹងពីនីតិវិធីប្រឆាំងនឹងខ្លួន។ មាត្រានេះចែងថា *"កាលណាសំណួរត្រូវសួរដល់ជនគ ថ្លង់ ក្រឡាបញ្ជីសរសេរសំណួរ ហើយឲ្យសាមីខ្លួនអាន និងឆ្លើយដោយលាយលក្ខណ៍អក្សរ។ ក្នុងករណីសាមីជនមិនចេះអាន ឬមិនចេះអក្សរ ប្រធានសវនាការត្រូវរកអ្នកបកប្រែក្នុងលក្ខខណ្ឌ ដែលមានចែងដោយមាត្រា ៣៣០ (...) ប្រធានសវនាការអាចហៅរកអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជននេះមកបកប្រែ"*។ ការណ៍នេះមានសារៈសំខាន់ ដើម្បីធានាថាផលប្រយោជន៍យុត្តិធម៌ត្រូវបានទទួល។ តុលាការត្រូវចាត់គ្រប់វិធានការណ៍ដែលចាំបាច់ ដើម្បីធានាថា បុគ្គលម្នាក់អាចយល់ដឹងពីបទចោទប្រកាន់ប្រឆាំងនឹងខ្លួន ដោយរាប់បញ្ចូលទាំងសេចក្តីត្រូវការជាពិសេសរបស់ជនត្រូវចោទផ្ទាល់។ ប្រសិនបើតុលាការខកខានមិនបានចាត់វិធានការណ៍នេះ ហើយបណ្តាលឲ្យខកខានមិនបានផ្តល់ឲ្យជនជាប់ចោទ ដែលមានសេចក្តីត្រូវការជាពិសេស នូវឱកាសយល់ដឹងបទចោទប្រកាន់ប្រឆាំងនឹងខ្លួន ឬឱកាសបង្ហាញ ឬយល់ដឹងពីភស្តុតាង ឬសក្ខីភាព ជនជាប់ចោទនោះនឹងមិនទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឡើយ។

## សិទ្ធិទទួលបានព័ត៌មានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

**ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

- **មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទ ឲ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់មកលើខ្លួន។"*
- **មាត្រា ១៤(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *"ជនជាប់ចោទត្រូវទទួលបានព័ត៌មានភ្លាមៗ និងដោយលំអិត អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ។"*

ការអនុវត្តសិទ្ធិទទួលបានព័ត៌មានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ នៅក្នុងដំណាក់កាលទាំងមុន និងក្នុងអំឡុងពេលជំនុំជម្រះ សារៈសំខាន់ដើម្បី ៖

- ធានាថា ជនជាប់ចោទយល់ពីមូលហេតុដែលខ្លួនត្រូវបានកាត់ទោស។
- ធានាថា ជនជាប់ចោទអាចតបតទៅនឹងការឃុំខ្លួនណាមួយ ដែលអាចនឹងកើតមាន នៅក្នុងរយៈពេលមួយឆាប់រហ័សតាមដែលអាចធ្វើបាន ។
- ធានាថា ជនជាប់ចោទមានឱកាសការពារក្តីតាមដែលអាចធ្វើបាន តបនឹងការចោទប្រកាន់ណាមួយប្រឆាំងនឹងខ្លួន ។
- ការពារប្រឆាំងនឹងការចោទប្រកាន់ដែលគ្មានមូលដ្ឋាន។

### ដំណាក់កាលមុនជំនុំជម្រះ៖

មាត្រា១៤(៣)(ក)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តម្រូវឲ្យជនជាប់ចោទមុននឹងត្រូវបាននាំខ្លួនមកកាន់សវនាការ ទទួលបានព័ត៌មានភ្លាមៗ អំពីបទចោទប្រកាន់ព្រហ្មទណ្ឌប្រឆាំងនឹងខ្លួន។ ការទាមទារនេះ ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី។

ការពន្យល់អំពីច្បាប់ពាក់ព័ន្ធ គួរតែត្រូវបានធ្វើឡើងនៅមុនពេលសវនាការ។ ជនជាប់ចោទត្រូវតែមានឱកាសយល់ពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ដើម្បីធានាថាកាតព្វកិច្ចនៅក្នុងមាត្រា ១៤ ត្រូវបានអនុវត្ត។ ប្រសិនបើតុលាការធ្វេសប្រហែសក្នុងការផ្តល់ឱកាសនេះទៅឲ្យជនជាប់ចោទនៅមុនពេលសវនាការ ករណីយកិច្ចត្រូវធ្លាក់ទៅលើតុលាការ ដើម្បីធានាថាតុលាការបានផ្តល់ព័ត៌មាននេះដល់ជនជាប់ចោទ។

### ដំណាក់កាលជំនុំជម្រះ៖

មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងទាក់ទងនឹងសិទ្ធិយល់អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នៅក្នុងដំណាក់កាលជំនុំជម្រះ។ ដើម្បីអនុវត្តកាតព្វកិច្ចដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចៅក្រមជំនុំជម្រះត្រូវតែ៖

- **ប្រកាសពីសំណុំរឿងដែលត្រូវជំនុំជម្រះ៖** តម្រូវការនេះត្រូវបានទាញចេញពីតម្រូវការដែលមានចែងក្នុងមាត្រា ១៤(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។
- **ពន្យល់អំពីបទចោទប្រកាន់ ដោយរួមបញ្ចូលទាំងកាលបរិច្ឆេទ និងទីកន្លែងដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត៖** មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តម្រូវឲ្យ *"ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទ ឲ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់លើខ្លួន"*។ នេះជាការចាំបាច់ណាស់ដែលលក្ខខណ្ឌនេះត្រូវបានបំពេញ ដើម្បីធានាថាជនជាប់ចោទ ឬអ្នកតំណាងរបស់ជននោះ បានទទួលព័ត៌មានត្រឹមត្រូវ ដើម្បីរៀបចំការពារក្តី ។
- **ប្រកាសអំពីភាគីពាក់ព័ន្ធ៖** មាត្រា ៣២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា *"ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់អត្តសញ្ញាណជនទាំងនោះ"*។ ការបង្ហាញអត្តសញ្ញាណនៃភាគីពាក់ព័ន្ធ ចាំបាច់ ដើម្បីធានាថា ជនជាប់ចោទពិតប្រាកដត្រូវបាននាំមកកាន់តុលាការដើម្បីជំនុំជម្រះ និងអ្នកជាប់ពាក់ព័ន្ធដទៃទៀតមានវត្តមាននៅឯសវនាការ ដើម្បីមានឱកាសសាកសួរ និង/ឬ ធ្វើជាអ្នកតំណាង ។

## សិទ្ធិពាក់ព័ន្ធនឹងភស្តុតាង ៖ សិទ្ធិទទួលដឹងពួភស្តុតាងដើម្បីការរៀបចំការពារក្តី

| ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ |
|---|
| ➢ **មាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿង នៅការិយាល័យក្រឡាបញ្ជីនៃតុលាការ នៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។ មេធាវី ឬលេខាធិការរបស់មេធាវី អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការ ឲ្យធ្វើការចម្លងលិខិតនៃសំណុំរឿង ដោយខ្លួនជាអ្នកចេញសោហ៊ុយ និងនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។"* |
| ➢ **មាត្រា ៣៩១ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"អគ្គព្រះរាជអាជ្ញា និងមេធាវីអាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលសវនាការ។"* |
| ➢ **មាត្រា ១២៩ ១៤៥ ១៤៩ ១៧០ ២៥៩** និង **៤២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ**។ |

ដើម្បីអាចមានលទ្ធភាពរៀបចំការពារក្តី តទល់នឹងការចោទប្រកាន់ ភាគីជនជាប់ចោទត្រូវមានសិទ្ធិពិនិត្យមើលភស្តុតាងដែលបានរកឃើញក្នុងអំឡុងពេលស៊ើបអង្កេត និងការវិភាគលើភស្តុតាង ដែលបានរៀបចំដោយព្រះរាជអាជ្ញា។ ភាពស្មើគ្នាក្នុងការទទួលបានភស្តុតាងមុនពេលជំនុំជម្រះ អាចឲ្យភាគីជនជាប់ចោទ វាស់ស្ទង់ស្ថានទម្ងន់នៃភស្តុតាង និងរៀបចំអំណះអំណាងដើម្បីការពារក្តីរបស់ខ្លួនបានល្អពេញលេញ។ សិទ្ធិនេះ មានសារៈសំខាន់ខ្លាំង ក្នុងការផ្តល់លទ្ធភាពដល់ជនជាប់ចោទវាយតម្លៃរឿងក្តីរបស់ខ្លួនថា តើនឹងត្រូវធ្វើការសម្រេចចិត្តការពារភាពគ្មានពិរុទ្ធភាពរបស់ខ្លួន ឬសារភាពកំហុស។

សិទ្ធិដើម្បីអាចត្រួតពិនិត្យសំណុំរឿង មានចែងនៅក្នុងមាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សិទ្ធិទទួលដឹងពួភស្តុតាង រួមមានសិទ្ធិរបស់ភាគីជនជាប់ចោទ ក្នុងការទទួលបានឯកសារពាក់ព័ន្ធនឹងសវនាការ។ សំណុំរឿង គឺជាឯកសារសំខាន់បំផុត។ ចៅក្រមស៊ើបសួររៀបចំសំណុំរឿងដែលមានដីកាចោទប្រកាន់ ដើម្បីបញ្ជូនទៅកាន់តុលាការជំនុំជម្រះ។ សំណុំរឿងមាននូវភស្តុតាងទាំងឡាយដែលប្រមូលបាន ព្រមទាំងសេចក្តីសន្និដ្ឋានរបស់ចៅក្រមស៊ើបសួរផងដែរ។ ជាការចាំបាច់ក្នុងការកត់សម្គាល់ថា មានតែទីប្រឹក្សាច្បាប់តែប៉ុណ្ណោះ ដែលអាចទទួលបានឯកសារសំណុំរឿង ហើយការទទួលយកឯកសារនេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី ដូចដែលមានចែងនៅក្នុងមាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## សិទ្ធិទទួលបានការជំនុំជម្រះ ពីតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង

**ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

- **មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *"ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ ពីសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតដោយច្បាប់ ។"*
- **មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញ** ចែងថា ៖ *"អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ។"*
- **មាត្រា ១៣២ នៃរដ្ឋធម្មនុញ្ញ**ចែងថា ៖ *"ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យភាពនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។"*
- **មាត្រា ៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា ៖ *"សមាជិកនៃសភាស៊ើបសួរ ពុំអាចចូលរួមក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ដែលខ្លួនបានចាត់ការ ក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើមិនដូច្នេះទេ សាលដីកានោះត្រូវចាត់ទុកជាមោឃៈ។"*
- **មាត្រា ២៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា ៖ *"ចៅក្រមណាដែលបានបំពេញមុខងារជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬជាចៅក្រមស៊ើបសួរលើរឿងណាមួយ មិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើពុំដូច្នោះទេ សាលក្រមនឹងត្រូវទុកជាមោឃៈ។"*
- **មាត្រា ៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"តុលាការថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាដើម្បីសម្រេច។ គ្មានបណ្តឹងសុំណាមួយអាចត្រូវដាក់ជូនតុលាការបានទៀតទេ។ គ្មានទឡ្ហីករណ៍ណាមួយអាចត្រូវបានលើកយកមកសំអាងទៀតបានឡើយ។ ព្រះរាជអាជ្ញា និងក្រឡាបញ្ជីមិនត្រូវបានអនុញ្ញាតឲ្យចូលរួមការពិភាក្សាសម្រេចនេះទេ។"*
- **មាត្រា ៥៥៦ និង ៥៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ពាក់ព័ន្ធទៅនឹងការប្តឹងជំទាស់ចិត្តចៅក្រមអសនៈ។

គោលគំនិតសំខាន់នៃការជំនុំជម្រះដោយយុត្តិធម៌ គឺធានាថាការសម្រេចសេចក្តី ដែលជាប់ពាក់ព័ន្ធទៅនឹងសិទ្ធិសេរីភាពរបស់បុគ្គល ត្រូវបានធ្វើឡើងដោយសាលាក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ត្រូវបានបង្កើតឡើងដោយច្បាប់ និងមានភាពឯករាជ្យពីគោលដៅ និងកម្មវត្ថុនយោបាយ។ នៅប្រទេសកម្ពុជា ឯករាជ្យភាព និងភាពមិនលំអៀងរបស់តុលាការ ត្រូវបានធានាដោយមាត្រា ១២៨ ដល់មាត្រា ១៣៥ នៃរដ្ឋធម្មនុញ្ញ។ មាត្រាទាំងនោះចែងថា ៖

- អំណាចតុលាការជាអំណាចឯករាជ្យ (មាត្រា ១២៨)
- អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ (មាត្រា ១២៨)
- អំណាចតុលាការ ត្រូវប្រគល់ឲ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ (មាត្រា ១២៨)
- ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យភាព នៃអំណាចតុលាការ ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ (មាត្រា ១៣២)
- ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន (មាត្រា១២៩)
- មានតែចៅក្រមទេ ដែលមានសិទ្ធិជម្រះក្តី (មាត្រា ១២៩)
- ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន (១២៩)
- អំណាចតុលាការ មិនត្រូវបានផ្តល់ឲ្យអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិឡើយ (មាត្រា ១៣០)

គ្រប់សាលាជម្រះក្តី និងតុលាការ រួមទាំងចៅក្រមផងនោះ ត្រូវតែឯករាជ្យពី៖

- អំណាចនីតិបញ្ញត្តិ និងនីតិប្រតិបត្តិនៃរដ្ឋាភិបាល
- ភាគីដែលពាក់ព័ន្ធនឹងនីតិវិធី
- យន្តការណាមួយរបស់រដ្ឋ

ដើម្បីធានាថា រដ្ឋាភិបាល ឬជនដទៃទៀត ដូចជាបុគ្គលដែលមានទ្រព្យសម្បត្តិ មិនអាចប្រើប្រព័ន្ធយុត្តិធម៌ជាមធ្យោបាយ ដើម្បីបម្រើឲ្យគោលបំណងផ្ទាល់ខ្លួន ដូចជាប្រើតុលាការ ដើម្បីធ្វើទុកបុកម្នេញជនណាដែលមិនឯកភាព ឬធ្វើឲ្យប៉ះពាល់ផលប្រយោជន៍ណាមួយ និងដើម្បីធានាថាយុត្តិធម៌ត្រូវបានផ្តល់ឲ្យ ប្រកបដោយតម្លាភាព ត្រូវតែមានការបែងចែកអំណាចឲ្យដាច់ពីគ្នា និងមិនត្រូវឲ្យមានខ្សែបន្ទាត់មិនច្បាស់លាស់ រវាងអំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការឡើយ ។

សាលាជម្រះក្តី តុលាការ និងចៅក្រម ត្រូវតែមិនលំអៀង។ នេះមានន័យថាចៅក្រមតុលាការ ឬក៏សាលាក្តីមិនត្រូវ៖

- ទទួលផលប្រយោជន៍ ឬជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿងដែលខ្លួនជំនុំជម្រះ
- ប្រកាន់នូវការមិនធ្វើឲ្យខូចប្រយោជន៍ ឬមិនមានទស្សនៈស្មានទុកជាមុន ផ្តោតទៅលើបញ្ហា ឬភាគីដែលពាក់ព័ន្ធ
- បង្ហាញទំនោរទៅរកភាគីណាមួយ

ភាពមិនលំអៀង និងឯករាជ្យភាពនៃតុលាការ ត្រូវថមថយនៅពេលដែលៈ

- ចៅក្រមធ្លាប់មានតួនាទីនៅក្នុងនីតិវិធី ដូចជាធ្លាប់ជាចៅក្រមស៊ើបសួរ ជាសាក្សី ឬប្រសិនជាករណីឧទ្ធរណ៍ ធ្លាប់ជាចៅក្រមសាលាដំបូង។ មាត្រា ៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានហាមប្រាមចៅក្រមយ៉ាងច្បាស់លាស់ ពីការចូលរួមក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌដែលខ្លួនបានចាត់ការ ក្នុងឋានៈជាចៅក្រមស៊ើបសួរបានទេ បើមិនដូច្នេះទេ សាលដីកានោះត្រូវចាត់ទុកជាមោឃៈ។
- ចៅក្រមជាភាគីនៃនីតិវិធី។
- ចៅក្រមមានចំណងមិត្តភាព ទំនាក់ទំនង ជាប់សាច់ញាតិជាមួយភាគីណាមួយនៃនីតិវិធី។
- មានការប្តឹងផ្តល់មិនទាន់ដាច់ស្រាច់ រវាងចៅក្រម ជាមួយនឹងភាគីណាមួយ
- ទំនងជាមានភស្តុតាង ដែលស្តែងឲ្យឃើញពីការជ្រៀតជ្រែកទៅលើការធ្វើសេចក្តីសម្រេចរបស់ចៅក្រម (ឧទាហរណ៍៖ ចៅក្រមទទួលទូរស័ព្ទនៅក្នុងតុលាការ ចាកចេញពីបន្ទប់សវនាការ និយាយទៅកាន់ជនណាម្នាក់ក្នុងពេលពិភាក្សាសម្រេច)។ មាត្រា ៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហាមមិនឲ្យមានបណ្តឹងសុំណាមួយ ត្រូវបានដាក់ជូនតុលាការទៀតទេ នៅពេលតុលាការថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សាដើម្បីសម្រេច ហើយជាពិសេសហាមមិនឲ្យព្រះរាជអាជ្ញា និងក្រឡាបញ្ជី ចូលរួមនៅក្នុងការពិភាក្សាសម្រេចរបស់ចៅក្រម។
- ចៅក្រមទំនងជាបង្ហាញនូវកំហឹងចំពោះភាគី៖ នេះអាចគូសបញ្ជាក់ អំពីភាពលំអៀង ដែលនាំឲ្យមានការទុកចិត្តតិចតួច ពីសំណាក់សាធារណជនទៅលើតុលាការ ។

## សិទ្ធិមានវត្តមាននៅក្នុងសវនាការ

**ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

- **មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"ជនជាប់ចោទត្រូវបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។"*
- **មាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *"ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបត្រូវមានសិទ្ធិត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន។"*
- មើលផងដែរនូវ **មាត្រា ៤៦ ៩៨ ១៤៣ ១៤៩ និង ៥១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ។

ជនជាប់ចោទមានសិទ្ធិមានវត្តមាន នៅក្នុងសវនាការដែលជាប់ពាក់ព័ន្ធនឹងខ្លួន។ ការធ្វើដូច្នេះ នឹងអាចឲ្យជននោះបានស្តាប់ និងជំទាស់ទៅនឹងការចោទប្រកាន់ ព្រមទាំងការពារតទល់នឹង

បទចោទប្រកាន់ប្រឆាំងនឹងខ្លួន។ ដើម្បីធានាថាសិទ្ធិនេះត្រូវបានគោរព អាជ្ញាធរមានសមត្ថកិច្ចត្រូវស្នើជនជាប់ចោទឲ្យមានវត្តមាននៅក្នុងសវនាការ រួមជាមួយមេធាវីរបស់ខ្លួន ផ្តល់ការជូនដំណឹងអំពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែងសវនាការដល់ជនជាប់ចោទ និងមិនរារាំង ឬបណ្តេញជនជាប់ចោទពីសវនាការ តាមអំពើចិត្ត។ បដិប្បញ្ញត្តិទៅនឹងសិទ្ធិមានវត្តមាននៅក្នុងសវនាការ អាចមានតែនៅក្នុងករណីធ្ងន់ធ្ងរប៉ុណ្ណោះ។ ករណីទាំងនោះរួមមានស្ថានភាព ដែលក្នុងនោះជនជាប់ចោទ៖

- ជ្រើសរើសបោះបង់ចោលសិទ្ធិមានវត្តមានរបស់ខ្លួន ។
- ព្យាយាមបង្អាក់នីតិវិធីនៃតុលាការ ដែលតុលាការពិចារណាថា មិនអាចបន្តសវនាការបានដោយសារវត្តមានរបស់ជនជាប់ចោទ។ ក្នុងករណីនេះ មេធាវីរបស់ជនជាប់ចោទត្រូវតែរក្សាវត្តមានរបស់ខ្លួននៅក្នុងសវនាការ ដើម្បីបន្តការពារកូនក្តីរបស់ខ្លួន។
- មិនអាចរកឃើញ ឬបដិសេធ បើទោះបីជាមានការផ្តល់ដំណឹងគ្រប់គ្រាន់ ដើម្បីចូលរួមសវនាការក៏ដោយ ។

ចំណុចទីមួយ និងទីបីនៃចំណុចនៃបញ្ជីខាងលើ អាចនាំឲ្យមានសវនាការកំបាំងមុខ។ ដើម្បីធានាថាសវនាការកំបាំងមុខ មានលក្ខណៈយុត្តិធម៌ តាមច្បាប់អន្តរជាតិនោះ ចាំបាច់ត្រូវមាន៖

- គ្រប់វិធានការណ៍ចាំបាច់ត្រូវបានអនុវត្ត ដើម្បីជូនដំណឹងដល់ជនជាប់ចោទ អំពីបទចោទប្រកាន់ទៅលើពួកគេ និងនីតិវិធីព្រហ្មទណ្ឌដែលនឹងកើតមានចំពោះពួកគេ
- គ្រប់វិធានការណ៍ចាំបាច់ត្រូវបានអនុវត្ត ដើម្បីជូនដំណឹងជាមុនដល់ជនជាប់ចោទក្នុងរយៈពេលមួយគ្រប់គ្រាន់ នូវទីតាំង និងពេលវេលានៃសវនាការ និងស្នើឲ្យមានការចូលរួមរបស់ជនជាប់ចោទ
- តុលាការដែលពាក់ព័ន្ធត្រូវចាត់គ្រប់វិធានការណ៍ចាំបាច់ ក្នុងការធានាបាននូវសិទ្ធិការពាររបស់ជនជាប់ចោទ រួមទាំងការផ្តល់ជំនួយការច្បាប់
- ជនជាប់ចោទមានលទ្ធភាពប្តឹងឧទ្ធរណ៍ ឬស្វែងរកដំណោះស្រាយផ្លូវច្បាប់ ដើម្បីបញ្ចប់សំណុំរឿងរបស់ខ្លួន។

យោងតាមច្បាប់ជាតិ មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានរៀបរាប់ពីសិទ្ធមានវត្តមាននៅក្នុងសវនាការ។ បន្ថែមពីលើនេះ យោងតាមមាត្រា ១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ច្បាប់អន្តរជាតិបានធានានូវការគោរពសិទ្ធិនេះ។ ការប៉ុនប៉ងទាំងឡាយណា ដើម្បីរារាំងជនជាប់ចោទមិនឲ្យមានវត្តមាននៅសវនាការ គឺជាការរំលោភទៅលើសិទ្ធិជនជាប់ចោទទទួលបានការជំនុំជម្រះដោយយុត្តិធម៌ លើកលែងតែការរារាំងនោះស្របទៅនឹងលក្ខខណ្ឌតម្រូវនៃសវនាការកំបាំងមុខ ។

ពេលវេលាគ្រប់គ្រាន់ត្រូវផ្តល់ដល់ជនជាប់ចោទ ដើម្បីមានវត្តមាននៅតុលាការ អាស្រ័យតាមទីកន្លែងដែលជននោះរស់នៅ។ អនុឡោមតាមមាត្រា ៤៥៧ និង ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោទមានរយៈពេល ១៥ ថ្ងៃ ដើម្បីបង្ហាញខ្លួន ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង រយៈពេល ២០ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ រយៈពេល ២ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយ ជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា និងរយៈពេល ៣ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃ

ផ្សេងទៀត។ គ្មានចន្លោះពេលអប្បបរមា រវាងការបញ្ជូនដីកាកោះ និងកាលបរិច្ឆេទបង្ហាញខ្លួននៅមុខតុលាការឡើយ ប្រសិនបើជនជាប់កំពុងជាប់ឃុំឃាំង។

## សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

| ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ |
|---|
| ➢ **មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា ៖ *"ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅក្នុងពេលសវនាការសាធារណៈ។"* |
| ➢ **មាត្រា ១៤(១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ ជនគ្រប់រូបមានសិទ្ធិទទួលបាននូវ *"ការជំនុំជម្រះក្តីដោយសមធម៌ និងជាសាធារណៈ (...)។"* |

ការជំនុំជម្រះជាសាធារណៈធានាថា រដ្ឋបាលប្រព័ន្ធយុត្តិធម៌មានតម្លាភាព និងធានាថា អំណាចតុលាការ មានទំនួលខុសត្រូវចំពោះសាធារណជន នូវគ្រប់សេចក្តីសម្រេច និងសាលក្រម ដែលខ្លួនបានសម្រេច។ សម្រាប់ភាគីដែលពាក់ព័ន្ធវិញ ការបើកឲ្យសាធារណជនពិនិត្យពិច័យនោះ អនុញ្ញាតឲ្យមានការត្រួតពិនិត្យ ចំពោះការសម្រេចសេចក្តីតាមអំពើចិត្ត និងដោយរំលោភអំណាច ការរំលោភនានាទៅលើនីតិវិធី រួមទាំងការប្រព្រឹត្តមិនស្មើភាពគ្នាទៅលើភាគីពាក់ព័ន្ធ និងការជ្រៀតជ្រែក និងឥទ្ធិពលពីភាគីខាងក្រៅ។ នៅពេលប្រព័ន្ធច្បាប់កំពុងដំណើរការ ស្របតាមគោលការណ៍ច្បាប់ និងសីលធម៌នោះ សវនាការជាសាធារណៈកើតឡើងដោយមានសមាសភាពមួយចំនួន៖ ជាទូទៅសវនាការគួរតែបើកទូលាយសម្រាប់សាធារណជន និងប្រព្រឹត្តទៅដោយផ្ទាល់មាត់ ព័ត៌មានពីទីកន្លែង និងពេលវេលានៃសវនាការគួរតែត្រូវបានបង្ហាញជាសាធារណៈ និងគួរតែមានសម្ភារៈរូបវន្តគ្រប់គ្រាន់ ជួយសម្រួលដល់ការចូលរួមរបស់សាធារណជន។[5] មាត្រា ៣១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងបន្ថែមថា នៅក្នុងគ្រប់ករណីទាំងអស់ សាលក្រមត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ នៅខណៈដែលមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា លើកលែងតែផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ ការចេញសាលក្រមទាំងអស់ អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ។

មានករណីលើកលែងមួយចំនួន ដែលអនុញ្ញាតឲ្យតុលាការដំណើរការសវនាការជាអសាធារណៈ។ យោងតាមច្បាប់ជាតិ មាត្រា ៣១៦ អនុញ្ញាតឲ្យតុលាការបង្គាប់ឲ្យការពិភាក្សាដេញដោលប្រព្រឹត្តទៅជាសម្ងាត់ ប្រសិនបើតុលាការពិចារណាទៅលើអង្គសេចក្តី យល់ឃើញថា សាធារណភាពបង្កឲ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់។ គួរកត់សម្គាល់ផងដែរថា ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានផ្តល់និយមន័យ ឬសេចក្តីណែនាំអំពីអ្វីទៅជា "គ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់" ឡើយ។

---

[5] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ *បទអត្ថាធិប្បាយទូទៅ លេខ ៣២៖ មាត្រា ១៤៖ សិទ្ធិស្មើភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងទទួលបានការជំនុំជម្រះដោយយុត្តិធម៌* (CCPR/C/GC/32) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ទំព័រទី២៨។

ក្នុងច្បាប់អន្តរជាតិ ករណីលើកលែងទាំងនេះ មានចែងនៅមាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមមាន ៖

- **សីលធម៌៖** ក្រុមប្រឹក្សាសង្គម និងសេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិ បានបង្ហាញថា ការកម្រិតទាំងឡាយទៅលើសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ដោយឈរលើមូលដ្ឋានសីលធម៌ មានសារៈសំខាន់ ក្នុងការរក្សាការការគោរពតម្លៃជាមូលដ្ឋាននៃសហគមន៍[6]
- **សណ្តាប់ធ្នាប់សាធារណៈ៖** ត្រូវបានឲ្យនិយមន័យដោយ គោលការណ៍ស៊ីរ៉ាគូសា ទាក់ទងនឹងករណីលើកលែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថាជា *"វិធានរួមដែលធានាដល់ការប្រព្រឹត្តទៅនៃសង្គម ឬជាសំណុំនៃគោលការណ៍ចម្បង ដែលតាមរយៈនោះសង្គមត្រូវបានបង្កើតឡើង។"*[7]
- **សន្តិសុខជាតិ នៅក្នុងសង្គមប្រជាធិបតេយ្យ៖** ការបដិសេចសាធារណជន មិនឲ្យចូលក្នុងសវនាការ ដោយយោងលើហេតុផលសន្តិសុខជាតិអាចធ្វើទៅបាន លុះត្រាតែមានគោលបំណងពិតប្រាកដ និងបង្ហាញនូវផលដែលអាចមើលឃើញ ថាទង្វើនោះធ្វើឡើងដើម្បីការពារអត្ថិភាពនៃប្រទេស ឬបូរណភាពដែនដី ប្រឆាំងនឹងការគំរាមកំហែង ឬការប្រើកម្លាំង ឬលទ្ធភាពឆ្លើយតបទៅនឹងការគំរាមកំហែង ឬការប្រើកម្លាំងនោះ។[8] ប្រសិនបើគោលបំណងពិតប្រាកដ ឬផលដែលអាចមើលឃើញ នៃទង្វើនោះ គឺដើម្បីការពារផលប្រយោជន៍ដែលមិនពាក់ព័ន្ធទៅនឹងសន្តិសុខជាតិ ដូចជាការពារកិត្តិនាមរបស់រដ្ឋាភិបាល ឬក៏ការលេចធ្លាយនូវទង្វើខុសឆ្គង ទង្វើនឹងមិនស្របច្បាប់ឡើយ និងជាការរំលោភបំពានលើសិទ្ធិជនជាប់ចោទទទួលបានការជំនុំជម្រះជាសាធារណៈ។
- **នៅពេលដែលផលប្រយោជន៍នៃភាពឯកជនរបស់ភាគីតម្រូវឲ្យធ្វើដូច្នេះ៖** ឧទាហរណ៍ដូចជាករណី ដែលនីតិវិធីជាប់ពាក់ព័ន្ធនឹងអនីតិជន។
- **នៅពេលដែលតុលាការយល់ឃើញថា សាធារណៈភាព អាចបង្កឲ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌៖** ជាក់ស្តែងនៅក្នុងករណីដែលការជ្រៀតជ្រែករបស់សាធារណជននៅក្នុងសវនាការ ហើយការរំខាននោះបណ្តាលឲ្យមានហានិភ័យសក្ខីភាពពិតរបស់សាក្សី ឧទាហរណ៍ ដូចជានៅពេលដែលសាក្សីអាចស្ថិតនៅក្នុងភាពគ្រោះថ្នាក់ ប្រសិនបើអត្តសញ្ញាណរបស់ពួកគេត្រូវបានបង្ហាញជាសាធារណៈ ឬប្រសិនបើវត្តមានរបស់សាធារណជន អាចបណ្តាលឲ្យសាក្សីផ្លាស់ប្តូរចម្លើយរបស់ពួកគេ ។

---

[6] គណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ - *គោលការណ៍ស៊ីរ៉ាគូសា ស្តីពីការដាក់កម្រិត និងបដិប្បញ្ញត្តិ ទៅក្នុង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* លេខ E/CN.៤/១៩៨៥/៤ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៨៤ អាចរកតាមរយៈគេហទំព័រ ៖ http://www.unhcr.org/refworld/docid/4672bc122.html ។

[7] ដូចខាងលើ កថាខណ្ឌទី២២។

[8] ដូចខាងលើ កថាខណ្ឌទី២៩។ សូមមើលផងដែរនូវមាត្រា១៩ គោលការណ៍ទី២ នៃគោលការណ៍ចូហានេសបឺគ ស្តីពីសន្តិសុខជាតិ សេរីភាពក្នុងការបញ្ចេញមតិ និងការទទួលបានព័ត៌មាន ចុះខែវិច្ឆិកា ឆ្នាំ១៩៩៦ អាចរកបានតាមរយៈ គេហទំព័រ៖ http://www.article19.org/data/files/pdfs/standards/joburgprinciples.pdf ។

ប្រសិនបើតុលាការដំណើរការសវនាការជាអសាធារណៈ ដោយឈរលើមូលហេតុណាមួយ ដែលមិនទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិនោះ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ត្រូវបានរំលោភ ហើយសិទ្ធិរបស់ជនជាប់ចោទត្រូវបានបំពាន។ ករណីលើកលែងទៅនឹងសវនាការជាសាធារណៈ ដែលបានរៀបរាប់ខាងលើ ត្រូវបកស្រាយយ៉ាងតឹងរ៉ឹងដោយតុលាការ និងត្រូវបានអនុវត្តតែក្នុងករណីពិសេសប៉ុណ្ណោះ។[9] ការធ្វើរបៀបនេះមានសារៈសំខាន់ ព្រោះថា សេចក្តីសម្រេចដំណើរការសវនាការជាអសាធារណៈ មិនអាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍ឡើយ (មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ នៅក្នុងករណីដែលតុលាការដំណើរការសវនាការជាសាធារណៈ តុលាការត្រូវសម្រេចតាមសាលក្រមមួយ ដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ឬតាមសេចក្តីសម្រេចពិសេសនៃសាលក្រម (មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ បើទោះបីជាតុលាការដំណើការសវនាការជាអសាធារណៈក៏ដោយ សាលក្រមត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។[10]

## សិទ្ធិនៅស្ងៀម

**ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

- **មាត្រា ១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថាៈ ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួនជនគ្រប់រូបមានសិទ្ធិ "*មិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ*"។

សិទ្ធិមិនឆ្លើយនេះ ផ្សាភ្ជាប់ជាមួយនឹងសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស និងជាយន្តការការពារដល់សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យផ្តល់កសិណ ឬសារភាពពិរុទ្ធភាព។ សិទ្ធិមិនឆ្លើយ ត្រូវបានការពារដោយមាត្រា ១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូច្នេះជាផ្នែកមួយនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ។

## សិទ្ធិរួចផុតពីការដាក់ខ្លួនក្នុងការចោទប្រកាន់

**ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ**

- **មាត្រា ១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថាៈ "*បុគ្គលណាម្នាក់ មិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។*"

---

[9] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ - កថាខណ្ឌទី ២៩ នៃ*បទអត្ថាធិប្បាយទូទៅ លេខ ៣២៖ មាត្រា១៤៖ សិទ្ធិស្មើភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងទទួលបានការជំនុំជម្រះដោយយុត្តិធម៌* (CCPR/C/GC/32) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ។

[10] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

> ➢ **មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ** ចែងថា៖ *"ច្បាប់ការពារមិនឲ្យមានការរំលោភបំពាន លើរូបរាងកាយបុគ្គលណាមួយឡើយ (...) ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ (...) ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំ តាមផ្លូវកាយក្តី ឬតាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។ វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។"*
>
> ➢ **មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា ៖ *"លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី (...) ការសារភាព ក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរាងកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ ។"*

សិទ្ធិរួចផុតពីការដាក់ខ្លួនក្នុងការចោទប្រកាន់ ផ្សារភ្ជាប់នឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។ សិទ្ធិនេះត្រូវបានបង្កើតឡើង ដើម្បីបង្ការមិនឲ្យជនជាប់ចោទ ត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសខ្លួនឯង និង/ឬ សារភាពថាមានពិរុទ្ធ។ សិទ្ធិនេះបង្កប់នូវសិទ្ធិមិនឆ្លើយ ដែលអនុញ្ញាតឲ្យជនជាប់ចោទអាចបដិសេធមិនផ្តល់កសិណានៅតុលាការ និង/ឬ បដិសេធមិនឆ្លើយសំណួរដែលចោទសួរខ្លួននៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី។

ផលដោយផ្ទាល់ដែលទទួលបានពីសិទ្ធិនេះ គឺសេរីភាពរួចផុតពីការបង្ខិតបង្ខំឲ្យសារភាពថាមានពិរុទ្ធ តាមរយៈការប្រើប្រាស់ទម្រង់បំភិតបំភ័យពីរយ៉ាង៖ ការបង្ខិតបង្ខំ និងទារុណកម្ម។ ជាការសំខាន់ ក្នុងការបែងចែកភាពខុសគ្នារវាងសិទ្ធិនេះ និងការសម្រេចចិត្តសារភាពដោយស្ម័គ្រចិត្តរបស់ជនជាប់ចោទ។ កត្តាដែលខុសគ្នាគួរឲ្យកត់សម្គាល់នោះគឺ ជម្រើស ថាតើភាគីណាមួយជ្រើសរើសដាក់ខ្លួនក្នុងការចោទប្រកាន់ ឬសារភាព ឬថាតើជននោះត្រូវបានបង្ខិតបង្ខំដោយកត្តាខាងក្រៅឲ្យដាក់ខ្លួនក្នុងការចោទប្រកាន់។ យោងតាមច្បាប់ជាតិ និងអន្តរជាតិ ការដាក់ខ្លួនក្នុងការចោទប្រកាន់ ឬការទទួលបានការសារភាពដោយមិនស្ម័គ្រចិត្ត មិនមានតម្លៃជាភស្តុតាងទេ នេះគឺរួមទាំងភស្តុតាងដែលទទួលបានតាមរយៈការបង្ខិតបង្ខំខាងផ្លូវកាយ ឬខាងផ្លូវចិត្ត ឬទារុណកម្ម ។

ច្បាប់អន្តរជាតិមានចែងពីបទប្បញ្ញត្តិដាច់ដោយឡែក សម្រាប់សិទ្ធិរួចផុតពីការដាក់ខ្លួនក្នុងការចោទប្រកាន់ តាមរយៈការបង្ខិតបង្ខំ និងទារុណកម្ម ដូចដែលមានចែងនៅក្នុងមាត្រា ១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៥ នៃសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស។ បន្ថែមពីលើនេះ អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម អនុវត្តទៅលើស្ថានភាពដែលមានការលួងលោមឲ្យដាក់ខ្លួនក្នុងការចោទប្រកាន់ និងទម្រង់ផ្សេងទៀត ដែលក្នុងនោះព័ត៌មានទទួលបានតាមរយៈការប្រើ ឬការគំរាមកំហែង លើរូបរាងកាយ ឬផ្លូវចិត្ត ការបំភិតបំភ័យ អំពើហិង្សាជាដើម។ អំពើធ្វើបាបខាងរាងកាយ បង្ខំឲ្យជនណាម្នាក់សារភាព អាចចាត់ទុកជាការធ្វើទារុណកម្ម។ នៅក្នុងបរិបទនេះ ការធ្វើទារុណកម្មផ្សារភ្ជាប់ទៅនឹងវិធីសាស្ត្រ ដែលអាជ្ញាធរប្រើ ដើម្បីទាញ

យកចម្លើយសារភាព ឬធ្វើឲ្យដាក់ខ្លួនក្នុងការចោទប្រកាន់។ ការធ្វើទារុណកម្មដើម្បីយកចម្លើយត្រូវបានហាមឃាត់ជាដាច់ខាតទាំងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។

## សិទ្ធិពាក់ព័ន្ធនឹងភស្តុតាង៖ សិទ្ធិហៅ និងសាកសួរសាក្សី

ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ

- **មាត្រា ១៤(៣)(ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *"បុគ្គលគ្រប់រូបមានសិទ្ធិ (...) មានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយ ទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក ។"*
- **មាត្រា ១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា ៖ *"ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍ នៅក្នុងការសម្តែងឲ្យឃើញការពិត (...) ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ (...) និងសាក្សីផងបានដែរ ។"*
- **មាត្រា ២៩៤ ២៩៥ និង ២៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងអំពីការកោះហៅសាក្សីឲ្យចូលរួមក្នុងសវនាការតាមដីកាបញ្ជូន តាមដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងករណីចូលបង្ហាញខ្លួនភ្លាម។
- **មាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នា ជាមួយជនជាប់ចោទ ត្រូវតែកោះហៅឲ្យចូលរួមក្នុងសវនាការ។"*
- **មាត្រា ២៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី អាចនាំចូលរួមក្នុងសវនាការ នូវសាក្សីទាំងឡាយណា ដែលព្រះរាជអាជ្ញាមិនបានកោះហៅ ដោយខ្លួនជាអ្នកចេញសោហ៊ុយ ។"*
- **មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយ ឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាង ដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ។ ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចម្លើយដែលទទួលបានក្រោមការបង្ខិតបង្ខំខាងរាងកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ។ ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន មិនអាចយកមកធ្វើជាភស្តុតាងបានឡើយ ។"*
- **មាត្រា ៣២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"នៅពេលបើកពិភាក្សាដេញដោលភាគីអាចសុំឲ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលដែលមានវត្តមាននៅ*

*ក្នុងបន្ទប់ ប៉ុន្តែមិនបានកោះហៅឲ្យបានត្រឹមត្រូវទេ។ ការស្តាប់ចម្លើយសាក្សីនេះ ត្រូវមានការយល់ព្រមពីប្រធានសវនាការ។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះ ឲ្យថយទៅនៅបន្ទប់រង់ចាំ ។"*

- **មាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ថា មានប្រយោជន៍ (...) ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឲ្យលើកសំណួរសួរ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់តំណាងអយ្យការនិងមេធាវី សំណួរផ្សេងៗទៀតត្រូវសួរតាមរយៈប្រធានសវនាការ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្ត ថាតើសំណួរនេះត្រូវតែសួរឬទេ។"*
- មើលផងដែរនូវ **មាត្រា ១៣៣** និង **១៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ។

សិទ្ធិហៅ និងសាកសួរសាក្សី ជាសមាសភាពដ៏សំខាន់នៃគោលការណ៍ "ស្មើភាពគ្នា" ពោលគឺ គោលការណ៍ដែលភាគីទាំងអស់គួរតែទទួលបានភាពស្មើគ្នា នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃសវនាការ និងពុំមានភាគីណាមួយស្ថិតក្នុងស្ថានភាពខាតប្រយោជន៍ ធៀបទៅនឹងភាគីដទៃទៀតឡើយ នៅក្នុងបង្ហាញរឿងក្តីរបស់ខ្លួន។ សិទ្ធិហៅ សាកសួរ និងសាកសួរសាក្សីភាគីបដិបក្ខ អាចឲ្យតុលាការមានឱកាសសង្កេតមើលភស្តុតាង និងស្តាប់អំពីការដេញដោលផ្នែកច្បាប់ ទាក់ទិននឹងតម្លៃនៃភស្តុតាង។ ការណ៍នេះជួយឲ្យតុលាការ ធ្វើការវាយតម្លៃលើអំណះអំណាងផ្សេងៗ ដែលបានបង្ហាញ និងធ្វើសេចក្តីសម្រេច។ ការណ៍នេះក៏អាចអោយភាគីជនជាប់ចោទ បង្ហាប់ឲ្យមានការចូលរួមរបស់សាក្សី និងសាកសួរ ព្រមទាំងសាកសួរសាក្សីខាងព្រះរាជអាជ្ញា។ លើសពីនេះទៀត ការធ្វើរបៀបនេះ គឺផ្តល់អំណាចឲ្យភាគីជនជាប់ចោទ ហៅសាក្សីរបស់ខ្លួន។ ដូច្នេះ ភាគីជនជាប់ចោទត្រូវមានឱកាស និងពេលវេលាគ្រប់គ្រាន់ ដើម្បី៖

- សាកសួរសាក្សីរបស់ខ្លួន ដើម្បីការពារក្តីរបស់ខ្លួន
- សាកសួរសាក្សីភាគីបដិបក្ខ
- តទល់នឹងភស្តុតាងទាំងអស់ដែលបង្ហាញនៅក្នុងសវនាការ។

នៅខណៈដែលព្រះរាជអាជ្ញាកោះហៅសាក្សី អនុឡោមតាមមាត្រា ២៩៨ និង ៣២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅក្នុងសវនាការ ភាគីជនជាប់ចោទអាចបង្ហាញសាក្សីណាមួយ ដែលពុំទាន់បានកោះហៅដោយព្រះរាជអាជ្ញា និងស្នើឲ្យតុលាការស្តាប់ចម្លើយរបស់ពួកគេ ក្នុងឋានៈជាសាក្សី។

## សិទ្ធិនិយាយសម្តីចុងក្រោយ

> ➢ **មាត្រា ៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា ៖ *"ជនជាប់ចោទ និងមេធាវីរបស់ខ្លួន ត្រូវនិយាយក្រោយគេបង្អស់ជានិច្ច។"*

សិទ្ធិនេះត្រូវបានចែងនៅក្នុងមាត្រា ៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយមានសារៈសំខាន់ណាស់ ពីព្រោះសិទ្ធិនេះធានាថា ភាគីជនជាប់ចោទ មានឱកាសពេញលេញ ដើម្បីឆ្លើយតបរាល់អំណះអំណាង និងភស្តុតាងដែលបង្ហាញដោយព្រះរាជអាជ្ញា និងភាគីដទៃទៀត។ សិទ្ធិនេះធានាថា ចៅក្រមបានស្តាប់សម្តីចុងក្រោយពីជនជាប់ចោទ ដែលជាបុគ្គលដែលទំនងនឹងខាតបង់បំផុត ប្រសិនបើរកឃើញថាមានពិរុទ្ធ។

## សិទ្ធិទទួលបានសាលក្រមក្នុងរយៈពេលមួយសមរម្យ

> **ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ**
>
> ➢ **មាត្រា ១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *"ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឲ្យសាលាក្តីជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញ ស្របតាមច្បាប់។"*
>
> ➢ **មាត្រា ៣៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"សាលក្រមត្រូវសម្រេចចេញនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ។ នៅក្នុងករណីខាងក្រោយនេះ ប្រធានសវនាការ ជូនដំណឹងដល់ភាគីទាំងឡាយដែលមានវត្តមាន អំពីថ្ងៃដែលត្រូវប្រកាសសាលក្រម។"*

សិទ្ធិទទួលបានសាលក្រមក្នុងរយៈពេលមួយសមរម្យ ជាប់ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានពន្យារពេល។ សិទ្ធិនេះគាំទ្រគំនិតដែលថា ការពន្យារពេលដែលមិនចាំបាច់ ធ្វើឲ្យនីតិវិធីដំណើរការយូរ បន្ថែមរយៈពេលដែលជនជាប់ចោទស្ថិតនៅក្នុងស្ថានភាពមិនច្បាស់លាស់។ ការខកខានមិនផ្តល់សាលក្រមនៅក្នុងរយៈពេលមួយសមរម្យ អាចរារាំងលទ្ធភាពជនជាប់ចោទ ក្នុងការប្តឹងឧទ្ធរណ៍។ យោងតាមមាត្រា ១៤ កឋាខណ្ឌ ៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា ទណ្ឌិតមានសិទ្ធិទទួលបានសាលក្រមដែលមានហេតុផល ត្រឹមត្រូវ ក្នុងរយៈពេលមួយសមរម្យ ដើម្បីឲ្យខ្លួនអាចអនុវត្តប្រកបដោយប្រសិទ្ធិភាពនូវសិទ្ធិសុំឲ្យសាលាក្តីជាន់ខ្ពស់ពិនិត្យឡើងវិញ។[11] មាត្រា ៣៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដាក់កាតព្វកិច្ចឲ្យតុលាការជូនដំណឹងដល់ភាគីទាំងឡាយដែលមានវត្តមាន អំពីថ្ងៃដែលត្រូវប្រកាសសាលក្រម នៅពេលដែល

---

[11] គណៈកម្មាធិការសិទ្ធិមនុស្ស - ទស្សនៈចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ១៩៩៤ *ហ៊ើរី តទល់នឹង ចាម៉ៃកា* កឋាខណ្ឌទី១៣.៥ នៃសេចក្តីជូនដំណឹងលេខ ៣៧៧/១៩៨៩។ *អាប់ដេលីហាមីដ ថាក៍យ អាមេដ ទូអានី មហាមេដ រីមេលី និងអាម៉ា យូសហ្វី តទល់នឹង អាល់ហ្សេរី* កឋាខណ្ឌទី ៨.៤ និង ៨.៥ នៃសេចក្តីជូនដំណឹងលេខ ១០៨៥/២០១១។

សាលក្រមត្រូវសម្រេចចេញនៅពេលសវនាការលើកក្រោយ។ ប៉ុន្តែ ពុំមានការកំណត់ ឲ្យតុលាការប្រាប់អំពីពេលវេលា ដែលតុលាការត្រូវចេញសាលក្រមនោះទេ។

## សិទ្ធិទទួលបានសាលក្រមដែលមានសំអាងហេតុ

ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ

- **មាត្រា ១៤(៥)** នៃ**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *ជនគ្រប់រូបដែលជាប់ពិរុទ្ធ ពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឲ្យសាលាក្តីជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញ ស្របតាមច្បាប់ ។*
- **មាត្រា ៣៥៧** នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *គ្រប់សាលក្រមត្រូវមានពីរផ្នែក៖ ផ្នែកសំអាងហេតុ (ពោលគឺទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឲ្យតុលាការ ចេញសេចក្តីសម្រេច) និងផ្នែកសម្រេច (ពោលគឺការសម្រេចរបស់តុលាការ)។ អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ។ តុលាការត្រូវពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកនៅពេលសវនាការ។ នៅក្នុងផ្នែកសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី។ ផ្នែកសេចក្តីសម្រេច ត្រូវចុះនិទ្ទេសអំពីបទល្មើសដែលជនជាប់ចោទប្រព្រឹត្តខុស អត្ថបទច្បាប់ដែលអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី។*

សិទ្ធិទទួលបានសាលក្រមដែលមានសំអាងហេតុ ទាមទារឲ្យតុលាការត្រួតពិនិត្យបទចោទ និងសេចក្តីសំអាងនីមួយៗ ដែលបង្ហាញនៅក្នុងអំឡុងពេលសវនាការ និងឆ្លើយតបទៅនឹងសេចក្តីសំអាងជាលាយលក្ខណ៍អក្សរ ដែលដាក់ជូនដោយភាគី។ សាលក្រមមានសំអាងហេតុ ធានាថា ជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធ ដោយអនុឡោមតាមគោលការណ៍ច្បាប់ និងផ្តល់ផ្លូវប្តឹងឧទ្ធរណ៍ ក្នុងករណីដែលការសំអាងហេតុនៅក្នុងសម្រេចសេចក្តីនោះ មានលក្ខណៈមិនស្របច្បាប់នឹងច្បាប់។

## សិទ្ធិនៅពេលផ្តន្ទាទោស

ប្រភពច្បាប់ជាតិ និងច្បាប់អន្តរជាតិ

- **មាត្រា ៩៤** នៃ**ក្រមព្រហ្មទណ្ឌ** ចែងអំពី**គោលការណ៍មូលទោស៖** *"កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធធានាគារ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ។ កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល។"*
- **មាត្រា ៩៦** នៃ**ក្រមព្រហ្មទណ្ឌ** ចែងអំពីគោលការណ៍ឯកត្តកម្មនៃទោស ៖ *"តុលាការប្រកាសទោស ដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើ*

*បុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ។"*

សូមមើលផងដែរនូវៈ

- **មាត្រា ៥៣** ដល់ **៧១ នៃក្រមព្រហ្មទណ្ឌ** ៖ ទោសបន្ថែម។
- **មាត្រា ៧២** ដល់ **៧៦ នៃក្រមព្រហ្មទណ្ឌ** ៖ ទោសជំនួស។
- **មាត្រា ១០៤** ដល់ **១១៦ នៃក្រមព្រហ្មទណ្ឌ** ៖ ការព្យួរទោសធម្មតា។
- **មាត្រា ១១៧** ដល់ **១២៣ នៃក្រមព្រហ្មទណ្ឌ** ៖ ការព្យួរទោសសាកល្បង។
- **មាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ការសម្រេចអំពីប្រយោជន៍ផ្នែករដ្ឋប្បវេណី។

## ព្រំដែននៃទណ្ឌកម្ម

ជនជាប់ចោទដែលត្រូវរកឃើញថាមានពិរុទ្ធពីបទល្មើសណាមួយ នឹងត្រូវបានផ្តន្ទាទោសស្របតាមបញ្ញត្តិច្បាប់ និងកម្រិតនៃទោសដែលពាក់ព័ន្ធនឹងបទល្មើសនោះតែប៉ុណ្ណោះ។ មាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ចែងថា ច្បាប់កំណត់អំពីកម្រិតអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល។ ការដាក់កម្រិតនៃការផ្តន្ទាទោសទាំងនេះ និងការអនុញ្ញាតឲ្យមានទោសបន្ថែម ឬទោសជំនួស សុទ្ធតែមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនេះ និងនៅលំអិតជាក់លាក់ នៅក្នុងប្រភេទបទល្មើសនីមួយៗ។ តុលាការមិនត្រូវផ្តន្ទាទោសដែលធ្ងន់ ឬស្រាលជាង ទោសដែលបានចែងនៅក្នុងក្រមព្រហ្មទណ្ឌឡើយ។

## ការពិចារណាទៅលើស្ថានសម្រាលនៅពេលផ្តន្ទាទោស

មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌ តម្រូវឲ្យតុលាការពិចារណាទៅលើស្ថានភាពស្មារតីរបស់ជនល្មើសនៅពេលសម្រេចផ្តន្ទាទោស។ ប្រសិនបើជនជាប់ចោទគ្រប់គ្រងស្មារតីរបស់ខ្លួននៅពេលប្រព្រឹត្តបទល្មើស ជននោះមិនគួរទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌឡើយ។ ប៉ុន្តែបើការដឹងខុសត្រូវរបស់ជនជាប់ចោទ ថមថយដោយសារវិបល្លាសស្មារតី នៅពេលប្រព្រឹត្តបទល្មើស ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ប៉ុន្តែតុលាការគួរពិចារណាទៅលើការថមថយការដឹងខុសត្រូវនេះ នៅពេលផ្តន្ទាទោស (ពោលគឺការសម្រាលនូវការទទួលខុសត្រូវ ឬការសម្រាលនូវសមត្ថភាពជាស្ថានសម្រាលទោស)។ ប្រសិនវិបល្លាសស្មារតីកើតឡើងដោយសារតែការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ នោះនឹងគ្មានការលើកលែងពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

## ការហាមឃាត់ចំពោះការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់

**ប្រភពច្បាប់ជាតិ និងអន្តរជាតិ**

- **មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *"គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ [ដូចគ្នានេះ មិនត្រូវដាក់ទោស ឲ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសនោះឡើយ។] ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់មានបញ្ញត្តិឲ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។ គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយដែលជននោះបានប្រព្រឹត្តក្នុងខណៈពេលដែលអំពើ ឬការខកខាននោះជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ។"*
- **មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ** ចែងថា៖ *"មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តតែប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន។"*
- **មាត្រា ១០ នៃក្រមព្រហ្មទណ្ឌ** ចែងថា៖ *"បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាង ត្រូវអនុវត្តភ្លាម។ ប៉ុន្តែ ការផ្តន្ទាទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលធ្ងន់ជាង នឹងត្រូវអនុវត្តតែលើអំពើ ដែលបានប្រព្រឹត្ត ក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ។"*

ការហាមឃាត់ចំពោះការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ ការពារជនជាប់ចោទ ពីការជំនុំជម្រះបទល្មើសដែលមិនមែនជាបទល្មើសនៅខណៈពេលប្រព្រឹត្ត។ គោលការណ៍ "គ្មានបទល្មើសបើគ្មានច្បាប់ចែង" មានន័យថា ជនណាម្នាក់មិនអាចត្រូវបានចាត់ទុកថាប្រព្រឹត្តបទល្មើសឡើយ ប្រសិនបើអំពើនោះមិនត្រូវបានច្បាប់ហាមឃាត់ នៅខណៈពេលប្រព្រឹត្ត។ ហេតុផលពីក្រោយគោលការណ៍នេះ ឬត្រូវបានគេស្គាល់ថាជា គោលការណ៍នីត្យានុកូលភាព គឺថាគ្មានជនណាម្នាក់អាចត្រូវបានអះអាងថាបានប្រព្រឹត្តបទល្មើសឡើយ ប្រសិនបើស្របតាមសមត្ថភាពជននោះគេមិនអាចបង្ហាញថាអំពើនោះជាបទល្មើសព្រហ្មទណ្ឌនៅខណៈពេលប្រព្រឹត្ត។ គោលការណ៍នេះមិនទាមទារឲ្យជនដែលប្រព្រឹត្ត ដឹងថាអំពើខ្លួនជាអំពើផ្ទុយច្បាប់នោះឡើយ ដូច្នេះការទាមទារនេះដាក់បន្ទុកភស្តុតាងទៅលើរដ្ឋ ជាជាងដាក់បន្ទុកទៅលើជនដែលប្រព្រឹត្តឲ្យដឹងដោយខ្លួនឯង នូវអំពើនោះថាខុសច្បាប់នៅខណៈ

ដែលប្រព្រឹត្ត។ រដ្ឋរួចផុតពីបន្ទុកនេះតាមរយៈការបោះផ្សាយច្បាប់។ ក្នុងន័យនេះ គោលការណ៍នេះបង្ការនូវស្ថានភាពទាំងឡាយណា ដែលច្បាប់អនុវត្តការផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអំពើដែលកើតមុនច្បាប់ចូលជាធរមាន ។

មាត្រា ៩ និង ១០ នៃក្រមព្រហ្មទណ្ឌចែងថា ៖

- ការជម្រះទោសពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ ដែលក្រមព្រហ្មទណ្ឌបានលុបចោល ត្រូវឈប់អនុវត្តភ្លាម។
- គ្រប់នីតិវិធីច្បាប់ពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌនោះ ត្រូវបញ្ចប់ ហើយការផ្តន្ទាទោស ឬដាក់ទណ្ឌកម្ម ទាក់ទងនឹងបទល្មើសនោះ មិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត។
- បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាង ត្រូវអនុវត្តភ្លាម។ ឧទាហរណ៍ នៅក្នុងករណីដែលក្រមព្រហ្មទណ្ឌចែងពីទោសដែលស្រាលជាង ហើយការផ្តន្ទាទោសមិនទាន់ត្រូវបានសម្រេច ទោសដែលស្រាលនោះត្រូវអនុវត្ត។
- បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង ត្រូវបានហាមឃាត់មិនឲ្យអនុវត្តជាលក្ខណៈប្រតិសកម្ម។ ឧទាហរណ៍ នៅក្នុងករណីដែលក្រមព្រហ្មទណ្ឌចែងពីទោសដែលធ្ងន់ជាង ទោសដែលពីមុនអនុវត្តដោយតុលាការ បទប្បញ្ញត្តិនោះនឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ (សូមមើលករណីសិក្សាអំពីលោក មឿង សុន)។

ករណីសិក្សាខាងក្រោមនេះ ឆ្លុះបញ្ចាំងឲ្យឃើញនូវបញ្ហាជាក់ស្តែង ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ដែលអ្នកទាំងឡាយមានបំណងបង្កើតគម្រោងសង្កេតការណ៍សវនាការអាចនឹងជួបប្រទះនៅក្នុងរយៈពេលក្រោយពីក្រមព្រហ្មទណ្ឌ ចូលជាធរមាន និងដាក់ឲ្យអនុវត្ត។

**ករណីសិក្សាទី ២ ៖ លោក មឿង សុន**



នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ លោកមឿង សុន ដែលជាប្រធានអង្គការមូលនិធិគាំទ្រអរិយធម៌ខ្មែរ ត្រូវបានរកឃើញថាមានពិរុទ្ធពីបទផ្សាយព័ត៌មានមិនពិត តាមមាត្រា ៦២ នៃច្បាប់អ៊ុនតាក់ ដោយសារ គាត់បានរិះគន់ការដាក់បង្គោលភ្លើងនៅប្រាសាទអង្គរវត្ត។ លោកមឿង សុន ត្រូវបានផ្តន្ទាទោសកំបាំងមុខ ដាក់ពន្ធនាគារចំនួន ២ ឆ្នាំ និងផាកពិន័យចំនួន ៧ លានរៀល និងបង្គាប់ឲ្យសងជំងឺចិត្តចំនួន ៨ លានរៀល។

នៅសាលាឧទ្ធរណ៍ ចៅក្រម ៣ រូបចេញសាលដីកា ដែលរក្សាទុកនូវចំនួនទឹកប្រាក់សងជំងឺចិត្តដដែល តែប្ដូរបទល្មើស ទៅជាបទ "ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ" តាមមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ ការផ្លាស់ប្តូរនេះ នាំឲ្យមានការកាត់បន្ថយចំនួនទឹកប្រាក់ពិន័យនៅត្រឹម ៤ លានរៀល ដែលនេះបានសម្រាលទោសលោកមឿង សុន (ដូចមានចែងក្នុងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ)។ ប៉ុន្តែ ការប្តូរទោសបែបនេះ អាចត្រូវបានបកស្រាយថា ជាការអនុវត្តច្បាប់មិនត្រឹមត្រូវ ដែលបណ្តាលឲ្យលោកមឿងសុន ត្រូវមានទោស តាមរយៈការអនុវត្តបទប្បញ្ញត្តិក្រមព្រហ្មទណ្ឌ ដែលមានលក្ខណៈមិនដូចគ្នានឹងបទល្មើសព្រហ្មទណ្ឌ ដែលគាត់ត្រូវបានចោទប្រកាន់។ នេះសបញ្ជាក់អំពីការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ ដែលជាការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោកមឿងសុន។ មិនតែប៉ុណ្ណោះ មេធាវីរបស់លោកបានទទួលដំណឹងពីការប្តូរបទល្មើសនេះនៅពេលប្រកាសសាលដីកា។ ដូច្នេះ លោក សុន ពុំបានទទួលពេលវេលាគ្រប់គ្រាន់ដើម្បីការពារក្តីឡើយ ហើយក៏មិនបានដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ទាំងនេះរឹតតែរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោកមឿង សុន ថែមទៀត ៕

## ការហាមឃាត់ការវិនិច្ឆ័យទោសពីរដង

**ប្រភពច្បាប់ជាតិ និងអន្តរជាតិ**

- **មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេ ចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។"*
- **មាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា ៖ *"គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើស ដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ។"*

ការវិនិច្ឆ័យទោសពីរដង ឬគោលការណ៍អាជ្ញាអស់ជំនុំ សំដៅទៅលើសិទ្ធិរបស់បុគ្គលម្នាក់ៗទទួលបានការការពារ ពីការជំនុំជម្រះអំពើ ឬបទល្មើសព្រហ្មទណ្ឌដដែលលើសពីម្តង។ នៅពេលដែលសាលក្រមចុងក្រោយ (សេចក្តីសម្រេចរបស់តុលាការជាន់ខ្ពស់ ឬតុលាការជាន់ទាបនៅក្នុងករណីដែលគ្មានភាគីណាមួយប្តឹងឧទ្ធរណ៍នៅក្នុងអាជ្ញាយុកាលកំណត់) ត្រូវបានចាត់ទុកដោយតុលាការថាជាការសម្រេចចុងក្រោយទៅលើរឿងក្តីពាក់ព័ន្ធនឹងអំពើ ឬបទល្មើសនោះ។ គ្រប់ភាគីទាំងអស់ត្រូវគោរពសេចក្តីសម្រេចនេះ ហើយខាងអយ្យការមិនអាចប៉ុនប៉ងជំនុំជម្រះទោសជននោះម្តងទៀតទេចំពោះអំពើដដែល។ សាលក្រមត្រូវបានប្រកាស ហើយការសម្រេចឲ្យរួចខ្លួន ឬផ្តន្ទាទោស ដើរតួជាការហាមឃាត់នូវការជំនុំជម្រះទោសជាថ្មីទៅលើអំពើនោះ។ សេចក្តីសម្រេចស្ថាពរ

នេះ នាំមកនូវគុណសម្បត្តិជាច្រើន ដល់ជនជាប់ចោទ និងសង្គមជាតិទាំងមូល តួយ៉ាង ដូចជាការជួយទប់ស្កាត់ការខ្ជះខ្ជាយធនធានច្បាប់នៅពេលដែលសេចក្តីសម្រេចត្រូវបានធ្វើរួចហើយ។

មិនមែនជាការវិនិច្ឆ័យទោសពីរដងឡើយ នៅក្នុងករណីដែលតុលាការជាន់ខ្ពស់បដិសេធចោលការផ្តន្ទាទោស ហើយជំនុំជម្រះសារឡើងវិញ។ មានករណីលើកលែងចំពោះវិធានវិនិច្ឆ័យទោសពីរដង ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ដូចជាការជំនុំជម្រះសារជាថ្មីនូវបទព្រហ្មទណ្ឌដែលអាចធ្វើបាននៅក្នុងករណីលើកលែងមួយចំនួន ជាអាទិ៍ ការរកឃើញនូវភស្តុតាងថ្មីដែលមិនបានដឹង ឬមិនបានរកឃើញនៅពេលសម្រេចឲ្យរួចខ្លួន។[12] ករណីលើកលែងទៅនឹងគោលការណ៍វិនិច្ឆ័យទោសពីរដង ក្នុងច្បាប់ជាតិ មានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។[13]

## សិទ្ធិរបស់អនីតិជន

**ប្រភពច្បាប់ជាតិ និងអន្តរជាតិ**

- **មាត្រា ៤០(១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ** ចែងថា៖ *"រដ្ឋភាគី ទទួលស្គាល់ថា កុមារដែលជាប់សង្ស័យ ជាប់ចោទ ឬដែលគេស្គាល់ថាបានល្មើសនឹងច្បាប់ព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការគិតគូរឲ្យបានសមស្របទៅនឹងការលើកស្ទួយ ការយល់របស់កុមារអំពីសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់ខ្លួន។ ការគិតបែបនេះ ពង្រឹងកុមារឲ្យចេះគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ និងយកមកគិតនូវអាយុរបស់កុមារ ព្រមទាំងនូវសេចក្តីប្រាថ្នាចង់បញ្ចូលកុមារមកក្នុងសង្គមវិញ និងចង់ឲ្យកុមារមានតួនាទីស្ថាបនានៅក្នុងសង្គម។*
- **មាត្រា ១៤ (៤) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *"នីតិវិធីអនុវត្តចំពោះយុវជន - យុវនារី ដែលមិនទាន់មាននីតិភាពតាមច្បាប់កំណត់ ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ។"*
- **មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ** ៖ *"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុង (...) កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។"*
- **មាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញ** ៖ *"រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិទទួលបានការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារ ទាំងឡាយ ដែលអាចធ្វើឲ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែល នាំឲ្យអន្តរាយដល់សុខភាព ឬសុខមាលភាពរបស់កុមារ។"*

[12] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ - *បទអត្ថាធិប្បាយទូទៅលេខ៣២៖ មាត្រា១៤៖សិទ្ធិសមភាពចំពោះ មុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌* (CCPR/C/GC/32) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ទំព័រទី៥៦។

[13] សូមមើលជាពិសេសមាត្រា ៧ និង ៤៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- **មាត្រា ២១២** ដល់**មាត្រា ២១៤** នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។
- **មាត្រា ៣៩** និង **មាត្រា ៤០** នៃ**ក្រមព្រហ្មទណ្ឌ៖ វិធានការណ៍អនុវត្តចំពោះអនីតិជន**។

អនីតិជនដែលត្រូវចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស មានសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ដែលអនុវត្តចំពោះនីតិជន ក៏ដូចជាការការពារផ្សេងៗបន្ថែមទៀត ស្របទៅតាមអាយុ ការដឹងខុសត្រូវ និងការលូតលាស់ផ្នែកបញ្ញាស្មារតី។ គោលបំណងបឋមនៃយុត្តិធម៌អនីតិជន គឺស្តារនីតិសម្បទា និងបញ្ចូលជនល្មើសឲ្យក្លាយជាសមាជិកស្ថាបនាសង្គមឡើងវិញ។ មាត្រា ៣១ និង ៤៨ នៃរដ្ឋធម្មនុញ្ញធានាថា រដ្ឋត្រូវការពារសិទ្ធិកុមារ ក្នុងខណៈដែលច្បាប់ជាតិដទៃទៀត ក៏ចែងពីការប្រព្រឹត្តដាច់ដោយឡែកចំពោះអនីតិជន ក្នុងស្ថានភាពសំខាន់ៗជាច្រើន។ ប្រសិនបើកាលៈទេសៈតម្រូវ តុលាការត្រូវពិចារណាលើការដោះស្រាយជាមួយជនល្មើសជាអនីតិជន ដោយមិនប្រើការជំនុំជម្រះជាផ្លូវការ ដោយធានាថាសិទ្ធិមនុស្ស និងការការពារផ្លូវច្បាប់ដទៃទៀត ដូចជាការសន្មតជាមុនថាគ្មានទោសត្រូវបានគោរពយ៉ាងពេញលេញ។ វិធានការដទៃទៀតដែលមិនមែនជានីតិវិធីព្រហ្មទណ្ឌ តួយ៉ាងដូចជាការសម្រុះសម្រួលរវាងជនល្មើស និងជនរងគ្រោះ ការប្រជុំជាមួយក្រុមគ្រួសាររបស់ជនល្មើស ការប្រឹក្សា ការងារសហគមន៍ ឬកម្មវិធីអប់រំវិជ្ជាជីវៈ ត្រូវយកមកពិចារណា។[14] មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ បានបង្កើតឲ្យមានសច្ចធារណ៍ជាប្រយោជន៍ដល់ជម្រើសផ្សេងក្រៅពីពន្ធនាគារសម្រាប់អនីតិជន។

## អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

**ប្រភពច្បាប់ជាតិ និងអន្តរជាតិ**

- **មាត្រា ៣៨** នៃ**ក្រមព្រហ្មទណ្ឌ** ចែងថា៖ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ៖ *"នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។"*
- **មាត្រា ៣៩** និង **៤០** នៃ**ក្រមព្រហ្មទណ្ឌ** ចែងថា៖ *"អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។"*
- **មាត្រា ២១២** ដល់ **២១៤** នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

[14] មាត្រា៤០(៣)(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ - *បទអត្ថាធិប្បាយទូទៅលេខ ៣២៖ មាត្រា ១៤ ៖ សិទ្ធិមានសមភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌* កថាខណ្ឌទី ៨៤។

មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ កំណត់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រឹម ១៨ ឆ្នាំ។ មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ អនុញ្ញាតឲ្យតុលាការ ប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជន[15] អាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ *"ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់*[អនីតិជន]*តម្រូវ។"* នេះមានន័យថា កុមារជាជនដែលមានអាយុតិចជាង ១៤ឆ្នាំ។ កុមារ មិនអាចទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ហើយចៅក្រមមានតួនាទីច្រានចោលពាក្យបណ្ដឹងទាក់ទងនឹងកុមារ។

## ការឃុំខ្លួនអនីតិជន - ការឃុំខ្លួនបណ្ដោះអាសន្ន

> - **មាត្រា ១០(២)(ខ) និង ១០(៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។**
> - **មាត្រា ៩៦ ១០០ ២១២ ដល់ ២១៤ និងមាត្រា ២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។**

បទដ្ឋានអន្តរជាតិមិនគាំទ្រឲ្យមានការឃុំខ្លួនបណ្ដោះអាសន្ន ចំពោះអនីតិជនឡើយ។ ក្នុងករណីភាគច្រើន ផលប្រយោជន៍ល្អបំផុតរបស់កុមារ ត្រូវបានការពារដោយការមិនបំបែកពួកគេចេញពីឪពុកម្ដាយ។[16] ការឃុំខ្លួនកុមារគួរតែជៀសវាងតាមតែអាចធ្វើបាន ហើយត្រូវបានយកមកអនុវត្តជាវិធានការចុងក្រោយ និងក្នុងរយៈពេលខ្លីបំផុតតែប៉ុណ្ណោះ។[17] ក្រមនីតិវិធីព្រហ្មទណ្ឌបានបង្កើតនូវតម្រូវការបន្ថែម អាស្រ័យទៅតាមអាយុរបស់កុមារ ឬជនជាប់ចោទអនីតិជន។ តម្រូវការបន្ថែមទាំងនេះមានដូចតទៅ ៖

### កុមារដែលមានអាយុតិចជាង ១៤ ឆ្នាំ៖

- មិនត្រូវឲ្យមានការឃាត់ខ្លួន (មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- មិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ប៉ុន្តែអាចនឹងត្រូវប្រគល់ទៅឲ្យឪពុកម្ដាយ/អ្នកអាណាព្យាបាល ឬមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រង់ចាំសេចក្ដីសម្រេចរបស់តុលាការ (មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- មិនត្រូវដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការទេ (មាត្រា ២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។

### អនីតិជនដែលមានអាយុ ១៤ ឆ្នាំ តែតិចជាង ១៦ ឆ្នាំ៖

- អាចស្ថិតនៅក្រោមការឃាត់ខ្លួនរបស់ប៉ូលីសរយៈពេលអតិបរមា ៣៦ ម៉ោង ចំពោះបទឧក្រិដ្ឋ និង ២៤ ម៉ោង ចំពោះបទមជ្ឈិម (មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

---

[15] កំណត់សម្គាល់៖ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ សំដៅលើអនីតិជន ជាជនទាំងឡាយណាដែលមានអាយុតិចជាង ១៨ ឆ្នាំ។ នៅក្នុងសៀវភៅនេះ ពាក្យថា "កុមារ" សំដៅតែទៅលើជនណាដែលមានអាយុក្រោម ១៤ ឆ្នាំ។ អ្នកដែលអាយុ ១៤ ឆ្នាំ តែតិចជាង ១៨ ឆ្នាំនឹងត្រូវបានហៅថា "អនីតិជន"។ ការបែងចែកនេះមានលក្ខណៈចាំបាច់ នៅពេលដែលយោងច្បាប់ជាតិ។

[16] មាត្រា ៩ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

[17] មាត្រា ៣៧(ខ) នៃអ.ស.ក ។

- ត្រូវមានឪពុកម្ដាយ អ្នកតំណាងស្របច្បាប់ ឬអ្នកទទួលភារកិច្ចលើអនីតិជន ដោយជូនដំណឹងដល់ពួកគាត់តាមគ្រប់មធ្យោបាយ កាលណាអនីតិជននោះ ត្រូវបានឃាត់ខ្លួន (មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- អាចស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្នរយៈពេលអតិបរមា ៤ខែ ចំពោះបទឧក្រិដ្ឋ (មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ឬចំពោះបទមជ្ឈិមមានរយៈពេលអតិបរមា ២ខែ ហើយមិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ (មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**អនីតិជនដែលមានអាយុ ១៦ ឆ្នាំ តែតិចជាង ១៨ ឆ្នាំ៖**

- អាចស្ថិតនៅក្រោមការឃាត់ខ្លួនរបស់ប៉ូលីសរយៈពេលអតិបរមា ៤៨ ម៉ោង ចំពោះបទឧក្រិដ្ឋ និង ៣៦ ម៉ោង ចំពោះបទមជ្ឈិម (មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- ត្រូវមានឪពុកម្ដាយ អ្នកតំណាងស្របច្បាប់ ឬអ្នកទទួលភារកិច្ចលើអនីតិជន ដោយជូនដំណឹងដល់ពួកគាត់តាមគ្រប់មធ្យោបាយ កាលណាអនីតិជននោះត្រូវបានឃាត់ខ្លួន (មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- អាចស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្នរយៈពេលអតិបរមា ៦ ខែ សម្រាប់បទឧក្រិដ្ឋ (មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ឬសម្រាប់បទមជ្ឈិមមានរយៈពេលអប្បបរមា ៤ ខែ ហើយមិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមា នៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ (មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

## សិទ្ធិទទួលបានជំនួយពីមេធាវី

- **មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"ជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌ ដែលចែងដោយច្បាប់ស្ដីអំពីលក្ខន្តិកៈមេធាវី ។"*
- **មាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ចែងថា៖ *"ជំនួយពីមេធាវីត្រូវតែមានដាច់ខាតនៅក្នុងករណី [...] កាលណាជនជាប់ចោទជាអនីតិជន។ ប្រសិនគ្មានការជ្រើសរើសដោយជនជាប់ចោទទេ មេធាវីត្រូវបានចាត់តាំងតាមគំនិតផ្ដើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី។"*

មាត្រា ១៤៣ និង ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ទាមទារជាចាំបាច់ ថាគ្រប់អនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តល្មើស ត្រូវមានមេធាវីជាដាច់ខាត។ ប្រសិនបើជនជាប់ចោទជាអនីតិជននោះ មិនបានជ្រើសរើសមេធាវីទេ តុលាការត្រូវចាត់តាំងមេធាវីឲ្យជននោះ។

## សិទ្ធិនៃជីវភាពឯកជន

> - **មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ចែងថា៖ *"សារព័ត៌មាន និងសាធារណជនអាចមិនឲ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ [...] នៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឲ្យធ្វើដូច្នេះ ។"*
> - **មាត្រា ៤០(២)(ខ)(៧) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ** ចែងថា៖ *"ក្នុងទិសដៅនេះ និងដោយគិតទៅនឹងបទប្បញ្ញត្តិនៃលិខិតូបករណ៍អន្តរជាតិដែលពាក់ព័ន្ធ រដ្ឋភាគីត្រូវធានា ជាពិសេសថា [....] ត្រូវគោរពយ៉ាងពេញលេញ នូវសិទ្ធិនៃជីវិតឯកជនរបស់ [កុមារ] នៅគ្រប់ដំណាក់កាលនៃនីតិវិធី ។"*

សវនាការព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងនីតិជន ជាទូទៅគួរតែបើកជាសាធារណៈដើម្បីអនុវត្តតាមសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ។ ក៏ប៉ុន្តែ នៅពេលដែលសវនាការពាក់ព័ន្ធនឹងអនីតិជន ការដាក់កំហិតអ្នកចូលរួមសវនាការគឺជាការស្របច្បាប់ ដើម្បីការពារជីវិតឯកជនរបស់កុមារ និងបញ្ចៀសផលវិបាកទៅថ្ងៃក្រោយ។ គ្រប់សវនាការពាក់ព័ន្ធនឹងអនីតិជនគួរតែដំណើរការជាអសាធារណៈ[18] ប៉ុន្តែក្នុងករណីដែលសវនាការជាអសាធារណៈមិនអាចធ្វើទៅបាន វិធានការណ៍ការពារជីវភាពឯកជនរបស់អនីតិជននៅពេលសវនាការគួរតែត្រូវបានអនុវត្ត។ ក្នុងគោលបំណងនេះ វិធីសាស្ត្រជាច្រើនដែលអាចអនុវត្តបាន មានដូចជា របាំងការពារ ឬការបើកសវនាការតាមរយៈការបង្ហាញសម្លេង តែមិនបង្ហាញមុខ ដោយប្រើទូរទស្សន៍។

## ការឃុំខ្លួនអនីតិជន - ការឃុំខ្លួនក្រោយសវនាការ

> - **មាត្រា ៣៩** ដល់ **៤០** នៃក្រមព្រហ្មទណ្ឌ ។

ផលប្រយោជន៍ល្អបំផុតរបស់កុមារត្រូវយកមកពិចារណាជាអាទិភាព នៅពេលបង្គាប់ ឬដាក់ទណ្ឌកម្មលើអនីតិជនល្មើសច្បាប់ព្រហ្មទណ្ឌ។[19] ការដាក់ពន្ធនាគារអនីតិជនដែលរកឃើញថាល្មើសច្បាប់ព្រហ្មទណ្ឌ ត្រូវបានចាត់ទុកជាវិធានការណ៍ចុងក្រោយបង្អស់ ដែលត្រូវបានអនុវត្តតែក្នុងករណីពិសេសមួយចំនួន។[20] មាត្រា ៣៩ និង ៤០ នៃក្រមព្រហ្មទណ្ឌចែងថា អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬ *"បុគ្គលិក*

---

[18] គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ - *បទអត្ថាធិប្បាយទូទៅលេខ ១០ សិទ្ធិកុមារនៅក្នុងយុត្តិធម៌អនីតិជន* CRC/C/GC/10 ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌទី៦៦។

[19] មាត្រា ៣៧(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[20] មាត្រា៣៧(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

*លក្ខណៈ របស់[អនីតិជន]* តម្រូវ។ កុមារមិនអាចជាកម្មវត្ថុនៃការដាក់ទណ្ឌកម្មព្រហ្មទណ្ឌឡើយ។ វិធានការណ៍ជំនួសពន្ធនាគារ ដែលតុលាការអាចអនុវត្ត រួមទាំងការដាក់ ឬប្រគល់អនីតិជនៈ

- ជាមួយឪពុកម្តាយ ឬអាណាព្យាបាល ឬបុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទុកចិត្ត។
- ទៅឲ្យសេវាសាធារណៈដែលសម្រាប់ទទួលបន្ទុកអនីតិជន។
- ទៅឲ្យអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។
- ទៅឲ្យមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។
- ឲ្យស្ថិតក្រោមការការពាររបស់តុលាការ។

ក្នុងករណីដែលអនីតិជនជាប់ទោសពន្ធនាគារ មាត្រា ១៦៦ នៃក្រមព្រហ្មទណ្ឌ ចែងថាអនីតិជននោះ "*ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន*" ហើយ "*ត្រូវស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែងសម្រាប់អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។*"

# ផ្នែកទី៣ ៖ ការសង្កេតការណ៍សវនាការ

ផ្នែកទី១នៃសៀវភៅមគ្គុទ្ទេសក៍នេះបានបរិយាយ អំពីអ្វីដែលជាការជំនុំជម្រះដោយយុត្តិធម៌ ដោយធ្វើការកត់សម្គាល់ថា ការជំនុំជម្រះដោយយុត្តិធម៌ពិតមានសារៈសំខាន់ មិនត្រឹមតែសម្រាប់កិច្ចការពារសិទ្ធិដល់ជនជាប់ចោទ និងជនរងគ្រោះប៉ុណ្ណោះទេ ថែមទាំងមានសារៈសំខាន់ដល់ការធានាបាននូវរដ្ឋបាលយុត្តិធម៌ល្អទៀតផង ដែលនេះគឺជាគន្លឹះឆ្ពោះទៅរកនីតិរដ្ឋ។ រីឯផ្នែកទី២វិញ បានផ្តោតការពិភាក្សាទៅសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាក់លាក់មួយចំនួន និងអត្ថន័យនៃសិទ្ធិទាំងនេះ ដែលមាននៅក្នុងច្បាប់ជាតិ និងអន្តរជាតិ រួមទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ មិនលម្អៀង និងមានសមត្ថកិច្ច ។

ដោយឡែក ផ្នែកទី៣នៃសៀវភៅមគ្គុទ្ទេសក៍នេះ នឹងរៀបរាប់អំពីបណ្តាដំណាក់កាល និងបញ្ហាជាក់ស្តែងនានា ដែលត្រូវយកមកពិចារណា នៅពេលសង្កេតការណ៍សវនាការ និងនៅពេលធ្វើរបាយការណ៍អំពីសង្កេតការណ៍នោះ។ ដូចដែលបានបញ្ជាក់ក្នុងផ្នែកខាងដើម សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាសិទ្ធិមូលដ្ឋានធានានូវនីតិវិធីតាមច្បាប់ និងរដ្ឋបាលយុត្តិធម៌ដ៏ត្រឹមត្រូវ។ ដូច្នេះ ការសង្កេតការណ៍សវនាការព្រហ្មទណ្ឌ មានសារៈសំខាន់ក្នុងការការពារសិទ្ធិមនុស្ស និងបឋមភាពនៃនីតិរដ្ឋ។ បន្ទាប់ពីបានរៀបរាប់អំពីច្បាប់ និងបទដ្ឋាននានា ពាក់ព័ន្ធនឹងការជំនុំជម្រះដោយយុត្តិធម៌ ផ្នែកទី៣នេះនឹងបង្ហាញនូវលក្ខខណ្ឌ និងទិដ្ឋភាពជាក់ស្តែងទាំងឡាយ ដែលចាំបាច់សម្រាប់ការសង្កេតការណ៍សវនាការ។ ផ្នែកនេះគួរតែត្រូវបានអនុវត្តត្រឹមតែជាមគ្គុទ្ទេសក៍ប៉ុណ្ណោះ ហើយអាចនឹងទាមទារឲ្យមានការកែសម្រួល អាស្រ័យតាមគោលបំណងជាក់លាក់នៃស្ថាប័នសង្កេតការណ៍សិទ្ធិទាក់ទងនឹងការជំនុំជម្រះ ("ស្ថាប័នសង្កេតការណ៍") ឬអាស្រ័យតាមវិសោធនកម្មច្បាប់ ដែលទាក់ទងនឹងសិទ្ធិទទួលបានជំនុំជម្រះដោយយុត្តិធម៌។

ដូចដែលនឹងលំអិតបន្ថែមទៀតក្នុងផ្នែកទី៣នេះ បណ្តាចំនុចខាងក្រោម នឹងត្រូវយកមកពិចារណានៅពេលសង្កេតការណ៍សវនាការ៖

- ការរៀបចំមុនពេលសង្កេតការណ៍សវនាការ
- ដំណើរការការសង្កេតការណ៍សវនាការ
- ការពិភាក្សា និងតស៊ូមតិ
- ការរក្សាទុកទិន្នន័យ
- ការវាយតម្លៃគម្រោងសង្កេតការណ៍សវនាការ។

## ក. ការរៀបចំមុនពេលសង្កេតការណ៍សវនាការ

គម្រោងសង្កេតការណ៍សវនាការ អាចទទួលបានគុណភាពខ្ពស់ ជោគជ័យ និងប្រសិទ្ធភាព អាស្រ័យលើការធ្វើផែនការ និងការរៀបចំ នៅមុនពេលសង្កេតការណ៍សវនាការ។ ដូចដែលនឹងលំអិតបន្ថែមទៀតនៅក្នុងផ្នែកនេះ ស្ថាប័នសង្កេតការណ៍នឹងត្រូវរៀបចំតាមការជាក់ស្តែង នូវចំណុចខាងក្រោម៖

- ការកំណត់អំពីគោលដៅ
- ការជ្រើសរើសសវនាការ
- ការជ្រើសរើសមន្រ្តីសង្កេតការណ៍សវនាការ
- ការផ្តល់ព័ត៌មានដល់មន្រ្តីសង្កេតការណ៍សវនាការ
- ការសិក្សាស្រាវជ្រាវបឋម ដោយមន្រ្តីសង្កេតការណ៍សវនាការ
- ការពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយភាគីពាក់ព័ន្ធ
- ការពិចារណាទៅលើការអនុវត្តជាក់ស្តែង

**គោលដៅ**

ជាការចាប់ផ្តើម ស្ថាប័នសង្កេតការណ៍ត្រូវពិចារណាអំពីគោលបំណង និងកំណត់គោលដៅឲ្យបានច្បាស់លាស់ សម្រាប់ការសង្កេតការណ៍សវនាការ។ ការកំណត់គោលដៅនេះ អាចជាដំណាក់កាលពិចារណាដ៏មានសារៈសំខាន់បំផុត ពីព្រោះវាជះឥទ្ធិពលខ្លាំង ទៅលើដំណាក់កាលរៀបចំបឋមដ៏ទៃទៀត រាប់ទាំងការជ្រើសរើសសវនាការសម្រាប់សង្កេតការណ៍ និងមន្ត្រីសង្កេតការណ៍សវនាការ (ដែលនឹងលំអិតបន្ថែមខាងក្រោម) ។ ជារឿយៗ ការសង្កេតការណ៍សវនាការមានគោលដៅទូទៅ មួយចំនួន ឬទាំងអស់ ដូចខាងក្រោម៖

- **ភាពអាចមើលឃើញ៖** វត្តមានរបស់មន្ត្រីសង្កេតការណ៍សវនាការ ជាសញ្ញាប្រាប់ដល់អាជ្ញាធរ និងសាធារណជន អំពីប្រយោជន៍នៃការសង្កេតភាពយុត្តិធម៌នៃនីតិវិធីព្រហ្មទណ្ឌ និងជំរុញឲ្យតុលាការផ្តល់នូវការជំនុំជម្រះមួយដែលយុត្តិធម៌ ។
- **យុត្តិធម៌៖** ធានានូវការគោរព និងការអនុវត្តសិទ្ធិជនជាប់ចោទ ទទួលបានការជំនុំជម្រះដោយយុត្តិធម៌។
- **ការប្រមូលព័ត៌មាន៖** ប្រមូលព័ត៌មានបន្ថែម អំពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដោយតុលាការ។ ទទួលបានព័ត៌មានលំអិត អំពីសវនាការជាក់លាក់ណាមួយ និងអំពីកត្តាខាងក្រៅដែលជះឥទ្ធិពលលើការជំនុំជម្រះ។
- **ការធ្វើរបាយការណ៍៖** ផ្តល់ព័ត៌មានដល់សាធារណជន អាជ្ញាធរ និងអង្គការអន្តរជាតិ អំពីភាពវិជ្ជមាន និងសមិទ្ធិផល ក៏ដូចជាភាពមិនប្រក្រតី និងភាពមិនសមស្របនឹងនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងការប្រព្រឹត្តស្របច្បាប់ដែលធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ គោលបំណងចម្បងនៃការធ្វើរបាយការណ៍អំពីការរំលោភបំពានទាំងនេះ គឺជំរុញឲ្យមានការផ្លាស់ប្តូរនៅក្នុងការអនុវត្តជាក់ស្តែង និងច្បាប់ និងផ្តល់អនុសាសន៍ ដើម្បីធានាថាច្បាប់ជាតិ និងការអនុវត្តជាក់ស្តែង អនុឡោមតាមបទដ្ឋានអន្តរជាតិ។

និយាយឲ្យលំអិតជាងនេះបន្តិច ស្ថាប័នសង្កេតការណ៍នឹងទទួលឥទ្ធិពល ពីរបៀបវារៈ និងផ្នែកដែលខ្លួនយកចិត្តទុកដាក់ជាពិសេស ដូចជាការផ្តោតទៅលើបណ្តុំសិទ្ធិមួយចំនួន ឬប្រភេទនៃសិទ្ធិសកម្មណាមួយ។ ការកំណត់គោលដៅនៃការសង្កេតការណ៍សវនាការនឹងធានាថាគោលដៅតូច និងគោលដៅធំ នៃគំនិតផ្តួចផ្តើមការសង្កេតការណ៍សវនាការ មានលក្ខណៈច្បាស់លាស់តាំងពីពេលចាប់ផ្តើម ហើយនឹងជួយឲ្យស្ថាប័នសង្កេតការណ៍ អាចជ្រើសរើសប្រភេទសវនាការសម្រាប់សង្កេតការណ៍។ ដើម្បីកំណត់គោលដៅនេះ ស្ថាប័នសង្កេតការណ៍គួរតែ៖

- ធានាគ្មានទំនាស់ផលប្រយោជន៍រវាងការគោលដៅដែលបានកំណត់។ ឧទាហរណ៍៖ នៅពេលស្ថាប័នមួយសង្កេតការណ៍ អំពីសិទ្ធិជនជាប់ចោទ នៅក្នុងសវនាការ ស្ថាប័ននេះក៏ត្រូវពិចារណាផងដែរ ថាតើខ្លួនបានធ្វើការជាមួយនឹងជនរងគ្រោះឬទេ ឬថាតើខ្លួនមានផលប្រយោជន៍ នៅក្នុងសវនាការ ដែលសង្កេតដែរឬទេ ពីព្រោះថាការណ៍អាចនឹងជះឥទ្ធិពល ភាពឯករាជ្យ និងមិនលម្អៀងនៃការសង្កេតការណ៍នេះ។
- ពិចារណាថា តើគោលដៅនីមួយៗ នឹងធ្វើឲ្យសកម្មភាពរបស់មន្ត្រីសង្កេតការណ៍លេចចេញជារូបរាងដែរឬទេ នៅក្នុងអំឡុងពេលដំណើរការសង្កេតការណ៍សវនាការ។ រាល់ការលំបាកទាំងឡាយ គួរតែត្រូវបានបំភ្លឺឲ្យច្បាស់ និងដោះស្រាយឲ្យហើយស្រេច នៅដំណាក់កាលដំបូង នៃការរៀបចំការសង្កេតការណ៍សវនាការ បំណងកាត់បន្ថយជាអតិបរមានូវវិវាទផលប្រយោជន៍រវាងគោលដៅ ដែលអាចកើតមាននាថ្ងៃមុខ។
- ពិចារណាទៅលើ ផលប៉ះពាល់អវិជ្ជមាន ដែលកើតចេញពីការសង្កេតការណ៍សវនាការ ។ ឧទាហរណ៍៖ តុលាការអាចនឹងសម្រេចផ្តន្ទាទោសយ៉ាងតឹងរឹងជាងធម្មតា ដល់ជនជាប់ចោទ ដោយសារតែវត្តមានរបស់មន្ត្រីសង្កេតការណ៍សវនាការនៅក្នុងសវនាការ។[21]

**ករណីសិក្សាទី៣ ៖ គម្រោងសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា**

គម្រោងនេះមានគោលដៅ កែលម្អនីតិវិធី និងការអនុវត្តនៅក្នុងតុលាការកម្ពុជា ឲ្យមានលក្ខណៈកាន់តែប្រសើរឡើង ដែលឈានទៅរកការគោរពខ្ជាប់ខ្ជួនជាងមុន នូវបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌។ បុគ្គលិកគម្រោង បានសង្កេតការណ៍សវនាការព្រហ្មទណ្ឌ នៅសាលាដំបូងរាជធានីភ្នំពេញ និងសាលាដំបូងខេត្តកណ្តាល តាំងពីខែសីហា ឆ្នាំ២០០៩ មកម្ល៉េះ។ គម្រោងនេះដំណើរការក្រោមកិច្ចឧបត្ថម្ភពីសំណាក់ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍអន្តរជាតិ នៃសហរដ្ឋអាមេរិក និងវិទ្យាស្ថានគ្រប់គ្រងបូព៌ាបច្ចឹម។

មន្ត្រីសង្កេតការណ៍សវនាការនៃម.ស.ម.ក ធ្វើដំណើរទៅកាន់តុលាការជារៀងរាល់ថ្ងៃ និងចូលរួមសវនាការឲ្យបានច្រើន តាមដែលអាចធ្វើទៅបាន ដើម្បីកត់ត្រាការគោរព សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយប្រើតារាងសង្កេតការណ៍សវនាការ ដែលត្រូវបានរៀបចំទុកជាមុន។ ទិន្នន័យដែលប្រមូលបាន នឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៅលើអ៊ីនធឺណិត ដែលសាធារណជនអាចចូលមើលបាន។ បុគ្គលិកគម្រោង ចងក្រងទិន្នន័យទាំងនោះ ជារបាយការណ៍ ពីរដងក្នុងមួយឆ្នាំ ដើម្បីបង្ហាញពីទិន្នន័យ ដែលប្រមូលបាននៅក្នុងអំឡុងពេលរបាយការណ៍មុនៗ ក្នុងគោលបំណងកំណត់ពីភាពផ្លាស់ប្តូរ។

របាយការណ៍នីមួយៗ បង្ហាញពីមូលដ្ឋានគ្រឹះពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌ នៅក្នុងច្បាប់ជាតិ និងអន្តរជាតិ និងផ្តល់អនុសាសន៍ជាក់ស្តែង ដើម្បីបង្កើនការគោរពបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ ។ មុននិងក្រោយពេលចេញផ្សាយរបាយការណ៍ បុគ្គលិកគម្រោងធ្វើការពិភាក្សាជាមួយដៃគូពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌ បំណងផ្លាស់ប្តូរយោបល់ក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងលើកទឹកចិត្តឲ្យមានការអនុវត្តអនុសាសន៍។ គម្រោងធ្វើការតស៊ូមតិបែបស្ថាបនាជាមួយតុលាការ។ ប្រធានសាលាដំបូងរាជធានីភ្នំពេញ និងខេត្តកណ្តាល ត្រូវបានផ្តល់ព័ត៌មាន និងបច្ចុប្បន្នកម្មពីដំណើរការរបស់គម្រោង តាំងពីពេលចាប់ផ្តើម រហូតដល់ការអនុវត្ត៕

[21] ទំព័រទី៥ នៃសៀវភៅណែនាំស្តីពីការសង្កេតការណ៍នីតិវិធីព្រ
(២០០៩)។

## សិទ្ធិសំខាន់ៗដែលជ្រើសរើសសម្រាប់ការសង្កេតការណ៍សវនាការ

ការជ្រើសរើសសិទ្ធិសម្រាប់ការសង្កេតការណ៍សវនាការ ពិតជាមានសារៈសំខាន់។ ជាឧទាហរណ៍ អាចជាការជ្រើសរើសវិភាគ ថាតើសិទ្ធិដែលចែងដោយច្បាប់ (សិទ្ធិជនជាប់ចោទពាក់ព័ន្ធនឹងការជំនុំជម្រះ) ត្រូវបានគោរព និងអនុវត្តជាក់ស្តែងនៅក្នុងសវនាការដែរឬទេ ឬក៏វិភាគពីអង្គសេចក្តីនៃរឿងក្តី ឬក៏ទាំងពីរ។ ស្ថាប័នសង្កេតការណ៍ត្រូវសម្រេចចិត្ត ថាតើគម្រោងត្រូវផ្តោតទៅលើអ្វីជាប្រាកដ ដើម្បីកំណត់ទិសដៅរបស់គម្រោង និងអាចកំណត់បាននូវគោលដៅដែលអាចសម្រេចបាន។

## ការជ្រើសរើសសវនាការ

ដូចដែលបានបកស្រាយខាងលើ គោលដៅ ផលប្រយោជន៍ និងជំនាញរបស់ស្ថាប័នសង្កេតការណ៍ នឹងជះឥទ្ធិពលលើការជ្រើសរើសប្រភេទសវនាការសម្រាប់សង្កេត និងមន្ត្រីសង្កេតការណ៍។ កត្តាដែលជះឥទ្ធិពលទាំងនោះ មានដូចខាងក្រោម៖[22]

- សារៈសំខាន់នៃនយោបាយ និងសិទ្ធិមនុស្សនៅក្នុងនីតិវិធី
- លក្ខណៈតំណាងនៃប្រភេទសវនាការ
- ភាពមិនប្រក្រតីនៃសវនាការដែលបានគិតទុកជាមុន
- ប្រវត្តិដែលពាក់ព័ន្ធនឹងសវនាការ
- ចំណាប់អារម្មណ៍របស់ប្រព័ន្ធសារព័ត៌មានលើសំណុំរឿង
- ឋានៈនៃភាគីពាក់ព័ន្ធនៅក្នុងសវនាការ រាប់ទាំងជនជាប់ចោទ និងជនរងគ្រោះ
- ប្រភេទនៃបទចោទប្រកាន់

## ការជ្រើសរើសមន្ត្រីសង្កេតការណ៍សវនាការ

កម្រិតនៃភាពជំនាញរបស់មន្ត្រីសង្កេតការណ៍សវនាការ ជាបញ្ហាមួយដែលស្ថាប័នសង្កេតការណ៍ត្រូវយកមកពិចារណា។ នៅខណៈដែលការសម្រេចចិត្តណាមួយ តែងតែនាំមកនូវគុណប្រយោជន៍ និងគុណវិបត្តិ ជាការសំខាន់ណាស់ ដែលមន្ត្រីសង្កេតការណ៍សវនាការ៖

- មានភាពឯករាជ្យ និងមិនលម្អៀង និងត្រូវបានគេមើលឃើញថាដូច្នេះ
- មានចំណេះដឹងពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងបរិបទសិទ្ធិមនុស្ស
- យល់ដឹងពីមូលដ្ឋានច្បាប់នៃសិទ្ធិទាំងនេះ
- យល់ពីតួនាទីរបស់មន្ត្រីសង្កេតការណ៍សវនាការ ដែលរាប់ទាំងភាពមិនលំអៀង និងមិនចូលរួមពាក់ព័ន្ធក្នុងនីតិវិធី ដោយមិននិយាយទៅកាន់ភាគីណាមួយ។

ស្ថាប័នសង្កេតការណ៍អាចផ្តល់ជាជំនួយ ដល់មន្ត្រីសង្កេតការណ៍សវនាការ ទាក់ទងនឹងចំណុចទី២ ដល់ទី៤ ខាងលើ តាមរយៈការផ្តល់ជាវគ្គបណ្តុះបណ្តាល និងការណែនាំតម្រង់ទិស។

---

[22] ដូចខាងលើ។

## ការផ្តល់ព័ត៌មានដល់មន្ត្រីសង្កេតការណ៍សវនាការ

តាំងពីពេលចាប់ផ្តើមគម្រោង រហូតដល់មុនពេលសង្កេតការណ៍សវនាការ ស្ថាប័នសង្កេតការណ៍ត្រូវធានាថា មន្ត្រីសង្កេតការណ៍សវនាការ បានទទួលពេញលេញនូវព័ត៌មានដែលពាក់ព័ន្ធឲ្យបានច្រើនតាមដែលអាចធ្វើបាន។ ព័ត៌មានទាំងនោះត្រូវលំអិតគ្រប់គ្រាន់ ដើម្បីពន្យល់ពីបេសកកម្មឲ្យបានត្រឹមត្រូវ បង្ហាញពីដំណាក់កាលសំខាន់ៗប្រសិនបើមាន និងផ្តល់ឲ្យមន្ត្រីសង្កេតការណ៍សវនាការនូវព័ត៌មានដែលចាំបាច់ និងចែកចាយឯកសារដែលមាន។ មន្ត្រីសង្កេតការណ៍សវនាការត្រូវយល់ច្បាស់ ពីចំណុចមួយចំនួនដូចខាងក្រោម៖

- គោលបំណងនៃគម្រោងសង្កេតការណ៍សវនាការ រាប់ទាំងតួនាទី និងការទទួលខុសត្រូវ ដើម្បីធានាថាវិសាលភាពនៃតួនាទី និងការងាររបស់មន្ត្រីសង្កេតការណ៍សវនាការ ត្រូវបានកំណត់ច្បាស់លាស់
- ចំណុចដែលត្រូវពិចារណាពេលសង្កេតការណ៍សវនាការ
- ច្បាប់ថតចម្លង ឬកម្រងគោលការណ៍ណែនាំអន្តរជាតិ ឬលិខិតូបករណ៍ ដែលពាក់ព័ន្ធនឹងនីតិវិធី
- ព័ត៌មានសំខាន់ៗ ដូចជាព័ត៌មានលំអិតអំពីទីតាំងតុលាការ ម៉ោងសវនាការ ឬតម្រូវការផ្សេងៗទៀតក្នុងតុលាការ
- ព័ត៌មានលំអិត អំពីសវនាការ ដូចជា ភាគីនៃនីតិវិធី ឈ្មោះបុគ្គលិកតុលាការ អង្គហេតុរឿងក្តី និងប្រភេទនៃបទចោទប្រកាន់
- គោលការណ៍នានា ឬក្រមសីលធម៌ ដែលត្រូវប្រើនៅពេលសង្កេតសវនាការ
- ព័ត៌មានលំអិតសម្រាប់ទាក់ទងបុគ្គលិកពាក់ព័ន្ធក្នុងស្ថាប័នសង្កេតការណ៍ ក្នុងករណីដែលក្នុងអំឡុងពេលអនុវត្តគម្រោងសង្កេតការណ៍សវនាការ មន្ត្រីសង្កេតការណ៍សវនាការត្រូវការព័ត៌មានពាក់ព័ន្ធនឹងបញ្ហាគោលនយោបាយ ឬបញ្ហាបន្ទាន់ដែលទាមទារឲ្យមានការដោះស្រាយឆាប់រហ័ស
- អនុស្សរណៈយោគយល់គ្នា ឬលិខិតអនុញ្ញាត ដែលផ្តល់ដោយតុលាការ (ដូចនឹងពិភាក្សាខាងក្រោម)
- ព័ត៌មានសុវត្ថិភាព រួមទាំងវិធីសាស្ត្រដែលត្រូវអនុវត្ត នៅពេលមានការគំរាមគំហែង ឬការព្រួយបារម្ភផ្សេងៗ

វាក៏ជាការប្រសើរផងដែរ ប្រសិនបើមន្ត្រីសង្កេតការណ៍សវនាការថ្មីដែលទើបនឹងអនុវត្តការងារ ត្រូវបានអមដោយមន្ត្រីសង្កេតការណ៍សវនាការដែលមានបទពិសោធន៍ខ្ពស់ នៅក្នុងអំឡុងពេលសង្កេតការណ៍សវនាការណាមួយ។ ការធ្វើរបៀបនេះ អាចឲ្យមន្ត្រីសង្កេតការណ៍សវនាការថ្មី មានឱកាសផ្សាំខ្លួនទៅនឹងដំណើរប្រព្រឹត្តទៅនៅក្នុងតុលាការ និងការងារទាំងឡាយពាក់ព័ន្ធនឹងការសង្កេតការណ៍សវនាការ ជាមួយនឹងគ្រូម្នាក់ ដែលអាចឆ្លើយនឹងសំណួរដែលអាចមាន ពាក់ព័ន្ធនឹងតុលាការ តារាងសង្កេតការណ៍សវនាការ នៅក្នុងការអនុវត្តជាក់ស្តែង។

### ការអនុវត្តដ៏ល្អបំផុត៖ ការជូនដំណឹងដល់តុលាការ អំពីការសង្កេតការណ៍សវនាការ

នៅពេលចាប់ផ្តើមអនុវត្តគម្រោងសង្កេតការណ៍សវនាការ ការជូនដំណឹងជាមុនដល់តុលាការអំពីទីកន្លែងនៃការសង្កេតការណ៍សវនាការ ត្រូវបានចាត់ទុកជាការអនុវត្តដ៏ល្អបំផុត។ ស្ថាប័នសង្កេតការណ៍ គួរតែទាក់ទងប្រធានតុលាការពាក់ព័ន្ធ ដើម្បីជូនដំណឹងអំពីគម្រោងសង្កេតការណ៍សវនាការ និងផ្តល់ដំណឹងថាសវនាការដែលដំណើរការនៅក្នុងតុលាការ នឹងត្រូវបញ្ចូលទៅក្នុងការសង្កេតរបស់គម្រោង។ ជាការអនុវត្តដ៏ល្អ ក្នុងការជួបប្រជុំជាមួយចៅក្រម និងបុគ្គលតុលាការ ដើម្បីជូនដំណឹងអំពីមូលហេតុនៃការសង្កេតការណ៍។ ការជួបប្រជុំនេះក៏ផ្តល់ឱកាសផងដែរ ដល់មន្ត្រីសង្កេតការណ៍សវនាការ ក្នុងការបង្កើតទំនាក់ទំនងល្អជាមួយចៅក្រម និងបុគ្គលិកតុលាការ។

### ការវាយតម្លៃខាងហានិភ័យសុវត្ថិភាព

ស្ថាប័នសង្កេតការណ៍គួរវាយតម្លៃពីហានិភ័យសុវត្ថិភាព ដើម្បីកំណត់ថាតើអាចមានហានិភ័យអ្វីខ្លះពាក់ព័ន្ធសុវត្ថិភាព ដែលកើតមានដោយសារគម្រោងសង្កេតការណ៍សវនាការ ឬដោយសារការសង្កេតការណ៍តុលាការណាមួយ ប្រសិនបើមានហានិភ័យកើតឡើង ត្រូវចាត់វិធានការណ៍ ដើម្បីកាត់បន្ថយហានិភ័យទាំងនោះ។ មន្ត្រីសង្កេតការណ៍សវនាការគួរទទួលបានព័ត៌មានអំពីហានិភ័យនេះ និងគួរតែដឹងថាខ្លួនជាអ្នកទទួលខុសត្រូវទាំងស្រុង ចំពោះសុវត្ថិភាពផ្ទាល់របស់ខ្លួន។ ក្នុងករណីដែលមិនអាចគ្រប់គ្រងហានិភ័យនេះបាន ស្ថាប័នសង្កេតការណ៍ត្រូវពិចារណាសារជាថ្មី ថាតើត្រូវបន្តអនុវត្តគម្រោងសង្កេតការណ៍សវនាការ ឬសង្កេតការណ៍តុលាការនោះ ឬយ៉ាងណា (សូមមើលករណីសិក្សាទី៣ សម្រាប់វិធីសាស្ត្រដែលអនុវត្តដោយម.ស.ម.ក។

## ខ. ការអនុវត្តការសង្កេតការណ៍សវនាការ

នៅពេលដែលដំណាក់កាលត្រួតពិនិត្យ និងស្រាវជ្រាវមុនពេលសង្កេតសវនាការ ត្រូវបានបញ្ចប់ ដំណើរការសង្កេតការណ៍សវនាការ ត្រូវចាប់ផ្តើម។ ផ្នែកនេះនឹងពិចារណា លើប្រធានបទដូចខាងក្រោម៖

- តារាងសង្កេតការណ៍សវនាការ
- ការចូលទៅកាន់បន្ទប់សវនាការ
- ការធ្វើកំណត់ត្រា
- ការមិនធ្វើអន្តរាគមន៍ក្នុងសវនាការ
- សិទ្ធិសំខាន់ៗដែលជ្រើសរើសសម្រាប់សង្កេតការណ៍សវនាការ
- សេចក្តីថ្លែងការណ៍ជាសាធារណៈ ធ្វើនៅក្នុងសវនាការ។

## តារាងសង្កេតការណ៍សវនាការ

**ករណីសិក្សាទី៤ ៖ តារាងសង្កេតការណ៍សវនាការនៃម.ស.ម.ក**

ម.ស.ម.ក បានបង្កើតតារាងសង្កេតការណ៍សវនាការ សម្រាប់ប្រើប្រាស់នៅក្នុងគម្រោងសង្កេតការណ៍សវនាការ។ តារាងសង្កេតការណ៍សវនាការនេះ ស្របតាមបរិបទប្រទេសកម្ពុជា ដោយបញ្ចូលសំណួរជាច្រើនទាក់ទងនឹង សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងបរិបទកម្ពុជា។ តារាងសង្កេតការណ៍សវនាការ ដែលអាចប្រើជាគំរូ អាចរកបាននៅក្នុងឧបសម្ព័ន្ធទី១ នៃសៀវភៅនេះ។ សំណួរនីមួយៗ ពាក់ព័ន្ធនឹងការការពារជាក់លាក់ ដែលធានាដោយច្បាប់ជាតិ និងអន្តរជាតិ ៕

តារាងសង្កេតការណ៍សវនាការ ជាវិធីសាស្ត្រមួយ ដែលស្ថាប័នសង្កេតការណ៍ អាចប្រើសម្រាប់សង្កេតសវនាការ។ តារាងនេះ បង្ហាញចំណុចជាច្រើន ដែលមន្ត្រីសង្កេតការណ៍សវនាការ ត្រូវពិចារណានៅពេលសង្កេតសវនាការ។ តារាងសង្កេតការណ៍នេះ ត្រូវបានបង្កើតឡើងស្របតាមបរិបទ ដែលបង្ហាញពីចំណុចដែលមន្ត្រីសង្កេតការណ៍សវនាការ គួរពិចារណា និងវិភាគនៅពេលសង្កេតសវនាការ។ ទម្រង់នៃតារាងនេះ ត្រូវបានបែងចែកស្របតាមដំណាក់កាលនីតិវិធីច្បាប់ ភ្ជាប់សិទ្ធិជំនុំជម្រះជាក់លាក់នីមួយៗ ដែលគួរតែត្រូវបានការពារ។ តារាងនេះដើរតួនាទីជាចំណុចរួមមួយ ដែលបែងចែកជាផ្នែកតូចៗលំអិតជាក់លាក់ ដើម្បីកំណត់ជាទម្រង់មួយ។ បន្ថែមពីលើនេះ តារាងផ្តល់នូវភាពដូចគ្នាដែលអាចប្រើបានដោយមន្ត្រីសង្កេតការណ៍សវនាការទាំងអស់។ លទ្ធផលដែលទទួលបានអាចប្រើប្រាស់សម្រាប់ប្រៀបធៀប និងជាទិន្នន័យដែលមានបរិមាណ។ ដូច្នេះ តារាងនេះ ជាឧបករណ៍ដ៏មានសារៈសំខាន់បំផុត សម្រាប់អនុវត្តការសង្កេតការណ៍សវនាការ។ បណ្តាស្ថាប័នសង្កេតការណ៍ ដែលជ្រើសរើសប្រើតារាងសង្កេតការណ៍សវនាការ គួរគប្បីបង្កើតតារាងមួយដែលលំអិត ឆ្លុះបញ្ចាំងគោលដៅនៃការសង្កេតការណ៍សវនាការ។ តារាងសង្កេតការណ៍សវនាការ ត្រូវតែងាយស្រួលប្រើសម្រាប់មន្ត្រីសង្កេតការណ៍សវនាការ ដើម្បីអាចបំពេញបាននៅក្នុងពេលសវនាការ។ អាស្រ័យហេតុនេះហើយទើបអក្សរនៅក្នុងតារាងនេះ ត្រូវមានចំនួនតិច។ ដូច្នេះ ប្រអប់សម្រាប់គូស មានសារៈប្រយោជន៍ នៅពេលដែលសំណួរនៅក្នុងតារាង អាចឆ្លើយបានដោយពាក្យថា "មាន" ឬ "គ្មាន"។ ការធ្វើរបៀបនេះក៏អាចកាត់បន្ថយបានជាអតិបរមា នូវការពឹងផ្អែកលើការចងចាំរបស់មន្ត្រីសង្កេតការណ៍ សវនាការ និងជួយធានាថាទិន្នន័យដែលទទួលបាន មានភាពត្រឹមត្រូវ និងសុក្រិត។

នៅពេលដែលមានតារាងសង្កេតការណ៍សវនាការហើយ មន្ត្រីសង្កេតការណ៍សវនាការត្រូវផ្សាំខ្លួនឯងទៅនឹងលក្ខខ័ណ្ឌនានា និងយល់ច្បាស់អំពីអត្ថន័យនៃការជ្រើសរើសប្រអប់នីមួយៗក្នុងតារាង។ មន្ត្រីសង្កេតការណ៍សវនាការគួរធ្វើការកត់ត្រាការអនុវត្តលក្ខខ័ណ្ឌនីមួយៗ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់តារាងនៅក្នុងការអនុវត្តជាក់ស្តែង។ គំរូរបស់តារាងសង្កេតការណ៍សវនាការ អាចរកបាននៅក្នុងផ្នែកឧបសម្ព័ន្ធនៃសៀវភៅមគ្គុទ្ទេសក៍នេះ។

## ការចូលទៅកាន់បន្ទប់សវនាការ

មន្ត្រីសង្កេតការណ៍សវនាការ គួរតែអាចចូលទៅក្នុងបន្ទប់សវនាការ ដោយមិនបាច់ចុះឈ្មោះ។ ប៉ុន្តែ ករណីមានសំណើឲ្យធ្វើដូច្នេះ មន្ត្រីសង្កេតការណ៍សវនាការត្រូវត្រៀមជាស្រេច ដើម្បី

ពន្យល់មន្ត្រីតុលាការ និងអ្នកពាក់ព័ន្ធ អំពីគោលដៅនៃគម្រោង និងគោលបំណងនៃការសង្កេតការណ៍។

មន្ត្រីសង្កេតការណ៍សវនាការគួរតែទៅដល់តុលាការឲ្យបានមុន ហើយដឹងច្បាស់ពីកាលវិភាគរបស់តុលាការ។ តុលាការកម្ពុជាខ្លះបិទផ្សាយកាលវិភាគប្រចាំថ្ងៃ លើក្តារខៀនព័ត៌មាននៅកន្លែងអង្គុយរង់ចាំរបស់សាធារណជន។ ឧទាហរណ៍ នៅសាលាដំបូងរាជធានីភ្នំពេញ ក្តារខៀនព័ត៌មានស្ថិតនៅកន្លែងរង់ចាំរបស់សាធារណជន ដែលនៅជិតផ្លូវចូលជាន់ផ្ទាល់ដី។ ប៉ុន្តែ ពេលខ្លះពុំមានការបិទផ្សាយពីកាលវិភាគសវនាការឡើយ នៅឯតុលាការដែលបានសង្កេត។ ក្នុងករណីបែបនេះ មន្ត្រីសង្កេតការណ៍សវនាការត្រូវទៅកាន់បន្ទប់សវនាការ និងសួរបុគ្គលិកតុលាការអំពីកាលវិភាគសវនាការ។

នៅក្នុងបន្ទប់សវនាការ មន្ត្រីសង្កេតការណ៍សវនាការត្រូវអង្គុយនៅកន្លែងសមរម្យមួយដែលអាចសង្កេត ឮច្បាស់ និងងាយស្រួលតាមដានការជំនុំជម្រះ។ គណៈកម្មាការអ្នកច្បាប់អន្តរជាតិ បានបង្ហាញពីចំណុចពីរដែលគួរពិចារណាបន្ថែមទៀតៈ

- មន្ត្រីសង្កេតការណ៍សវនាការគួរតែអង្គុយនៅ**កន្លែងដែលលេចធ្លោ** និងគួរតែជ្រើសរើសកន្លែងនៅក្នុងបន្ទប់សវនាការ ដែលធ្វើឲ្យវត្តមានរបស់ខ្លួនមានប្រសិទ្ធិភាព[23]
- មន្ត្រីសង្កេតការណ៍សវនាការគួរតែអង្គុយនៅ**កន្លែងអព្យាក្រឹត** និងគួរតែជ្រើសរើសកន្លែងនៅក្នុងបន្ទប់សវនាការ ដែលរក្សាបាននូវភាពមិនលំអៀង។[24]

នៅប្រទេសកម្ពុជា មន្ត្រីសង្កេតការណ៍សវនាការ នឹងអង្គុយនៅកន្លែងសម្រាប់សាធារណជន គោលការណ៍ដែលរៀបរាប់ខាងលើ ត្រូវតែគោរព។ លើសពីនេះ មន្ត្រីសង្កេតការណ៍សវនាការគួរតែអង្គុយនៅជួរមុខ ជាជាងអង្គុយនៅកន្លែងដែលបិទបាំង ព្រោះអាចនាំឲ្យប៉ះពាល់ដល់គុណភាពនៃការសង្កេត។

សវនាការត្រូវបើកជាសាធារណៈ លើកលែងតែករណីពិសេសមួយចំនួន។ ប្រសិនបើមន្ត្រីសង្កេតការណ៍សវនាការ ត្រូវបានហាមឃាត់មិនឲ្យចូលក្នុងបន្ទប់សវនាការ ដោយបុគ្គលិកតុលាការណាម្នាក់ នោះមន្ត្រីសង្កេតការណ៍សវនាការត្រូវពន្យល់ប្រាប់ថា ខ្លួនចូលរួមសវនាការ ដើម្បីតែសង្កេតមើលការជំនុំជម្រះប៉ុណ្ណោះ។ ក្នុងករណីនៅតែមានការហាមឃាត់មិនឲ្យចូល មន្ត្រីសង្កេតការណ៍សវនាការត្រូវកត់ត្រាពីមូលហេតុនៃការហាមឃាត់ រួមទាំងមូលហេតុដែលផ្តល់ដោយចៅក្រមជំនុំជម្រះ។ ការធ្វើរបៀបនេះ អាចឲ្យមន្ត្រីសង្កេតការណ៍សវនាការពិចារណា ថាតើមូលហេតុដែលនាំឲ្យដំណើរការសវនាការជាអសាធារណៈនេះ ស្របតាមច្បាប់ជាតិ និងអន្តរជាតិ ដែលចែងអំពីករណីលើកលែងទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ដែរឬទេ។ មន្ត្រីសង្កេតការណ៍សវនាការ មិនត្រូវសុំទាមទារចូលក្នុងបន្ទប់សវនាការឡើយ ហើយត្រូវរក្សាការគួរសមគ្រប់ពេលវេលា។ ស្ថាប័នសង្កេតការណ៍អាចទាក់ទងជាមួយតុលាការ និងក្រសួងយុត្តិធម៌ អំពីការហាមឃាត់នេះ ដើម្បីស្វែងរកដំណោះស្រាយ។

[23] ដូចខាងលើ ទំព័រទី១៨ ។

[24] ដូចខាងលើ ។

## ការធ្វើកំណត់ត្រា

ការធ្វើកំណត់ត្រានូវអ្វីដែលបានកើតឡើងនៅក្នុងសវនាការ ជាការចាំបាច់ដាច់ខាត។ ការធ្វើកំណត់ត្រានេះមិនត្រឹមតែជាជំនួយដល់ការវិភាគពីសិទ្ធិជំនុំជម្រះ នៅពេលសរសេររបាយការណ៍ប៉ុណ្ណោះទេ ថែមទាំងបង្ហាញនូវការយកចិត្តទុកដាក់ និងការវិភាគយ៉ាងហ្មត់ចត់ទៅលើដំណើរការ និងអ្នកអនុវត្តនីតិវិធីច្បាប់។

តុលាការមិនគួរបដិសេធមិនឲ្យមន្ត្រីសង្កេតការណ៍សវនាការ ធ្វើកំណត់ត្រាឡើយ។ ប៉ុន្តែ ម.ស.ម.ក បានជួបប្រទះនូវករណីដែលសវនាការត្រូវបានផ្អាក ដោយសារតែការធ្វើកំណត់ត្រារបស់មន្ត្រីសង្កេតការណ៍សវនាការ។ មន្ត្រីសង្កេតការណ៍សវនាការត្រូវដឹងថាករណីនេះអាចកើតឡើង ហើយគួរតែកត់ត្រាដោយភ្ជាប់ជាមួយមូលហេតុ ហើយធ្វើការផ្តល់ដំណឹងដល់ស្ថាប័នសង្កេតការណ៍។

ចំណុចដែលត្រូវយកមកពិចារណាមួយទៀត គឺហានិភ័យនៅពេលអាជ្ញាធររឹបអូស ឬត្រួតពិនិត្យសៀវភៅកំណត់ត្រា។ មន្ត្រីសង្កេតការណ៍សវនាការ គួរតែព្រាងកំណត់ត្រាក្នុងរបៀបដែលអាចរក្សាបាននូវការសម្ងាត់នៃព័ត៌មាន។ កំណត់ត្រាព្រាងនេះ អាចបន្ថែមនៅពេលក្រោយទៀត ក្នុងបរិយាកាសសុវត្ថិភាពជាងនេះ ហើយខណៈដែលព័ត៌មានទាំងនោះស្ថិតនៅក្នុងការចងចាំនៅឡើយ ។

## ការមិនធ្វើអន្តរាគមន៍ក្នុងដំណើរការជំនុំជម្រះ

មន្ត្រីសង្កេតការណ៍សវនាការ ជាអ្នកតំណាងឲ្យភាពមិនលម្អៀង មានវត្តមាននៅក្នុងសវនាការ ដើម្បីសង្កេតពីដំណើរការតុលាការ។ ដូច្នេះគោលការណ៍ដែលជាប់ជាមួយនឹងមុខងាររបស់មន្ត្រីសង្កេតការណ៍សវនាការ គឺការមិនធ្វើអន្តរាគមន៍ និងគោរពឯករាជ្យភាពនៃដំណើរការតុលាការ។ មិនតែប៉ុណ្ណោះ មន្ត្រីសង្កេតការណ៍សវនាការមិនត្រូវមានបំណងបញ្ចុះបញ្ចូល ឬជ្រៀតជ្រែកក្នុងការជំនុំជម្រះ ឬនៅមុនពេលជំនុំជម្រះ នៅគ្រប់រូបភាពទាំងអស់។ ក្នុងន័យនេះ មន្ត្រីសង្កេតការណ៍សវនាការគួរតែ៖

- មិនរំខានដល់ដំណើរការនីតិវិធី
- មិនបញ្ចេញមតិជាសាធារណៈអំពីដំណើរការនីតិវិធី
- មិនផ្តល់អនុសាសន៍ដល់ភាគីណាមួយក្នុងសវនាការ
- មិនចូលរួមយ៉ាងសកម្មក្នុងកិច្ចពិភាក្សាជុំវិញការជំនុំជម្រះ
- គោរពអាជ្ញាធរ និងបុគ្គលិកតុលាការ
- មិនតវ៉ា ឬចូលរួមក្នុងការប្រឈមណាមួយ

គួរកត់សម្គាល់ថា ចំណុចបារម្ភណាមួយដែលកើតមានចំពោះមន្ត្រីសង្កេតការណ៍សវនាការ ពាក់ព័ន្ធនឹងការគោរពគោលការណ៍ ឬដំណើរការតុលាការ អាចត្រូវបានបង្ហាញនៅក្នុងរបាយការណ៍។ ដូច្នេះ មន្ត្រីសង្កេតការណ៍សវនាការ មិនចាំបាច់សម្តែងមតិជាសាធារណៈ នៅពេលដែលសវនាការកំពុងតែប្រព្រឹត្តទៅនោះទេ។

ទាក់ទងនឹងចំណុចទី ២ ខាងលើ ការបញ្ចេញមតិជាសាធារណៈ ស្ថាប័នសង្កេតការណ៍គួរតែពិចារណាយ៉ាងប្រុងប្រយ័ត្ន អំពីគោលបំណងនៃការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ និងសេចក្តីប្រកាសព័ត៌មាន។ ឧទាហរណ៍ ស្ថាប័នសង្កេតការណ៍នឹងត្រូវពិចារណា ថាតើសេចក្តីថ្លែងការណ៍របស់ខ្លួន នឹងអាចមានផលប៉ះពាល់ដល់ភាពមិនលម្អៀង និងភាពជោគជ័យនៃការសង្កេតសវនាការដែរឬទេ។ ទោះជាយ៉ាងណាក៏ដោយ ស្ថាប័នសង្កេតការណ៍មិនត្រូវញញើត មិនឲ្យអ្នកសារព័ត៌មានដឹងពីវត្តមានរបស់ខ្លួនឡើយ។ ស្ថាប័ននេះគួរតែមានការប្រុងប្រយ័ត្ននឹងអត្ថន័យនៃយោបល់របស់ខ្លួន។

## គ .ប្រព័ន្ធផ្ទុកទិន្នន័យ

ស្ថាប័នសង្កេតការណ៍ត្រូវពិចារណាផងដែរ ពីវិធីរក្សាទុកទិន្នន័យដែលខ្លួនប្រមូលបាន ដូចជាការរក្សាទុកក្នុងប្រព័ន្ធកុំព្យូទ័រ ឬជាឯកសារ។ ប្រសិនបើស្ថាប័នសង្កេតការណ៍ជ្រើសរើសការរក្សាទុកទិន្នន័យជាឯកសារ ចាំបាច់ត្រូវធានាថា ឯកសារទាំងនោះត្រូវបានរក្សាទុកយ៉ាងមានរបៀបរៀបរយ និងនៅកន្លែងមានសុវត្ថិភាព។ ស្ថាប័នសង្កេតការណ៍គួរតែប្រឹថតចម្លងទុក នូវឯកសារសំខាន់ៗទាំងអស់ ដើម្បីជៀសវាងការបាត់បង់ ឬខូចខាតឯកសារដើម។ ឯកសារថតចម្លងត្រូវរក្សាទុកនៅកន្លែងដាច់ដោយឡែកពីឯកសារដើម។

ការរក្សាទុកទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័រ អាចឲ្យស្ថាប័នសង្កេតការណ៍ អាចចែកចាយទិន្នន័យរបស់ខ្លួនទៅឲ្យសាធារណជន ក្នុងលក្ខណៈទូលំទូលាយ និងលឿនជាងការរក្សាទុកជាឯកសារ។ រាល់ទិន្នន័យដែលរក្សាទុកនៅក្នុងកុំព្យូទ័រ ត្រូវមានការថតទុក (ក្នុងករណីបាត់បង់ ខូចខាតទិន្នន័យដើម ហើយការថតទុកនេះត្រូវធ្វើជារៀងរាល់ថ្ងៃមុនពេលចេញពីធ្វើការ ដើម្បីធានាថាទិន្នន័យមានបច្ចុប្បន្នភាពគ្រប់ពេលវេលា)។ ការថតទុកច្រើនបែបនេះជាការអនុវត្តដ៏ល្អ ហើយយ៉ាងហោចណាស់ ទិន្នន័យមួយដែលបានថតចម្លងទុក ត្រូវរក្សាទុកដាច់ដោយឡែកពីទិន្នន័យដើម។

ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមបណ្តាញអ៊ិនធឺណេត ជាវិធីសាស្ត្រមួយទៀតនៃប្រព័ន្ធផ្ទុកទិន្នន័យក្នុងកុំព្យូទ័រ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមានសារៈសំខាន់ ដោយសារតែអាចដើរតួទាំងថតចម្លងទុក និងចែកចាយទិន្នន័យដល់សាធារណជន និងស្ថាប័នដទៃទៀត។ ការអនុញ្ញាតឲ្យសាធារណជនទទួលបានទិន្នន័យទាំងនេះ គឺភាគច្រើនអាស្រ័យទៅតាមគោលដៅរបស់ស្ថាប័នសង្កេតការណ៍។ ប៉ុន្តែទោះបីជាស្ថាប័នសង្កេតការណ៍មិនមានគោលដៅនេះក៏ដោយ ក៏ប្រព័ន្ធគ្រប់គ្រងទិន្នន័យគួរតែត្រូវបានប្រើ ដើម្បីធានាថា គុណភាពនៃទិន្នន័យត្រូវបានត្រួតពិនិត្យ ធានាបាននូវភាពស្របគ្នា រវាងទិន្នន័យដែលប្រមូលបាន និងទិន្នន័យដែលមាននៅក្នុងប្រព័ន្ធទិន្នន័យ។ ចំពោះការបោះពុម្ពផ្សាយទិន្នន័យ ស្ថាប័នសង្កេតការណ៍គួរតែគិតគូរពីគោលការណ៍រក្សាការសម្ងាត់នូវព័ត៌មានមួយចំនួន និងធានាថាមិនបោះពុម្ពផ្សាយព័ត៌មានសម្ងាត់។ ចំពោះបញ្ហានេះ ស្ថាប័នសង្កេតការណ៍ត្រូវមានការប្រុងប្រយ័ត្នខ្ពស់។

## ឃ. កិច្ចពិភាក្សា និងការតស៊ូមតិ

ផ្នែកសំខាន់នៃគម្រោងសង្កេតការណ៍សវនាការ គឺរបៀបប្រើប្រាស់ និង/ឬ ផ្សព្វផ្សាយទិន្នន័យដែលប្រមូលបាន។ ស្ថាប័នសង្កេតការណ៍នឹងត្រូវពិចារណា អំពីរបៀបបង្ហាញការរកឃើញរបស់

ខ្លួន។ ទម្រង់ប្រើសម្រាប់បង្ហាញការរកឃើញនេះ គួរតែជាការវិភាគពីទិន្នន័យ ឆ្លុះបញ្ចាំងទៅនឹងគោលដៅរបស់គម្រោងសង្កេតការណ៍ និងប្រសិនបើអាច គួរបញ្ចូលទាំងការបោះពុម្ពផ្សាយជាលក្ខណៈទម្រង់វែង និងទម្រង់ខ្លី ព្រមទាំងចូលរួមកិច្ចពិភាក្សាជាមួយដៃគូពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌ ដែលមានដូចជាតុលាការ និងក្រសួងយុត្តិធម៌ ។

ទម្រង់មួយដែលមានលក្ខណៈវែង ហើយមានប្រយោជន៍ ក្នុងការរៀបទិន្នន័យ ផ្សព្វផ្សាយព័ត៌មាន និងសម្រួលកិច្ចពិភាក្សាជាមួយដៃគូរពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌ គឺរបាយការណ៍ដែលបង្ហាញពីការរកឃើញសំខាន់ៗ និងផ្តល់ជាអនុសាសន៍ដោយស្ថាប័នសង្កេតការណ៍។ របាយការណ៍នោះត្រូវធានាថាលទ្ធផលដែលបង្ហាញ មានភាពច្បាស់លាស់ហើយស៊ីសង្វាក់គ្នា។

របាយការណ៍អាចជាឧបករណ៍យ៉ាងសំខាន់ ដែលជួយឲ្យស្ថាប័នសង្កេតការណ៍ អាចផ្តល់អនុសាសន៍។ ស្ថាប័នសង្កេតការណ៍គួរតែឆ្លៀតឱកាសក្នុងពេលបោះពុម្ពផ្សាយរបាយការណ៍ពិចារណាទៅលើគ្រប់បញ្ហាដែលរកឃើញនៅក្នុងពេលសង្កេតការណ៍សវនាការ។ ស្ថាប័នសង្កេតការណ៍គួរតែគិតថា របាយការណ៍នឹងផ្តល់លទ្ធភាពឲ្យភាគីខាងក្រៅវាយតម្លៃដំណើរការសង្កេតការណ៍សវនាការ ភាពមិនលំអៀង និងភាពឯករាជ្យ។ បញ្ហាទាំងនេះនឹងជះឥទ្ធិពលទៅលើសេចក្តីសន្និដ្ឋានរបស់ស្ថាប័នសង្កេតការណ៍ និងទៅលើវិសាលភាពដែលភាគីទីបីអាចអនុវត្តអនុសាសន៍ ព្រមទទួលយកអនុសាសន៍។ ដូច្នេះ ជាការសំខាន់ដែលគ្រប់ព័ត៌មានទាំងអស់ នៅក្នុងរបាយការណ៍មានលក្ខណៈសុក្រឹត ច្បាស់លាស់ ងាយស្រួលយល់ និងបង្ហាញពីភាពឯករាជ្យ អព្យាក្រឹតនៃស្ថាប័នសង្កេតការណ៍។

ការបោះពុម្ពផ្សាយតាមទម្រង់ខ្លី ដែលមានដូចជា ព្រឹត្តិបត្រព័ត៌មានប្រចាំខែ ខិត្តប័ណ្ណ ជាដើម គឺជាឧបករណ៍ដ៏វិសេសវិសាល សម្រាប់ផ្សព្វផ្សាយព័ត៌មាន។ ប្រសិនស្ថាប័នសង្កេតការណ៍ជ្រើសរើសការបោះពុម្ពផ្សាយតាមទម្រង់ខ្លី ចាំបាច់ត្រូវសម្រេចជ្រើសរើសដោយផ្តោតទៅលើប្រធានបទជាក់លាក់ណាមួយ ដូចជាសិទ្ធិណាមួយ ហើយវិភាគតែទិន្នន័យពាក់ព័ន្ធនឹងសិទ្ធិនោះ។ ការធ្វើរបៀបនេះ អត្ថបទដែលនឹងត្រូវបោះពុម្ពផ្សាយនឹងមានលក្ខណៈខ្លី ងាយស្រួលយល់ និងអាចទាក់ទាញអ្នកអានបានច្រើន។ យុទ្ធសាស្ត្របែបនេះក៏មានសារៈប្រយោជន៍ក្នុងការសង្កត់ធ្ងន់លើបញ្ហា ឬទិន្នន័យសំខាន់ៗ ដែលប្រមូលបានដោយស្ថាប័នសង្កេតការណ៍។

ទិន្នន័យដែលមានបរិមាណប្រមូលបាន តាមរយៈការសង្កេតការណ៍សវនាការ អាចត្រូវបានប្រើប្រាស់ តាមវិធីច្រើនយ៉ាង ដូចជា៖

- ប្រៀបធៀបតុលាការ
- សង្កេតពីបម្រែបម្រួល
- ប្រើសម្រាប់ជាភស្តុតាងក្នុងកិច្ចពិភាក្សា និងការតស៊ូមតិ

ទិន្នន័យដែលប្រមូលបានតាមរយៈសង្កេតការណ៍សវនាការ ប្រើប្រាស់ជាមូលដ្ឋាន នៅក្នុងកិច្ចពិភាក្សា និងការតស៊ូមតិ អាចយកមកប្រើប្រាស់តាមវិធីច្រើនយ៉ាង។ ឧទាហរណ៍ ដូចជាបទបង្ហាញទិន្នន័យទៅតុលាការ និងដៃគូពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌ដទៃទៀត (ឧទាហរណ៍ដូចជាក្រសួងយុត្តិធម៌) ក្នុងគោលបំណងលើកកម្ពស់កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ។ ការចូលរួមក្នុងកិច្ចពិភាក្សា ជាមួយដៃគូពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌ មានសារៈប្រយោជន៍ខ្ពស់ ក្នុងការនាំមកនូវ

ការកែទម្រង់នេះ ដោយសារតែកិច្ចពិភាក្សានេះអាចបង្កើតបាននូវទំនាក់ទំនងវិជ្ជមានជាមួយតុលាការថ្នាក់ក្រោម និងក្រសួងពាក់ព័ន្ធដទៃទៀត។ ទំនាក់ទំនងវិជ្ជមាននេះជាជំនួយយ៉ាងសំខាន់ ដល់ការបែងចែកយោបល់តបបែបស្ថាបនា ឲ្យដល់ភាគីពាក់ព័ន្ធ។ ការធ្វើរបៀបនេះ ក៏អាចនាំទៅរកបរិយាកាសដែលការផ្លាស់ប្តូរងាយនឹងកើតឡើង ដូច្នេះជាជំនួយដល់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

**ករណីសិក្សាទី៥ ៖ ការសរសេររបាយការណ៍ និងកិច្ចសន្ទនា ៖ តឹកតាងនៃវឌ្ឍនភាព**

គម្រោងសង្កេតការណ៍សវនាការនៃម.ស.ម.ក បានកត់សម្គាល់នូវភាពជោគជ័យ ដែលកើតចេញពីការខិតខំប្រឹងប្រែងឲ្យការគោរពបទដ្ឋានជំនុំជម្រះដោយយុត្តិធម៌មានលក្ខណៈកាន់តែប្រសើរឡើង។ ចាប់តាំងពីខែសីហា ឆ្នាំ២០០៩ ដល់ខែធ្នូ ឆ្នាំ២០១០ មន្ត្រីសង្កេតការណ៍សវនាការបានកត់សម្គាល់ឃើញការកើនឡើងនូវការបិទផ្សាយព័ត៌មានអំពីសវនាការលើក្តារខៀន នៅក្រៅបន្ទប់សវនាការនៃតុលាការដែលបានសង្កេត។ អត្រាមានការកើនឡើងពី ៣% ក្នុងឆ្នាំ២០០៩ ដល់៩០% នៅខែធ្នូ ឆ្នាំ២០១០។[25]

ដូចគ្នានេះដែរ មន្ត្រីសង្កេតការណ៍សវនាការនៃម.ស.ម.ក ក៏កត់សម្គាល់ឃើញនូវការធ្លាក់ចុះអត្រានៃការប្រើប្រាស់ទូរស័ព្ទដៃក្នុងបន្ទប់សវនាការ។ ពីខែសីហា ឆ្នាំ២០០៩ ដល់ខែធ្នូ ឆ្នាំ២០១០ អត្រាធ្លាក់ចុះពី ២៨% មកនៅត្រឹម ២២%។[26] ការរីកចម្រើនទាំងពីរនេះ កើតចេញមកពីអនុសាសន៍នៅក្នុងរបាយការណ៍របស់ម.ស.ម.ក ដែលបោះពុម្ពផ្សាយបន្ទាប់ពីមានកិច្ចពិភាក្សារវាងម.ស.ម.ក ជាមួយនឹងដៃគូពាក់ព័ន្ធ ជុំវិញទិន្នន័យដែលប្រមូលបាន។ ការរីកចម្រើនទាំងនេះ ជាភស្តុតាងបង្ហាញពីទំនាក់ទំនងរវាងការសង្កេតការណ៍សវនាការ និងការរីកចម្រើននៃការគោរពបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅឯតុលាការ៕

## ខ .ការវាយតម្លៃដំណើរការសង្កេតការណ៍សវនាការ

ប្រសិនបើស្ថាប័នសង្កេតការណ៍ សម្រេចបង្កើតគម្រោងសង្កេតការណ៍សវនាការ ស្ថាប័នសង្កេតការណ៍ត្រូវត្រួតពិនិត្យ និងវាយតម្លៃដំណើរការសង្កេតសវនាការរបស់ខ្លួន និងឯករាជ្យភាពជាក់ស្តែងរបស់មន្ត្រីសង្កេតការណ៍សវនាការ។ រាល់តារាងសង្កេតការណ៍សវនាការដែលបានបង្កើតអាចនឹងត្រូវកែសម្រួលឡើងវិញ ដើម្បីឆ្លុះបញ្ចាំងពីបញ្ហាដែលបានមើលឃើញដោយមន្ត្រីសង្កេតការណ៍សវនាការ ឬបញ្ហាដែលរកឃើញដោយការវាយតម្លៃលើគម្រោងសង្កេតការណ៍សវនាការ និងដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរក្នុងបញ្ញត្តិច្បាប់។ ប៉ុន្តែ ប្រសិនបើស្ថាប័នសង្កេតការណ៍ នឹងត្រូវធ្វើការប្រៀបធៀបគម្រោងសង្កេតការណ៍សវនាការផ្សេងៗទៀត នោះភាពស៊ីសង្វាក់គ្នានៃសំណួរដែលកត់ត្រាដោយមន្ត្រីសង្កេតការណ៍សវនាការ មានលក្ខណៈចាំបាច់សម្រាប់ការប្រៀបធៀបដ៏ត្រឹមត្រូវ។

[25] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា - ទំព័រទី២០ នៃ*របាយការណ៍ប្រចាំឆមាសទី៣ ៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌-វិវឌ្ឍន៍ក្នុងរយៈពេលមួយឆ្នាំ* មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ខែមករា ឆ្នាំ២០១២។
[26] ដូចខាងលើ ទំព័រទី៣១។

# សេចក្តីសន្និដ្ឋាន

សវនាការយុត្តិធម៌ គឺជាទិដ្ឋភាពមួយដ៏សំខាន់ដែលសង្គមត្រូវការ ដើម្បីឆ្លុះបញ្ចាំងពីភាពយុត្តិធម៌ និងសមភាពសម្រាប់ជនគ្រប់រូប។ សវនាការយុត្តិធម៌មួយអាចកើតឡើងបាន លុះត្រាតែច្បាប់ទទួលយកគោលការណ៍ និងសិទ្ធិដែលត្រូវបានទទួលស្គាល់ដោយអន្តរជាតិ។ ច្បាប់ទាំងនោះមិនត្រឹមតែឯករាជ្យ និងមិនលម្អៀងប៉ុណ្ណោះទេ ថែមទាំងត្រូវឲ្យគេមើលឃើញថាពិតជាឯករាជ្យ និងមិនលម្អៀងមែន ។

ការសង្កេតការណ៍សវនាការ ជាឧបករណ៍ដ៏សំខាន់ដែលជួយធានាឯករាជ្យភាព ភាពមិនលម្អៀង និងតុលាការប្រកបដោយវិជ្ជាជីវៈ ដែលគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងបទដ្ឋានដែលទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ។ ម.ស.ម.ក បានតាក់តែងសៀវភៅនេះឡើងទុកជាមគ្គុទ្ទេសក៍ដល់មេធាវី អ្នកការពារសិទ្ធិមនុស្ស និងស្ថាប័នសង្កេតការណ៍ ដែលមានបំណងចង់បង្កើតគម្រោងសង្កេតការណ៍សវនាការដោយខ្លួនឯង។ យុទ្ធសាស្ត្ររបស់គម្រោងទាំងនោះអាចខុសគ្នាពីមួយទៅមួយ ដូច្នេះផ្នែកខ្លះនៃសៀវភៅនេះ នឹងពុំអាចយកមកអនុវត្តបានទេ ប៉ុន្តែស្ថាប័នសង្កេតការណ៍នានាអាចប្រើប្រាស់តារាងសង្កេតការណ៍សវនាការ និងក្រមសីលធម៌ ដែលភ្ជាប់ក្នុងសៀវភៅមគ្គុទ្ទេសក៍នេះ។ ម.ស.ម.ក រីករាយនឹងផ្តល់ជូននូវជំនួយបន្ថែមដល់ស្ថាប័នទាំងឡាយ ដែលមានបំណងចង់បង្កើតគម្រោងសង្កេតការណ៍សវនាការដោយខ្លួនឯង ឬកំពុងនឹងអនុវត្តគម្រោងនេះ។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

**កញ្ញា ម៉ាង ម៉ូនីកា**
ទូរស័ព្ទលេខ ៖ +៨៥៥-១៦-៩២៧-២៧៩
អ៊ីម៉ែល ៖ monika.mang@cchrcambodia.org

ឬ **កញ្ញា សាណា ហ្គោស**
ទូរស័ព្ទលេខ ៖ +៨៥៥-៨៩-៦១៩-៣៣៤
អ៊ីម៉ែល៖ sana.ghouse@cchrcambodia.org

# គន្ថនិទ្ទេស

## ច្បាប់ជាតិ

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (២០០៧)។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(១៩៩៣ ដូចដែលបានធ្វើវិសោធនកម្ម)។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (២០០៩)។

បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល (អ៊ុនតាក់) (UNTAC) (១៩៩២)។

## ច្បាប់អន្តរជាតិ

មហាសន្និបាតអង្គការសហប្រជាជាតិ - *អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប* ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៨៤។

មហាសន្និបាតអង្គការសហប្រជាជាតិ - *អនុសញ្ញាស្តីពីសិទ្ធិកុមារ* ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ១៩៨៩។

មហាសន្និបាតអង្គការសហប្រជាជាតិ - *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។

មហាសន្និបាតអង្គការសហប្រជាជាតិ - *សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស* ចុះថ្ងៃទី១០ខែធ្នូ ឆ្នាំ១៩៤៨ ។

មហាសន្និបាតអង្គការសហប្រជាជាតិ - *ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងនឹងទារុណកម្ម* (OPCAT) អនុគណៈកម្មាធិការបង្ការទារុណកម្ម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២។

## ករណីសិក្សាជាតិ

ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា - សេចក្តីសម្រេចលេខ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

## ករណីសិក្សាអន្តរជាតិ

គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ - *ទស្សនៈនៃគណៈកម្មាធិកាសិទ្ធិមនុស្ស លើមាត្រា ៥ កថាខណ្ឌ ៤ នៃពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្តីជូនដំណឹងលេខ ១០៨៥/២០០២៖ អាប់ដេលីហាមេដ ថារ៉ាយ អាមេដថ ទូអាឌី មហាមេដ រីមលី និងអាម៉ា យូហ្វី តទល់នឹង អាល្ហេរី។* សេចក្តីសម្រេចចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ (ICCPR/C/86/ D/1085/2002) អាចរកបាននៅលើ

គេហទំព័រ៖ http://www.unhchr.ch/tbs/ doc.nsf/0/95ee 23f6e010a 5efc1257199004c8995?Opendocument ។

គណៈកម្មាធិការសិទ្ធិមនុស្ស *ទស្សនៈនៃគណៈកម្មាធិកាសិទ្ធិមនុស្សលើមាត្រា ៥ កថាខណ្ឌ ៤ នៃពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្តីជូនដំណឹងលេខ ៣៧៧/១៩៨៩៖ យើរី តទល់នឹង ចាម៉ៃកា។* សេចក្តីសម្រេចចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៤ (ICCPR/C/50/D/377/1989) អាចរកបាននៅលើគេហទំព័រ៖ http://www1.umn. edu/ humanrts/undocs/html/Vws377.htm ។

## គោលការណ៍ និងបទអត្ថាធិប្បាយទូទៅរបស់អង្គការសហប្រជាជាតិ

គណៈកម្មាធិការសិទ្ធិមនុស្ស - *គោលការណ៍ស៊ីរ៉ាគូសាស្តីពីការដាក់កម្រិត និងបដិប្បញ្ញត្តិនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៨៤ លេខ E/CN.៤/១៩៨៥/៤ អាចរកបាននៅលើគេហទំព័រ៖ http://www.unhcr.org/refworld/docid/4672bc122.html។

គណៈកម្មាធិការសិទ្ធិកុមារ - *បទអត្ថាធិប្បាយទូទៅលេខ ១០៖ សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន* (CRC/C/GC/10) ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧។

គណៈកម្មាធិការសិទ្ធិមនុស្ស - *បទអត្ថាធិប្បាយទូទៅលេខ ៣២៖ មាត្រា១៤៖ សិទ្ធិសមភាពចំពោះមុខតុលាការ និងសាលាជម្រះក្តី និងការជំនុំជម្រះដោយយុត្តិធម៌* (CCPR/C/GC/32) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧។

## សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌

គណៈកម្មការអ្នកច្បាប់អន្តរជាតិ - សៀវភៅណែនាំអំពី*ការសង្កេតនីតិវិធីព្រហ្មទណ្ឌ៖ សេចក្តីណែនាំលេខ៥* គណៈកម្មការអ្នកច្បាប់អន្តរជាតិ ឆ្នាំ២០០៩។

## របាយការណ៍

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា - របាយការណ៍ប្រចាំឆមាសទី៣៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ - វិវឌ្ឍន៍ក្នុងរយៈពេលមួយឆ្នាំ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ខែមករា ឆ្នាំ២០១២ ទំព័រទី ២០។

## ផ្សេងៗ

មាត្រា១៩ គោលការណ៍ជូហាន់នេសប៊ើក ស្តីពីសន្តិសុខជាតិ សេរីភាពបញ្ចេញមតិ ការទទួលបានព័ត៌មាន ខែវិច្ឆិកា ឆ្នាំ១៩៩៦ អាចរកបាននៅលើគេហទំព័រ៖ http://www.article19.org/data/files/pdfs/standards/joburgprinciples.pdf ។

## ឧបសម្ព័ន្ធទី១ ៖ តារាងសង្កេតការណ៍សវនាការ

### ក. ព័ត៌មានទូទៅអំពីសវនាការ

| ១. ព័ត៌មានទូទៅ | | | | |
|---|---|---|---|---|
| ១(ក)កាលបរិច្ឆេទសវនាការ | ម៉ោងចាប់ផ្តើម៖ | | | |
| ១(ខ) មន្ត្រីសង្កេតការណ៍សវនាការ | | | | |
| ១(គ) តុលាការ | ☐ ភ្នំពេញ ☐ កណ្តាល ☐ បន្ទាយមានជ័យ ☐ រតនគិរី ☐ ផ្សេងៗ សូមបញ្ជាក់៖ ______ | | | |
| ១(ឃ) ចៅក្រម | ទី១<br>ទី២<br>ទី៣<br>☐ ផ្សេងៗ សូមបញ្ជាក់៖ | | | |
| ១(ង) ក្រឡាបញ្ជី | | | | |
| ១(ច) ចំនួនជនជាប់ចោទ | ចំនួនសរុប៖ | | | |
| | នីតិជន៖ | ប្រុស៖ | វត្តមាន៖ | អវត្តមាន៖ |
| | | ស្រី៖ | វត្តមាន៖ | អវត្តមាន៖ |
| | អនីតិជន៖ | ប្រុស៖ | វត្តមាន៖ | អវត្តមាន៖ |
| | | ស្រី៖ | វត្តមាន៖ | អវត្តមាន៖ |
| | តំណាងនីតិបុគ្គល៖ | ប្រុស៖ | វត្តមាន៖ | អវត្តមាន៖ |
| | | ស្រី៖ | វត្តមាន៖ | អវត្តមាន៖ |
| ១(ឆ) ចំនួនជនរងគ្រោះ៖ | ចំនួនសរុប៖ | | | |
| | នីតិជន៖ | ប្រុស៖ | វត្តមាន៖ | អវត្តមាន៖ |
| | | ស្រី៖ | វត្តមាន៖ | អវត្តមាន៖ |
| | អនីតិជន៖ | ប្រុស៖ | វត្តមាន៖ | អវត្តមាន៖ |
| | | ស្រី៖ | វត្តមាន៖ | អវត្តមាន៖ |

| | | | | |
|---|---|---|---|---|
| | តំណាងនីតិបុគ្គល៖ | ប្រុស៖ | វត្តមាន៖ | អវត្តមាន៖ |
| | | ស្រី៖ | វត្តមាន៖ | អវត្តមាន៖ |

## សិទ្ធិក្នុងពេលជំនុំជម្រះ

| ២. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ | | |
|---|---|---|
| ២(ក) តើមានការបិទផ្សាយជូនដំណឹងអំពីសវនាការនៅលើក្ដារខៀនក្រៅបន្ទប់សវនាការដែរឬទេ? | ☐ មាន | ☐ គ្មាន |
| ២(ខ) តើសាធារណៈជនត្រូវបានរាំងមិនឲ្យចូល ឬបណ្ដេញចេញពីបន្ទប់សវនាការដែរឬទេ? | ☐ មាន<br>ប្រសិនបើមាន មូលហេតុ៖ | ☐ គ្មាន |

| ៣. សិទ្ធិទទួលបានព័ត៌មានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ | | | |
|---|---|---|---|
| ៣(ក) តើចៅក្រមបានប្រកាសបទចោទដែរឬទេ? | ☐ មាន | ☐ គ្មាន | |
| ៣(ខ) តើចៅក្រមបានប្រកាសពីច្បាប់ពាក់ព័ន្ធដែរឬទេ? | ☐ មាន | ☐ គ្មាន | |
| ៣(គ) តើចៅក្រមបានប្រកាសពីកាលបរិច្ឆេទប្រព្រឹត្តបទល្មើសដែរឬទេ? | ☐ មាន | ☐ គ្មាន | |
| ៣(ឃ) តើចៅក្រមបានប្រកាសពីទីកន្លែងប្រព្រឹត្តបទល្មើសដែរឬទេ? | ☐ មាន | ☐ គ្មាន | |
| ៣(ង) តើចៅក្រមបានប្រកាសអំពីភាគីពាក់ព័ន្ធដែរឬទេ? | ☐ មាន | ☐ គ្មាន | |
| ៣(ច) ប្រសិនបើត្រូវការ តើអ្នកបកប្រែត្រូវបានផ្ដល់ឲ្យដែរឬទេ? | ☐ មាន | ☐ គ្មាន | ☐ មិនពាក់ព័ន្ធ |
| ៣(ឆ) ប្រសិនបើត្រូវការ តើជនពិការត្រូវបានគេផ្ដល់ជំនួយដែរឬទេ? | ☐ មាន | ☐ គ្មាន | ☐ មិនពាក់ព័ន្ធ |

| | |
|---|---|
| ប្រសិនបើមាន តើជាជំនួយអ្វី? | ☐ ស្តាប់ ☐ មើល ☐ ផ្សេងៗ<br>សូមបញ្ជាក់៖ |

| ៤. ការពន្យល់ប្រាប់សិទ្ធិ | ☐ មិនពាក់ព័ន្ធ | | |
|---|---|---|---|
| ៤(ក) តើចៅក្រមបានប្រាប់ និងពន្យល់ ជនជាប់ចោទពីសិទ្ធិទទួលបានជំនួយពីមេធាវី ឬសិទ្ធិស្វ័យការពារ ដែរឬទេ? | ☐ ប្រាប់ | ☐ ប្រាប់ និង ពន្យល់ | ☐ គ្មានទាំងប្រាប់ និង គ្មានទាំងពន្យល់ |
| ៤(ខ) តើចៅក្រមបានប្រាប់ និងពន្យល់ ជនជាប់ចោទពីសិទ្ធិឆ្លើយ ឬមិនឆ្លើយ ដែរឬទេ? | ☐ ប្រាប់ | ☐ ប្រាប់ និង ពន្យល់ | ☐ គ្មានទាំងប្រាប់ និង គ្មានទាំងពន្យល់ |

| ៥. សិទ្ធិហៅ និងសាកសួរសាក្សី | | | |
|---|---|---|---|
| ៥(ក) តើមានអ្វីមួយ ដែលបង្ហាញថា ភាគីណាមួយមិនទទួលបានឱកាសហៅសាក្សី ដែរឬទេ? | ☐ មាន<br>ប្រសិនបើមាន តើភាគីណាមួយ?<br>☐ ព្រះរាជអាជ្ញា<br>មូលហេតុ៖ | ☐ គ្មាន<br><br>☐ ភាគីជនជាប់ចោទ | <br><br>☐ ភាគីរដ្ឋប្បវេណី |
| ៥ (ខ) តើសាក្សីស្ថិតនៅក្នុងបន្ទប់សវនាការនៅមុនពេលសាកសួរ ដែរឬទេ? | ☐ មាន | ☐ គ្មាន | ☐ មិនពាក់ព័ន្ធ |

| សូមរៀបរាប់អំពីអង្គហេតុឲ្យបានក្បោះក្បាយ |
|---|
| |

<table>
<tr><th colspan="8">៦. ការបង្ហាញភស្តុតាង</th></tr>
<tr><td rowspan="8">៦(ក) តើភស្តុតាង / សាក្សី ត្រូវបានបង្ហាញ ដែរឬទេ?</td><td colspan="7">☐ មាន ☐ គ្មាន<br>ប្រសិនបើមានតើភាគីណាមួយ? និង ភស្តុតាងប្រភេទណាមួយដែលត្រូវបានបង្ហាញ?</td></tr>
<tr><td>ភាគី/ប្រភេទ</td><td colspan="2">ព្រះរាជអាជ្ញា</td><td colspan="2">ភាគីជនជាប់ចោទ</td><td colspan="2">ភាគីរដ្ឋប្បវេណី</td></tr>
<tr><td>សាក្សី៖</td><td>វត្តមាន</td><td>អវត្តមាន</td><td>វត្តមាន</td><td>អវត្តមាន</td><td>វត្តមាន</td><td>អវត្តមាន</td></tr>
<tr><td>វត្ថុតាង</td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>ឯកសារ</td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>ចម្លើយសារភាព</td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td colspan="7">បញ្ជាក់បន្ថែម៖</td></tr>
<tr><td colspan="7"></td></tr>
<tr><td rowspan="2">៦(ខ) តើចៅក្រមបានច្រានចោលភស្តុតាងណាមួយដែលត្រូវបានបង្ហាញ ដែរឬទេ?</td><td colspan="7">☐ មាន ☐ គ្មាន ☐ មិនពាក់ព័ន្ធ</td></tr>
<tr><td colspan="7">ប្រសិនបើមាន សូមបញ្ជាក់បន្ថែម៖</td></tr>
</table>

<table>
<tr><th colspan="2">៧. សិទ្ធិទទួលដឹងឮភស្តុតាង/សិទ្ធិស្មើភាពគ្នា</th></tr>
<tr><td>៧(ក) តើមានអ្វីមួយដែលបង្ហាញថាភាគីណាមួយមិនទទួលបានឱកាសបង្ហាញភស្តុតាង?</td><td>☐ មាន ☐ គ្មាន<br>ប្រសិនបើមាន តើភាគីណាមួយ?<br>☐ ព្រះរាជអាជ្ញា ☐ ភាគីជនជាប់ចោទ ☐ ភាគីរដ្ឋប្បវេណី<br>មូលហេតុ៖</td></tr>
<tr><td>៧(ខ) តើមានអ្វីមួយដែលបង្ហាញថាភាគីណាមួយមិនទទួលបានឱកាសសាកសួរសាក្សី ដែរឬទេ?</td><td>☐ មាន ☐ គ្មាន ☐ មិនពាក់ព័ន្ធ<br>ប្រសិនបើមាន តើភាគីណាមួយ?<br>☐ ព្រះរាជអាជ្ញា ☐ ភាគីជនជាប់ចោទ ☐ ភាគីរដ្ឋប្បវេណី<br>មូលហេតុ៖</td></tr>
<tr><td>៧(គ) តើមានអ្វីមួយដែលបង្ហាញថាភាគីណាមួយមិនបានទទួលឱកាសមើលសំណុំរឿងមុនពេលសវនាការ ដែរឬទេ?</td><td>☐ មាន ☐ គ្មាន ☐ មិនពាក់ព័ន្ធ<br>ប្រសិនបើមាន តើភាគីណាមួយមិនបានទទួលសំណុំរឿងនៅមុនពេលសវនាការ?<br>☐ ព្រះរាជអាជ្ញា ☐ ជនជាប់ចោទ ☐ ភាគីជនជាប់ចោទ ☐ ភាគីរដ្ឋប្បវេណី</td></tr>
</table>

| | |
|---|---|
| | (ប្រសិនបើគ្មាន មេធាវី)<br>មូលហេតុ (សូមពន្យល់លំអិតអំពីមូលហេតុដែលបង្ហាញថាភាគីពាក់ព័ន្ធមិនបានទទួលសំណុំរឿង)៖ |
| ៧(ឃ) តើជនជាប់ចោទ ឬ ភាគីជនជាប់ចោទមិនទទួលបានឱកាសនិយាយសំដីចុងក្រោយ ដែរឬទេ? | ☐ មាន ☐ គ្មាន ☐ មិនពាក់ព័ន្ធ<br>☐ ជនជាប់ចោទ ☐ ភាគីជនជាប់ចោទ<br>ប្រសិនបើគ្មាន សូមបញ្ជាក់មូលហេតុ៖ |

| ៨. ភាពឯករាជ្យ ភាពមិនលំអៀង និងទង្វើរបស់ចៅក្រម | |
|---|---|
| ៨(ក) តើមានអ្វីមួយ ដែលបង្ហាញថា ចៅក្រមមានផលប្រយោជន៍នៅក្នុងរឿងក្តី ដោយសារតួនាទីនៅក្នុង វិស័យតុលាការ ដែរឬទេ? | ☐ មាន ☐ គ្មាន<br>ប្រសិនបើមាន តើជាផលប្រយោជន៍អ្វី?<br>☐ គ្រួសារ ☐ នយោបាយ ☐ ហិរញ្ញវត្ថុ ☐ ផ្សេងៗ<br>តើមានអ្វីដែលបង្ហាញថាផលប្រយោជន៍នេះកើតឡើង?<br>សូមពន្យល់៖ |
| ៨(ខ) តើចៅក្រមប្រព្រឹត្តទង្វើដែលធ្វើទុក្ខបុកម្នេញដល់ភាគីដែរឬទេ? | ☐ មាន ☐ គ្មាន<br>ប្រសិនបើមាន សូមពន្យល់៖ |
| ៨(គ) តើចៅក្រមបាននិយាយដោយមានលក្ខណៈរើសអើងភាគីណាមួយដែរឬទេ? | ☐ មាន ☐ គ្មាន<br>ប្រសិនបើមាន ជាការរើសអើងទៅលើ៖<br>☐ ពូជសាសន៍ ☐ យេនឌ័រ ☐ សាសនា ☐ ផ្សេងៗ<br>សូមបញ្ជាក់អំពីសំដីនោះ៖ |
| ៨(ឃ) តើចៅក្រមចាកចេញពីបន្ទប់សវនាការនៅក្នុងពេលជំនុំជម្រះ ដែរឬទេ? | ☐ មាន ☐ គ្មាន<br>ប្រសិនបើមាន សូមបញ្ជាក់ពីមូលហេតុ៖ ☐ មិនដឹង |
| ៨(ង) តើចៅក្រមនិយាយទូរស័ព្ទនៅក្នុងពេលជំនុំជម្រះដែរឬទេ? | ☐ មាន ☐ គ្មាន<br>ប្រសិនបើមាន តើចៅក្រម៖<br>☐ ឆ្លើយយ៉ាងខ្លី ហើយដាក់ចុះ ☐ បន្តការសន្ទនា<br>ប្រសិនបើមាន តើជា៖<br>☐ សម្លេងរោទិ៍ខ្លាំង ☐ សម្លេងញ័រ |

| ៩. ការពិភាក្សាសម្រេចរបស់តុលាការ | | | | |
|---|---|---|---|---|
| ម៉ោងបញ្ចប់៖ | | | | |
| ៩(ក) តើមានការពិភាក្សាសម្រេច ដែរឬទេ? | ☐ មាន | ☐ គ្មាន | ☐ ថ្ងៃបន្ទាប់ | ☐ មិនដឹង |
| | ប្រសិនបើមាន តើរយៈពេលប៉ុន្មាន? | | | |
| | ប្រសិនបើគ្មាន បញ្ជាក់ពីមូលហេតុ៖ | | | |
| ៩(ខ) តើមានអ្វីមួយដែលបង្ហាញថាភាគីណាមួយនិយាយទៅកាន់ចៅក្រមនៅក្នុងអំឡុងពេលពិភាក្សាសម្រេចរបស់តុលាការ? | ☐ មាន | ☐ គ្មាន | ☐ មិនពាក់ព័ន្ធ | ☐ មិនដឹង |
| | ប្រសិនបើមាន តើភាគីណាមួយ? | | | |
| | ☐ ព្រះរាជអាជ្ញា | ☐ ភាគីជនជាប់ចោទ | ☐ ភាគីរដ្ឋប្បវេណី | ☐ បុគ្គលិកតុលាការ |

| ១០. សាលក្រម | | | | | | |
|---|---|---|---|---|---|---|
| ១០(ក) តើសាលក្រមត្រូវបានប្រកាសនៅថ្ងៃសវនាការដែរឬទេ? | ☐ មាន | ☐ គ្មាន | | | | |
| | ប្រសិនបើគ្មាន តើកាលបរិច្ឆេទប្រកាសសាលក្រមត្រូវបានប្រកាសនៅក្នុងថ្ងៃសវនាការដែរឬទេ? | | | | | |
| | ☐ មាន | ☐ គ្មាន | | | | |
| ១០(ខ) ថ្ងៃប្រកាសសាលក្រម | | | | | | |
| ១០(គ) នៅពេលប្រកាសសាលក្រម តើចៅក្រមមានវត្តមានប៉ុន្មាននាក់? | ☐ ១ | ☐ ២ | ☐ ៣ | ☐ ៥ | ☐ ៩ | ☐ មិនដឹង |
| ១០(ឃ) តើសាលក្រម ត្រូវបានប្រកាសជាសាធារណៈដែរឬទេ? | ☐ មាន | ☐ គ្មាន | ☐ មិនដឹង | | | |
| | ប្រសិនបើគ្មាន សូមបញ្ជាក់ពីមូលហេតុ៖ | | | | | |
| ១០(ង) តើចៅក្រមបានប្រាប់ និងពន្យល់ នីតិវិធី និងរយៈពេលប្ដឹងឧទ្ធរណ៍ដែរឬទេ? | ☐ ប្រាប់ | ☐ ប្រាប់ និងពន្យល់ | ☐ គ្មានទាំងប្រាប់ និងគ្មានទាំងពន្យល់ | ☐ មិនពាក់ព័ន្ធ | ☐ មិនដឹង | |

| **រយៈពេលសវនាការសរុប៖** |
|---|

| កំណត់ត្រាពិសេស |
|---|
| |

## ខ. ព័ត៌មានអំពីជនជាប់ចោទនីមួយៗ

| ១១. ការទទួលខុសត្រូវព្រហ្មទណ្ឌ | | | | | |
|---|---|---|---|---|---|
| ជនជាប់ចោទ | ទី១ | ទី២ | ទី៣ | ទី៤ | ទី៥ |
| ១១(ក) នៅពេលប្រព្រឹត្តបទល្មើស តើជនជាប់ចោទជាអនីតិជនដែរឬទេ? (សូមបំពេញឯកសារភ្ជាប់ទី១ សម្រាប់ជនជាប់ចោទអនីតិជន) | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

| ១២. មូលដ្ឋានច្បាប់នៃបទចោទប្រកាន់ | | | | | |
|---|---|---|---|---|---|
| ១២(ក) នីតិវិធីព្រហ្មទណ្ឌប្រព្រឹត្តទៅដោយ | ☐ ការស៊ើបសួរ<br>☐ ជំនុំជម្រះផ្ទាល់<br>☐ បង្ហាញខ្លួនភ្លាម<br>☐ មិនដឹង | ☐ ការស៊ើបសួរ<br>☐ ជំនុំជម្រះផ្ទាល់<br>☐ បង្ហាញខ្លួនភ្លាម<br>☐ មិនដឹង | ☐ ការស៊ើបសួរ<br>☐ ជំនុំជម្រះផ្ទាល់<br>☐ បង្ហាញខ្លួនភ្លាម<br>☐ មិនដឹង | ☐ ការស៊ើបសួរ<br>☐ ជំនុំជម្រះផ្ទាល់<br>☐ បង្ហាញខ្លួនភ្លាម<br>☐ មិនដឹង | ☐ ការស៊ើបសួរ<br>☐ ជំនុំជម្រះផ្ទាល់<br>☐ បង្ហាញខ្លួនភ្លាម<br>☐ មិនដឹង |
| ១២(ខ) បទចោទប្រឆាំងជនជាប់ចោទ | ☐ ឧក្រិដ្ឋ<br>☐ មជ្ឈឹម<br>☐ លហុ | ☐ ឧក្រិដ្ឋ<br>☐ មជ្ឈឹម<br>☐ លហុ | ☐ ឧក្រិដ្ឋ<br>☐ មជ្ឈឹម<br>☐ លហុ | ☐ ឧក្រិដ្ឋ<br>☐ មជ្ឈឹម<br>☐ លហុ | ☐ ឧក្រិដ្ឋ<br>☐ មជ្ឈឹម<br>☐ លហុ |
| បទល្មើស៖[27]<br>ច្បាប់ពាក់ព័ន្ធ៖ | | | | | |

[27] ប្រសិនបើជាករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ សូមបំពេញឯកសារភ្ជាប់ទី២៖ សវនាការករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។

| មាត្រាច្បាប់ពាក់ព័ន្ធ៖ | |
|---|---|

## សិទ្ធិមុនពេលជំនុំជម្រះ

| ១៣. សិទ្ធិមានសេរីភាព និងទទួលបានការជំនុំជម្រះដោយគ្មានពន្យារពេល | | | | | |
|---|---|---|---|---|---|
| **ជនជាប់ចោទ** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ១៣(ក) កាលបរិច្ឆេទប្រព្រឹត្តបទល្មើស | ______ ☐ មិនដឹង | ______ ☐ មិនដឹង | ______ ☐ មិនដឹង | ______ ☐ មិនដឹង | ______ ☐ មិនដឹង |
| ១៣(ខ) កាលបរិច្ឆេទនៃការចាប់ខ្លួន | ______ ☐ មិនដឹង ☐ មិនពាក់ព័ន្ធ | ______ ☐ មិនដឹង ☐ មិនពាក់ព័ន្ធ | ______ ☐ មិនដឹង ☐ មិនពាក់ព័ន្ធ | ______ ☐ មិនដឹង ☐ មិនពាក់ព័ន្ធ | ______ ☐ មិនដឹង ☐ មិនពាក់ព័ន្ធ |
| ១៣(គ) តើមានការត្រួតពិនិត្យតាមផ្លូវតុលាការដែរឬទេ? | ☐ មាន ☐ គ្មាន ☐ មិនដឹង | ☐ មាន ☐ គ្មាន ☐ មិនដឹង | ☐ មាន ☐ គ្មាន ☐ មិនដឹង | ☐ មាន ☐ គ្មាន ☐ មិនដឹង | ☐ មាន ☐ គ្មាន ☐ មិនដឹង |
| ១៣(ឃ) តើមានការឃុំខ្លួនបណ្តោះអាសន្ន ដែរឬទេ? ប្រសិនបើមាន កាលបរិច្ឆេទដែលការឃុំខ្លួនបណ្តោះ អាសន្នចាប់ផ្តើម | ☐ មាន ☐ គ្មាន ☐ មិនដឹង ______ ☐ មិនដឹង | ☐ មាន ☐ គ្មាន ☐ មិនដឹង ______ ☐ មិនដឹង | ☐ មាន ☐ គ្មាន ☐ មិនដឹង ______ ☐ មិនដឹង | ☐ មាន ☐ គ្មាន ☐ មិនដឹង ______ ☐ មិនដឹង | ☐ មាន ☐ គ្មាន ☐ មិនដឹង ______ ☐ មិនដឹង |
| កាលបរិច្ឆេទដែលការឃុំខ្លួន បណ្តោះអាសន្នបញ្ចប់ | ______ ☐ មិនដឹង | ______ ☐ មិនដឹង | ______ ☐ មិនដឹង | ______ ☐ មិនដឹង | ______ ☐ មិនដឹង |

| ១៤. សិទ្ធិនៅក្នុងអំឡុងពេលសួរចម្លើយ និងការហាមឃាត់ការធ្វើទារុណកម្ម | | | | | |
|---|---|---|---|---|---|
| **ជនជាប់ចោទ** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ១៤(ក) តើមានអ្វីមួយដែលបង្ហាញថាជនជាប់ចោទសារភាពប្រព្រឹត្តបទល្មើសនៅមុនពេលសវនាការ ដែរឬទេ? ប្រសិនបើមានសូមបញ្ជាក់៖ | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន |
| ១៤(ខ) តើមានអ្វីមួយដែលបង្ហាញថាជនជាប់ចោទត្រូវបានសួរចម្លើយដោយគ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន |

| | | | | | |
|---|---|---|---|---|---|
| វត្តមានមេធាវី ដែរឬទេ? ប្រសិនបើមានសូមបញ្ជាក់៖ | | | | | |
| ១៤(គ) តើមានអ្វីមួយដែលបង្ហាញថាជនជាប់ចោទត្រូវបានគំរាមកំហែងឲ្យសារភាព ដែរឬទេ? ប្រសិនបើមានសូមបញ្ជាក់៖ | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន |
| ១៤(ឃ) តើមានអ្វីមួយដែលបង្ហាញថាជនជាប់ចោទទទួលរងអំពើហិង្សា ឬទារុណកម្មបង្ខំឲ្យសារភាព ដែរឬទេ? ប្រសិនបើមានសូមបញ្ជាក់៖ | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន |

| ១៥. សិទ្ធិមុនពេលជំនុំជម្រះ៖ និយាយជាមួយមេធាវី និងសិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ការពារក្ដី | | | | | |
|---|---|---|---|---|---|
| **ជនជាប់ចោទ** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ១៥(ក) តើមានអ្វីមួយដែលបង្ហាញថាមេធាវីជនជាប់ចោទត្រូវបានចាត់តាំងនៅក្នុងថ្ងៃសវនាការ ដែរឬទេ? ប្រសិនបើមានសូមបញ្ជាក់៖ | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន |
| ១៥(ខ) តើបញ្ហាមធ្យោបាយ និងពេលវេលាមិនគ្រប់គ្រាន់ក្នុងការរៀបចំការការពារក្ដីត្រូវបានលើកឡើងដោយភាគីជនជាប់ចោទដែរឬទេ? ប្រសិនបើមានសូមបញ្ជាក់៖ | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន |

## សិទ្ធិក្នុងពេលជំនុំជម្រះ

| ១៦. សិទ្ធិមានវត្តមាននៅក្នុងសវនាការ និងទទួលបានជំនួយពីមេធាវី | | | | | |
|---|---|---|---|---|---|
| **ជនជាប់ចោទ** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ១៦(ក) តើជនជាប់ចោទមានវត្តមាននៅក្នុងសវនាការ ដែរឬទេ? | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន | ☐ មាន ☐ គ្មាន |
| ១៦(ខ) តើជនជាប់ចោទ | ☐ មាន | ☐ មាន | ☐ មាន | ☐ មាន | ☐ មាន |

| | | | | | |
|---|---|---|---|---|---|
| ទទួលបានជំនួយពីមេធាវីនៅក្នុងសវនាការដែរឬទេ? | ☐ គ្មាន | ☐ គ្មាន | ☐ គ្មាន | ☐ គ្មាន | ☐ គ្មាន |
| ១៦(គ) ប្រសិនបើជនជាប់ចោទជាស្ត្រី តើជនជាប់ចោទទទួលបានជំនួយពីមេធាវីជាស្ត្រី ដែរឬទេ? | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ |
| ១៦(ឃ) តើមេធាវីការពារក្តីឲ្យជនជាប់ចោទលើសពីម្នាក់ដែរឬទេ? | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |
| ប្រសិនបើមាន តើមានជម្លោះផលប្រយោជន៍កើតឡើងរវាងជនជាប់ពីរនាក់ ឬច្រើននាក់ដែលការពារក្តីដោយមេធាវីតែម្នាក់ដែរឬទេ?<br>ជម្លោះផលប្រយោជន៍អ្វី? | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

| ១៧. ការសន្មតជាមុនថាគ្មានទោស | | | | | |
|---|---|---|---|---|---|
| **ជនជាប់ចោទ** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ១៧(ក) តើជនជាប់ចោទបង្ហាញខ្លួននៅមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោសដែរឬទេ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ |
| ១៧(ខ) តើជនជាប់ចោទជាប់ខ្នោះនៅក្នុងអំឡុងពេលសវនាការដែរឬទេ? | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ |
| ១៧(គ) តើចៅក្រមបាននិយាយអំពីភាពមាន ឬគ្មានទោសរបស់ជនជាប់ចោទនៅមុនពេលចេញសាលក្រមដែរឬទេ?<br>ប្រសិនបើមាន តើជាសំដីអ្វី? | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

| | | | | | |
|---|---|---|---|---|---|
| ១៧(ឃ) តើមានអ្វីមួយដែលបង្ហាញថាថៅក្រមទាញពិរុទ្ធភាពពីការនៅស្ងៀមរបស់ជនជាប់ចោទ ដែរឬទេ?<br><br>ប្រសិនបើមាន តើជាអ្វី? | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ |

| ១៨. ការហាមឃាត់ការវិនិច្ឆ័យទោសពីរដង | | | | | |
|---|---|---|---|---|---|
| **ជនជាប់ចោទ** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ១៨(ក) តើមានអ្វីមួយដែលបង្ហាញថាជនជាប់ចោទត្រូវបានជំនុំជម្រះ និងដាក់ទោសចំពោះបទល្មើសនេះពីមុនដែរឬទេ?<br>ប្រសិនបើមាន សូមបញ្ជាក់អំពីការជំនុំជម្រះការដាក់ទោស និងបទល្មើសនោះ៖ | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

| ១៩. ហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ | | | | | |
|---|---|---|---|---|---|
| **ជនជាប់ចោទ** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ១៩(ក) តើជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទល្មើសស្ថិតនៅក្នុងច្បាប់ជាធរមាននៅពេលប្រព្រឹត្តបទល្មើសដែរឬទេ?<br>ប្រសិនបើគ្មាន សូមបញ្ជាក់៖ | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

| ២០. សាលក្រម | | | ☐ មិនដឹង | | |
|---|---|---|---|---|---|
| **ជនជាប់ចោទ** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ២០(ក) តើជនជាប់ចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្ននៅមុនពេលប្រកាសសាលក្រម ដែរឬទេ? | ☐ មាន<br>☐ គ្មាន<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនដឹង |
| ២០(ខ) តើតុលាការសម្រេច | ☐ មាន | ☐ មាន | ☐ មាន | ☐ មាន | ☐ មាន |

| | | | | | |
|---|---|---|---|---|---|
| យ៉ាងដូចម្ដេច? | ពិរុទ្ធភាព<br>☐ គ្មានពិរុទ្ធភាព<br>☐ ស៊ើបសួរម្ដងទៀត<br>☐ មុនអង្គសេចក្ដី | ពិរុទ្ធភាព<br>☐ គ្មានពិរុទ្ធភាព<br>☐ ស៊ើបសួរម្ដងទៀត<br>☐ មុនអង្គសេចក្ដី | ពិរុទ្ធភាព<br>☐ គ្មានពិរុទ្ធភាព<br>☐ ស៊ើបសួរម្ដងទៀត<br>☐ មុនអង្គសេចក្ដី | ពិរុទ្ធភាព<br>☐ គ្មានពិរុទ្ធភាព<br>☐ ស៊ើបសួរម្ដងទៀត<br>☐ មុនអង្គសេចក្ដី | ពិរុទ្ធភាព<br>☐ គ្មានពិរុទ្ធភាព<br>☐ ស៊ើបសួរម្ដងទៀត<br>☐ មុនអង្គសេចក្ដី |
| ២០(គ) តើចៅក្រមបានយោងមាត្រាច្បាប់ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ដែរឬទេ? | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |
| ២០(ឃ) តើចៅក្រមបានយោងភស្តុតាងដែលបានបង្ហាញ ដែរឬទេ? | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |
| ២០(ង) ប្រសិនបើជនជាប់ចោទសារភាពបទល្មើសដែលបានចោទ នៅមុនពេល ឬនៅក្នុងពេលសវនាការ តើចៅក្រមពឹងផ្អែកលើចម្លើយសារភាពនោះជាភស្តុតាងដែរឬទេ? (ប្រសិនបើគ្មានការសារភាព - មិនពាក់ព័ន្ធ) | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ<br>☐ មិនដឹង |

**២១. ទោស** ☐ មិនពាក់ព័ន្ធ ☐ មិនដឹង

| **ជនជាប់ចោទ** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
|---|---|---|---|---|---|
| ១២(ក) តើជនជាប់ចោទត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារដែរឬទេ?<br>រយៈពេលជាប់ពន្ធនាគារសរុប៖<br>រយៈពេលជាប់ពន្ធនាគារ៖<br><br>រយៈពេលព្យួរទោស៖ | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

| | | | | | |
|---|---|---|---|---|---|
| តើរយៈពេលឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានគិតបញ្ចូលក្នុងការអនុវត្តទោសដែរឬទេ? | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ<br>☐ មិនដឹង | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ<br>☐ មិនដឹង |
| ២១(ខ) តើជនជាប់ចោទជាប់ទោសពិន័យ ដែរឬទេ?<br><br>ចំនួនប្រាក់ពិន័យៈ | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |
| ២១(គ) តើជនជាប់ចោទត្រូវបង់ថ្លៃសងជំងឺចិត្ត ដែរឬទេ?<br><br>ចំនួនប្រាក់សងជំងឺចិត្តៈ | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |
| ២១(ឃ) តើមានការអនុវត្តទោសជំនួសដែរឬទេ?<br><br>ប្រសិនបើមាន តើជាអ្វី? | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |
| ២១(ង) តើមានអ្វីដែលបង្ហាញថានៅក្នុងសាលក្រមចៅក្រមយោងភស្តុតាងដែលនៅក្រៅសំណុំរឿង ឬមិនត្រូវបានបង្ហាញនៅក្នុងសវនាការដែរឬទេ?<br>ប្រសិនបើមាន សូមបញ្ជាក់ៈ | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |
| ២១(ច) តើទោសប្បញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌត្រូវបានប្រើនៅក្នុងការដាក់ទោសដែរឬទេ? | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |
| ២១(ឆ) ប្រសិនបើមាន តើការអនុវត្តអនុភាពប្រតិសកម្មនៃ | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

| | | | | | |
|---|---|---|---|---|---|
| ទោសបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ ត្រឹមត្រូវ ដែរឬទេ?<br><br>ប្រសិនបើមិនត្រឹមត្រូវ សូមបញ្ជាក់៖ | ☐<br>មិនពាក់ព័ន្ធ | ☐<br>មិនពាក់ព័ន្ធ | ☐<br>មិនពាក់ព័ន្ធ | ☐<br>មិនពាក់ព័ន្ធ | ☐<br>មិនពាក់ព័ន្ធ |

## ឯកសារភ្ជាប់ទី១ ៖ ជនជាប់ចោទជាអនីតិជន

| ២២. អាយុ | | | | | |
|---|---|---|---|---|---|
| **ជនជាប់ចោទជាអនីតិជន** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ២២(ក) អាយុជនជាប់ចោទនៅពេលប្រព្រឹត្តបទល្មើស | ☐ < ១៤<br>☐ ១៤-១៥<br>☐ ១៦-១៧ | ☐ < ១៤<br>☐ ១៤-១៥<br>☐ ១៦-១៧ | ☐ < ១៤<br>☐ ១៤-១៥<br>☐ ១៦-១៧ | ☐ < ១៤<br>☐ ១៤-១៥<br>☐ ១៦-១៧ | ☐ < ១៤<br>☐ ១៤-១៥<br>☐ ១៦-១៧ |
| ២២(ខ) ប្រសិនបើជនជាប់ចោទមានអាយុក្រោម ១៤ ឆ្នាំនៅពេលប្រព្រឹត្តបទល្មើស តើចៅក្រមសម្រេចឲ្យជនជាប់ចោទរួចទោសភ្លាមៗដែរឬទេ? | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ |

| ២៣. ការឃុំខ្លួនបណ្ដោះអាសន្ន | | | | | |
|---|---|---|---|---|---|
| **ជនជាប់ចោទជាអនីតិជន** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ២៣(ក) អាយុជនជាប់ចោទ នៅពេលឃុំខ្លួនបណ្ដោះអាសន្ន? | ☐ < ១៤<br>☐ ១៤-១៥<br>☐ ១៦-១៧<br>☐ មិនពាក់ព័ន្ធ | ☐ < ១៤<br>☐ ១៤-១៥<br>☐ ១៦-១៧<br>☐ មិនពាក់ព័ន្ធ | ☐ < ១៤<br>☐ ១៤-១៥<br>☐ ១៦-១៧<br>☐ មិនពាក់ព័ន្ធ | ☐ < ១៤<br>☐ ១៤-១៥<br>☐ ១៦-១៧<br>☐ មិនពាក់ព័ន្ធ | ☐ < ១៤<br>☐ ១៤-១៥<br>☐ ១៦-១៧<br>☐ មិនពាក់ព័ន្ធ |
| ២៣(ខ) តើមានអ្វីមួយដែលបង្ហាញថាជនជាប់ចោទមិនត្រូវបានឃុំដាច់ដោយឡែកពីនីតិជនដែរឬទេ? ប្រសិនបើមានសូមបញ្ជាក់៖ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ | ☐ មាន<br>☐ គ្មាន<br>☐ មិនពាក់ព័ន្ធ |

| ២៤. ការជំនុំជម្រះ ☐ មិនពាក់ព័ន្ធ | | | | | |
|---|---|---|---|---|---|
| **ជនជាប់ចោទជាអនីតិជន** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ២៤(ក) តើមានវិធានការការពារភាពឯកជនរបស់ជនជាប់ចោទជាអនីតិជននៅក្នុងសវនាការដែរឬទេ? | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

| | | | | | |
|---|---|---|---|---|---|
| ប្រសិនបើមាន តើជាអ្វី? | | | | | |
| ២៤(ខ) តើចៅក្រមបានផ្តល់ឱកាសឲ្យជនជាប់ចោទជាអនីតិជនបញ្ចេញយោបល់ដោយសេរីដោយខ្លួនឯង ឬតាមរយៈតំណាង ដូចជាមេធាវី ឬឪពុកម្តាយ ដែរឬទេ? | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

| **២៥. ទោស** | ☐ មិនពាក់ព័ន្ធ | | ☐ មិនដឹង | | |
|---|---|---|---|---|---|
| **ជនជាប់ចោទជាអនីតិជន** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ២៥(ក) តើចៅក្រមបានយោងមាត្រា ៣៨ ឬ ៣៩ នៃក្រមព្រហ្មទណ្ឌនៅពេល ដាក់ទោស ជនជាប់ចោទ ដែរឬទេ? | ☐ មាត្រា ៣៨<br>☐ មាត្រា ៣៩<br>☐ មាត្រាទាំងពីរ<br>☐ គ្មានទាំងពីរ<br>☐ មិនពាក់ព័ន្ធ | ☐ មាត្រា ៣៨<br>☐ មាត្រា ៣៩<br>☐ មាត្រាទាំងពីរ<br>☐ គ្មានទាំងពីរ<br>☐ មិនពាក់ព័ន្ធ | ☐ មាត្រា ៣៨<br>☐ មាត្រា ៣៩<br>☐ មាត្រាទាំងពីរ<br>☐ គ្មានទាំងពីរ<br>☐ មិនពាក់ព័ន្ធ | ☐ មាត្រា ៣៨<br>☐ មាត្រា ៣៩<br>☐ មាត្រាទាំងពីរ<br>☐ គ្មានទាំងពីរ<br>☐ មិនពាក់ព័ន្ធ | ☐ មាត្រា ៣៨<br>☐ មាត្រា ៣៩<br>☐ មាត្រាទាំងពីរ<br>☐ គ្មានទាំងពីរ<br>☐ មិនពាក់ព័ន្ធ |
| ២៥(ខ) តើមានអ្វីមួយដែលបង្ហាញថាចៅក្រមពិចារណាដាក់ទោសមិនមែនពន្ធនាគារ? ប្រសិនបើមាន សូមបញ្ជាក់៖ | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

## ឯកសារភ្ជាប់ទី២ ៖ សវនាការករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ[28]

| ២៦. ព័ត៌មានទូទៅ | |
|---|---|
| ២៦(ក) តើសវនាការត្រូវបានពន្យារពេលពីមុនមកដែរឬទេ? | ☐ មាន ☐ គ្មាន<br>ប្រសិនបើមាន សូមបញ្ជាក់បន្ថែម៖ |
| ២៦(ខ) ច្បាប់ពាក់ព័ន្ធ៖ | |
| សូមរៀបរាប់អំពីអង្គហេតុឲ្យបានក្បោះក្បាយ៖ | |

| ២៧. ព័ត៌មានអំពីជនជាប់ចោទ | | | | | |
|---|---|---|---|---|---|
| **ជនជាប់ចោទ** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ២៧(ក) អាយុ | ☐ ០-១៤<br>☐ ១៥-១៧<br>☐ ១៨-២៥<br>☐ ២៦-៣៥<br>☐ ៣៦-៤៥<br>☐ >៤៦ | ☐ ០-១៤<br>☐ ១៥-១៧<br>☐ ១៨-២៥<br>☐ ២៦-៣៥<br>☐ ៣៦-៤៥<br>☐ >៤៦ | ☐ ០-១៤<br>☐ ១៥-១៧<br>☐ ១៨-២៥<br>☐ ២៦-៣៥<br>☐ ៣៦-៤៥<br>☐ >៤៦ | ☐ ០-១៤<br>☐ ១៥-១៧<br>☐ ១៨-២៥<br>☐ ២៦-៣៥<br>☐ ៣៦-៤៥<br>☐ >៤៦ | ☐ ០-១៤<br>☐ ១៥-១៧<br>☐ ១៨-២៥<br>☐ ២៦-៣៥<br>☐ ៣៦-៤៥<br>☐ >៤៦ |
| ២៧(ខ) ភេទ | ☐ ប្រុស<br>☐ ស្រី | ☐ ប្រុស<br>☐ ស្រី | ☐ ប្រុស<br>☐ ស្រី | ☐ ប្រុស<br>☐ ស្រី | ☐ ប្រុស<br>☐ ស្រី |
| ២៧(គ) មុខរបរ | ☐ មេបន<br>☐ អ្នកទេសចរណ៍<br>☐ អ្នករកស៊ីផ្លូវភេទ<br>☐ ផ្សេងៗ សូមបញ្ជាក់៖ | ☐ មេបន<br>☐ អ្នកទេសចរណ៍<br>☐ អ្នករកស៊ីផ្លូវភេទ<br>☐ ផ្សេងៗ សូមបញ្ជាក់៖ | ☐ មេបន<br>☐ អ្នកទេសចរណ៍<br>☐ អ្នករកស៊ីផ្លូវភេទ<br>☐ ផ្សេងៗ សូមបញ្ជាក់៖ | ☐ មេបន<br>☐ អ្នកទេសចរណ៍<br>☐ អ្នករកស៊ីផ្លូវភេទ<br>☐ ផ្សេងៗ សូមបញ្ជាក់៖ | ☐ មេបន<br>☐ អ្នកទេសចរណ៍<br>☐ អ្នករកស៊ីផ្លូវភេទ<br>☐ ផ្សេងៗ សូមបញ្ជាក់៖ |

[28] ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨។

| | | | | | |
|---|---|---|---|---|---|
| | ______<br>☐ មិនដឹង | ______<br>☐ មិនដឹង | ______<br>☐ មិនដឹង | ______<br>☐ មិនដឹង | ______<br>☐ មិនដឹង |
| ២៧(ឃ) សញ្ជាតិ | ☐ កម្ពុជា<br>☐ វៀត<br>ណាម<br>☐ ថៃ<br>☐ ឡាវ<br>☐ ផ្សេងៗ<br>សូមបញ្ជាក់<br>______<br>☐ មិនដឹង | ☐ កម្ពុជា<br>☐ វៀត<br>ណាម<br>☐ ថៃ<br>☐ ឡាវ<br>☐ ផ្សេងៗ<br>សូមបញ្ជាក់<br>______<br>☐ មិនដឹង | ☐ កម្ពុជា<br>☐ វៀត<br>ណាម<br>☐ ថៃ<br>☐ ឡាវ<br>☐ ផ្សេងៗ<br>សូមបញ្ជាក់<br>______<br>☐ មិនដឹង | ☐ កម្ពុជា<br>☐ វៀត<br>ណាម<br>☐ ថៃ<br>☐ ឡាវ<br>☐ ផ្សេងៗ<br>សូមបញ្ជាក់<br>______<br>☐ មិនដឹង | ☐ កម្ពុជា<br>☐ វៀត<br>ណាម<br>☐ ថៃ<br>☐ ឡាវ<br>☐ ផ្សេងៗ<br>សូមបញ្ជាក់<br>______<br>☐ មិនដឹង |
| ២៧(ង) តើមានអ្វីមួយដែលបង្ហាញថាជនជាប់ចោទជាសមាជិកគ្រួសារជនរងគ្រោះដែរឬទេ?<br>ប្រសិនបើមានសូមបញ្ជាក់៖ | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

| **២៨. ព័ត៌មានអំពីជនរងគ្រោះ** | | | | | |
|---|---|---|---|---|---|
| **ជនរងគ្រោះ** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ២៨(ក) អាយុ | ☐ ០-១៤<br>☐ ១៥-១៧<br>☐ ១៨-២៥<br>☐ ២៦-៣៥<br>☐ ៣៦-៤៥<br>☐ >៤៦ | ☐ ០-១៤<br>☐ ១៥-១៧<br>☐ ១៨-២៥<br>☐ ២៦-៣៥<br>☐ ៣៦-៤៥<br>☐ >៤៦ | ☐ ០-១៤<br>☐ ១៥-១៧<br>☐ ១៨-២៥<br>☐ ២៦-៣៥<br>☐ ៣៦-៤៥<br>☐ >៤៦ | ☐ ០-១៤<br>☐ ១៥-១៧<br>☐ ១៨-២៥<br>☐ ២៦-៣៥<br>☐ ៣៦-៤៥<br>☐ >៤៦ | ☐ ០-១៤<br>☐ ១៥-១៧<br>☐ ១៨-២៥<br>☐ ២៦-៣៥<br>☐ ៣៦-៤៥<br>☐ >៤៦ |
| ២៨(ខ) ភេទ | ☐ ប្រុស<br>☐ ស្រី | ☐ ប្រុស<br>☐ ស្រី | ☐ ប្រុស<br>☐ ស្រី | ☐ ប្រុស<br>☐ ស្រី | ☐ ប្រុស<br>☐ ស្រី |
| ២៨(គ) មុខរបរ | ☐ អ្នក<br>ម៉ាស្សា<br>☐ អ្នករក<br>ស៊ីផ្លូវភេទ<br>☐ អ្នករត់តុ<br>☐ អ្នកធ្វើ | ☐ អ្នក<br>ម៉ាស្សា<br>☐ អ្នករក<br>ស៊ីផ្លូវភេទ<br>☐ អ្នករត់តុ<br>☐ អ្នកធ្វើ | ☐ អ្នក<br>ម៉ាស្សា<br>☐ អ្នករក<br>ស៊ីផ្លូវភេទ<br>☐ អ្នករត់តុ<br>☐ អ្នកធ្វើ | ☐ អ្នក<br>ម៉ាស្សា<br>☐ អ្នករក<br>ស៊ីផ្លូវភេទ<br>☐ អ្នករត់តុ<br>☐ អ្នកធ្វើ | ☐ អ្នក<br>ម៉ាស្សា<br>☐ អ្នករក<br>ស៊ីផ្លូវភេទ<br>☐ អ្នករត់តុ<br>☐ អ្នកធ្វើ |

| | | | | | |
|---|---|---|---|---|---|
| | ការតាមផ្ទះ: ☐ អ្នកលីសែងតវ៉ាន់ ☐ កម្មករសំណង់ ☐ ផ្សេងៗ សូមបញ្ជាក់៖ ____ | ការតាមផ្ទះ: ☐ អ្នកលីសែងតវ៉ាន់ ☐ កម្មករសំណង់ ☐ ផ្សេងៗ សូមបញ្ជាក់៖ ____ | ការតាមផ្ទះ: ☐ អ្នកលីសែងតវ៉ាន់ ☐ កម្មករសំណង់ ☐ ផ្សេងៗ សូមបញ្ជាក់៖ ____ | ការតាមផ្ទះ: ☐ អ្នកលីសែងតវ៉ាន់ ☐ កម្មករសំណង់ ☐ ផ្សេងៗ សូមបញ្ជាក់៖ ____ | ការតាមផ្ទះ: ☐ អ្នកលីសែងតវ៉ាន់ ☐ កម្មករសំណង់ ☐ ផ្សេងៗ សូមបញ្ជាក់៖ ____ |
| ២៨(ឃ) សញ្ជាតិ | ☐ កម្ពុជា ☐ វៀតណាម ☐ ថៃ ☐ ឡាវ ☐ ផ្សេងៗ សូមបញ្ជាក់៖ ____ ☐ មិនដឹង | ☐ កម្ពុជា ☐ វៀតណាម ☐ ថៃ ☐ ឡាវ ☐ ផ្សេងៗ សូមបញ្ជាក់៖ ____ ☐ មិនដឹង | ☐ កម្ពុជា ☐ វៀតណាម ☐ ថៃ ☐ ឡាវ ☐ ផ្សេងៗ សូមបញ្ជាក់៖ ____ ☐ មិនដឹង | ☐ កម្ពុជា ☐ វៀតណាម ☐ ថៃ ☐ ឡាវ ☐ ផ្សេងៗ សូមបញ្ជាក់៖ ____ ☐ មិនដឹង | ☐ កម្ពុជា ☐ វៀតណាម ☐ ថៃ ☐ ឡាវ ☐ ផ្សេងៗ សូមបញ្ជាក់៖ ____ ☐ មិនដឹង |

| ២៩. សិទ្ធិជនរងគ្រោះ | ☐ មិនពាក់ព័ន្ធ | |
|---|---|---|
| ២៩(ក) តើចៅក្រមបានប្រាប់ជនរងគ្រោះអំពីសិទ្ធិរបស់ខ្លួន ដែរឬទេ? | ☐ មាន<br>សូមបញ្ជាក់៖ | ☐ គ្មាន |
| ២៩(ខ) តើជនរងគ្រោះផ្តល់កសិណ ដែរឬទេ? | ☐ មាន | ☐ គ្មាន |
| ២៩(គ) តើមានអ្វីដែលបង្ហាញថាតុលាការបង្គាប់ឲ្យជនរងគ្រោះផ្តល់កសិណប្រឆាំងនឹងឆន្ទៈរបស់ខ្លួន ដែរឬទេ? | ☐ មាន<br>សូមបញ្ជាក់៖ | ☐ គ្មាន |
| ២៩(ឃ) តើមានអ្វីមួយដែលបង្ហាញថាជនរងគ្រោះកុហកអំពីអាយុរបស់ខ្លួន ដែរឬទេ? | ☐ មាន<br>សូមបញ្ជាក់៖ | ☐ គ្មាន |
| ២៩(ង) តើមានអ្វីមួយដែលបង្ហាញថាជនរងគ្រោះមានទំនាក់ទំនង (ផ្ទាល់ ឬមិនផ្ទាល់) | ☐ មាន | ☐ គ្មាន |

| | |
|---|---|
| ជាមួយជនជាប់ចោទនៅចន្លោះពេលដែលជនជាប់ចោទត្រូវបានចាប់ខ្លួន និងសវនាការដែរឬទេ? | សូមបញ្ជាក់៖ |
| ២៩(ច) តើមេធាវីជនរងគ្រោះស្នើសុំការពារអត្តសញ្ញាណជនរងគ្រោះជាសំងាត់ (ឧ. តើមេធាវីស្នើសុំសវនាការអសាធារណៈ ឬប្រើរបាំង) ដែរឬទេ? | ☐ មាន ☐ គ្មាន<br>ប្រសិនបើមាន តើចៅក្រមឯកភាពតាមការស្នើសុំ ដែរឬទេ?<br>☐ មាន ☐ គ្មាន |
| ២៩(ឆ) តើចៅក្រមប្រព្រឹត្តឥរិយាបថសមរម្យចំពោះករណីរសើប ដែរឬទេ? | ☐ មាន ☐ គ្មាន ☐ មិនពាក់ព័ន្ធ<br>សូមបញ្ជាក់៖ |

| ៣០. ជនរងគ្រោះជាស្ត្រី | ☐ មិនពាក់ព័ន្ធ | | | | |
|---|---|---|---|---|---|
| ៣០(ក) តើមានបុគ្គលិកតុលាការជាស្ត្រី ដែរឬទេ? | ☐ មាន ☐ គ្មាន<br>សូមបញ្ជាក់៖ | | | | |
| **ជនរងគ្រោះជាស្ត្រី** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ៣០(ខ) តើជនរងគ្រោះទទួលជំនួយពីមេធាវីជាស្ត្រី ដែរឬទេ?<br>សូមបញ្ជាក់៖ | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

| ៣១. សាក្សី | ☐ មិនពាក់ព័ន្ធ |
|---|---|
| ៣១(ក) តើមានអ្វីមួយដែលបង្ហាញជនជាប់ចោទធ្វើទុក្ខបុកម្នេញសាក្សី ដែរឬទេ? | ☐ មាន ☐ គ្មាន<br>សូមបញ្ជាក់៖ |

| ៣២. ច្បាប់ | |
|---|---|
| ៣២(ក) តើ ចៅក្រមបាននិយាយ ឬបញ្ចេញយោបល់បង្ហាញថាខ្លួនភ័ន្តច្រឡំអំពីករណីជួញដូរមនុស្ស ឬករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ | ☐ មាន ☐ គ្មាន<br>សូមបញ្ជាក់៖ |

| | |
|---|---|
| ដែរឬទេ? | |
| ៣២(ខ) តើអង្គហេតុឆ្លុះបញ្ចាំងពីធាតុផ្សំនៃបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទដែលជនជាប់ចោទត្រូវបានចោទប្រកាន់ដែរឬទេ? | ☐ មាន ☐ គ្មាន<br>សូមបញ្ជាក់៖ |

| ៣៣. ជនរងគ្រោះជាអនីតិជន | | | ☐ មិនពាក់ព័ន្ធ | | |
|---|---|---|---|---|---|
| **ជនរងគ្រោះជាអនីតិជន** | **ទី១** | **ទី២** | **ទី៣** | **ទី៤** | **ទី៥** |
| ៣៣(ក) នៅពេលនិយាយទៅកាន់ជនរងគ្រោះជាអនីតិជន តើចៅក្រមមានការប្រុងប្រយ័ត្នជាពិសេស ដែរឬទេ? សូមបញ្ជាក់៖ | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |
| ៣៣(ខ) តើមានអ្វីមួយដែលបង្ហាញថា អនីតិជនចង់ឲ្យឪពុកម្ដាយ/អាណាព្យាបាលខ្លួនមានវត្តមាននៅក្នុងសវនាការ ដែរឬទេ?<br>ប្រសិនបើមាន តើឪពុកម្ដាយ/អាណាព្យាបាល មានវត្តមាននៅក្នុងសវនាការ ដែរឬទេ? សូមបញ្ជាក់៖ | ☐ មាន<br>☐ គ្មាន<br>☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន<br>☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន<br>☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន<br>☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន<br>☐ មាន<br>☐ គ្មាន |
| ៣៣(គ) តើមានរបាំងការពារអនីតិជនពីការផ្ដល់កសិណជាសាធារណៈ ដែរឬទេ? | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន | ☐ មាន<br>☐ គ្មាន |

# ឧបសម្ព័ន្ធទី២ ៖ ក្រមសីលធម៌មន្ត្រីសង្កេតការណ៍សវនាការ

## ការរៀបចំ និងត្រៀមទុកជាមុន

### ករណីយកិច្ចទូទៅ

*ការរក្សាការសម្ងាត់*

- កម្មវិធីសង្កេតការណ៍សវនាការគោរពយ៉ាងពេញលេញនូវគោលការណ៍រក្សាការសម្ងាត់ ដោយមិនផ្សព្វផ្សាយព័ត៌មានសម្ងាត់។
- មន្ត្រីសង្កេតការណ៍សវនាការទាំងអស់ត្រូវយល់ដឹងឲ្យបានទូលំទូលាយ នូវគោលការណ៍រក្សាការសម្ងាត់ទាក់ទងនឹងការសង្កេតការណ៍សវនាការ ពាក់ព័ន្ធនឹងព័ត៌មានទាំងឡាយដែលយកបានពីតុលាការ ក៏ដូចជាព័ត៌មានទាក់ទងទៅនឹងដំណើរការ និងការគ្រប់គ្រងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ។

### មុនពេលអនុវត្តគម្រោងសង្កេតការណ៍សវនាការ

*ការវាយតម្លៃបឋម*

នៅមុនពេលដំណើរការការសង្កេតការណ៍សវនាការ មន្ត្រីសង្កេតការណ៍សវនាការនោះ ត្រូវមានការយល់ដឹងឲ្យបានច្បាស់លាស់អំពី៖

- យន្តការតុលាការនៅក្នុងប្រទេសកម្ពុជា
- ឋានានុក្រម និងយុត្តាធិការតុលាការ
- កម្រិតនៃការសហការ និង/ឬ ការចូលរួម ដែលសង្ឃឹមថានឹងទទួលបានពី ក) ចៅក្រម ខ) ព្រះរាជ អាជ្ញា គ) មេធាវីជនជាប់ចោទ និង ឃ) រដ្ឋាភិបាល។

*សេចក្តីជូនដំណឹង*

- សេចក្តីសម្រេចអំពីអ្នក ដែលនឹងទទួលសេចក្តីជូនដំណឹងអំពីការសង្កេតការណ៍សវនាការជាផ្លូវការ និង/ឬ មិនផ្លូវការ ត្រូវធ្វើឡើងមុនការសង្កេតការណ៍សវនាការចាប់ផ្តើម និងត្រូវសម្រេចដោយប្រធានគម្រោង ស្របតាមគោលបំណងរបស់គម្រោង។
- ប្រសិនបើ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាជូនដំណឹងទៅតុលាការ អំពីការសង្កេតការណ៍សវនាការ សេចក្តីជូនដំណឹងនោះត្រូវតែអនុលោមទៅតាមការអនុវត្តជាទូទៅ។
- មន្ត្រីសង្កេតការណ៍សវនាការ ត្រូវតែកត់ត្រាទុកនូវបុគ្គលទាំងឡាយណាដែលខ្លួនបានផ្តល់ព័ត៌មាន និង/ឬ ពិគ្រោះយោបល់ជាមួយមុន និង/ឬ ក្នុងអំឡុងពេលសវនាការ។ កំណត់ត្រាទាំងនេះរួមមាន សេចក្តីលំអិត និងទម្រង់នៃសេចក្តីជូនដំណឹង។
- ថាតើមានអនុស្សរណៈយោគយល់គ្នាមួយ ត្រូវបានចុះហត្ថលេខារវាងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងក្រសួងយុត្តិធម៌ដែរឬយ៉ាងណា។

## នៅមុនពេលសង្កេតការណ៍សវនាការនីមួយៗ

### *ការវាយតម្លៃបឋម*

ព័ត៌មានខាងក្រោមត្រូវប្រមូលមុនពេលសវនាការនីមួយៗ ឬ នៅពេលដែលមិនអាចធ្វើដូច្នេះបាន គឺត្រូវមានការកត់ចំណាំ និងស្រាវជ្រាវ ធ្វើឡើងបន្ទាប់ ឬក្នុងអំឡុងពេលសវនាការ ៖

- ថាតើមានរបាយការណ៍ពាក់ព័ន្ធនឹងសវនាការនៅកម្ពុជាស្រដៀងគ្នាដែរឬទេ។
- ថាតើកម្រងច្បាប់ និងសន្ធិសញ្ញាអន្តរជាតិណាមួយ ដែលទាក់ទងនឹងសវនាការកំពុងសង្កេតការណ៍នេះ។
- ថាតើច្បាប់ជាតិ និងច្បាប់នីតិវិធីណាខ្លះទាក់ទងនឹងករណីដែលកំពុងសង្កេតការណ៍នេះ។
- ថាតើមានបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញ ដែលពាក់ព័ន្ធ។

### *សេចក្តីជូនដំណឹង*

- អ្នកសង្កេតការណ៍សវនាការទាំងអស់ត្រូវចងក្រងឯកសារលំអិតអំពីការប្រឹក្សាយោបល់ជាមួយ ក) រដ្ឋាភិបាល ខ) ស្មាក្តីភាគីខាងចុងចោទ គ) ព្រះរាជអាជ្ញា ឃ) ចៅក្រម ង) ក្រឡាបញ្ជី ឬ ច)ភាគី ពាក់ព័ន្ធដទៃទៀត ។

### *ការចូលទៅកាន់តុលាការ*

មន្ត្រីសង្កេតការណ៍សវនាការទាំងអស់ ត្រូវចុះឈ្មោះនៅតុលាការមុនធ្វើការសង្កេតការណ៍ ប្រសិនបើចង់ស្នើសុំឯកសារ ឬចូលក្នុងតុលាការ។ អ្នកសង្កេតការណ៍សវនាការទាំងអស់ត្រូវរក្សាទុកឯកសារផ្លូវការទាំងអស់ ។

## នៅក្នុងអំឡុងពេលសវនាការ

### *គោលការណ៍ទូទៅ*

- ត្រូវទៅដល់តុលាការឲ្យបានមុនម៉ោង ដើម្បីមានពេលវេលាគ្រប់គ្រាន់នឹងចូលទៅកាន់តុលាការ ស្វែងរកបន្ទប់សវនាការ និងរកកន្លែងអង្គុយសមរម្យ។ ចំណុចនេះត្រូវពិពណ៌នានៅក្នុងទម្រង់របាយការណ៍។
- មន្ត្រីសង្កេតការណ៍សវនាការត្រូវរៀបចំខ្លួន និងអាចពន្យល់ឲ្យបានច្បាស់អំពីមូលដ្ឋានច្បាប់ គោលបំណង និងទិសដៅនៃគម្រោង ដល់បុគ្គលិកតុលាការ និងមន្ត្រីច្បាប់នានា។

### *អត្តសញ្ញាណ*

- ត្រូវពាក់អត្តសញ្ញាណប័ណ្ណសម្គាល់ជាមន្ត្រីសង្កេតការណ៍សវនាការនៅគ្រប់ពេលវេលា និង បង្ហាញអត្តសញ្ញាណប័ណ្ណនេះទៅមន្ត្រីតុលាការប្រសិនបើមានការស្នើសុំឲ្យបង្ហាញ។
- ប្រសិនបើមានបញ្ហាណាមួយកើតឡើង ក្នុងការចូលទៅក្នុងតុលាការ ត្រូវតែធ្វើការពន្យល់ដល់មន្ត្រីមូលដ្ឋានឲ្យស្គាល់គម្រោងសង្កេតការណ៍សវនាការ។

### *ការប្រព្រឹត្តក្នុងតុលាការ*

- ត្រូវប្រកាន់ខ្ជាប់នូវអត្តចរិតជាមន្ត្រីសង្កេតការណ៍សវនាការ គ្រប់ពេលវេលា។
- ត្រូវមានចំណេះដឹងច្បាប់ខ្ពស់ រួមទាំងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។
- ត្រូវសម្រេចថាអង្គុយកន្លែងណា ដើម្បីធានាបាននូវភាពមិនលំអៀង និងងាយស្រួលក្នុងការសង្កេតការណ៍សវនាការ។ មន្ត្រីសង្កេតការណ៍គួរជ្រើសរើសកន្លែងអង្គុយ ដែលគេអាចមើលឃើញ ជាកន្លែងអព្យាក្រឹត នៅក្នុងបន្ទប់សវនាការ ។ មន្ត្រីសង្កេតការណ៍សវនាការត្រូវបង្ហាញអាកប្បកិរិយាគួរសម និងសុភាពចំពោះមន្ត្រីតុលាការ និងភាគីទាំងអស់ពាក់ព័ន្ធរឿងក្តី។
- ត្រូវស្លៀកសម្លៀកបំពាក់សមរម្យ។
- ត្រូវទៅដល់តុលាការទាន់ពេលវេលា។
- ត្រូវរក្សានូវការគោរពក្នុងគ្រប់ទំនាក់ទំនងជាមួយមន្ត្រីតុលាការ និងអ្នកដទៃទៀត។
- ត្រូវធ្វើការកត់ត្រាដោយចំហក្នុងអំឡុងពេលសវនាការ ដោយផ្អែកលើតារាងសង្កេតការណ៍សវនាការរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដោយមិនធ្វេសប្រហែសក្នុងពេលសវនាការ។
- ត្រូវមានភាពច្នឹក និងយល់ច្បាស់អំពីតារាងសង្កេតការណ៍សវនាការនិងសេចក្តីណែនាំអំពីការសង្កេតការណ៍សវនាការ ។
- ត្រូវធានាសុវត្ថិភាព និងរក្សាការសម្ងាត់នូវរាល់កំណត់ត្រាទាំងអស់ ។
- ត្រូវធ្វើការណែនាំខ្លួនទៅកាន់តុលាការតាមរយៈភាគីមួយដែលអព្យាក្រឹត (ប្រសិនយើងនៅបន្តសង្កេតការណ៍ក្នុងបន្ទប់សវនាការ រហូតដល់ពេលបញ្ចប់សវនាការទាំងអស់) ដើម្បីបង្កើននូវតម្លាភាព ។

### *ភាពមិនលម្អៀង និងភាពមិនជ្រៀតជ្រែក*

- ត្រូវអង្គុយនៅកន្លែងសមរម្យមួយនៅក្នុងបន្ទប់សវនាការ ដែលអាចសង្កេតបាន ឮបាន និងអាចតាមមើលបាននូវគ្រប់ចំណុចទាំងអស់នៃសវនាការ។
- មិនត្រូវអង្គុយជាប់ជាមួយភាគីជនជាប់ចោទ ឬព្រះរាជអាជ្ញា។
- មិនត្រូវសួរអ្នកច្បាប់អំពីគំនិតរបស់ពួកគេ ឬឲ្យគេផ្តល់ការណែនាំអំពីរឿងក្តីណាមួយ។
- ជៀសវាងជ្រៀតជ្រែកចូលដំណើរការសវនាការ ។
- មិនត្រូវបង្អាក់ដំណើរការសវនាការណាមួយ ឬនិយាយទៅកាន់មន្ត្រីច្បាប់ ឬអ្នកចូលរួមសវនាការ។
- មិនត្រូវធ្វើអន្តរាគមន៍នៅក្នុងសវនាការ ឬប៉ុនប៉ងជះឥទ្ធិពលទៅលើលទ្ធផលនៃរឿងក្តីក្នុងគ្រប់រូបភាព។
- មិនត្រូវបង្ហាញភាពលំអៀង ឬការគាំទ្រណាមួយដល់ភាគីនៃរឿងក្តី។

- មិនត្រូវសំដែងយោបល់ណាមួយអំពីដំណើរការសវនាការ ទោះជានៅក្នុង ឬនៅក្រៅបន្ទប់សវនាការក៏ដោយ។ នៅពេលមានអ្នកណាម្នាក់សួរសំណួរជាក់លាក់ ត្រូវឆ្លើយតបដោយពន្យល់ អំពីតួនាទីជាមន្ត្រីសង្កេតការណ៍សវនាការ និងអំពីក្រមសីលធម៌នៃភាពមិនលំអៀង ។
- មិនគួរធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈណាមួយឡើយ ។
- ប្រសិនបើអាច គួរកត់ត្រាទុកនូវរាល់អត្ថបទសារព័ត៌មានណា ដែលពាក់ព័ន្ធទៅនឹងសវនាការ និង ត្រូវដឹងអំពីរបៀបឃ្លាំមើលដែលងាយអនុវត្ត ដើម្បីទុកជាប្រយោជន៍ដល់មន្ត្រីសង្កេតការណ៍សវនាការនាពេលអនាគត ។